ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**

**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**

**សាធារណៈ**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៦៤**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វិចស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent DE WILDE D'ESTMAEL)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី អាឡិចសាន់ដ្រើស ប្រេហ្សង់ទី

*(Ms. Alexandre PREZANTI)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គឹម ម៉េងឃី

កញ្ញា ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សណាព្រូស

*(Ms. Fabienne Trusse-Naprous)*

កញ្ញា ចេស្ស៊ីកា ហ្វីណែល

*(Ms. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### វេជ្ជបណ្ឌិត ឈឹម សុធារ៉ា

សួរដោយ ប្រធានអង្គជំនុំ ផ្ដើមពី ........ ទំព័រ ២
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ........ ទំព័រ ៩
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........ ទំព័រ ១៤
សួរដោយ លោក សេង ប៊ុនឃាង ផ្ដើមពី ........ ទំព័រ ១៩
សួរដោយ លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........ ទំព័រ ២០
សួរដោយ លោក ហុង គឹមសួន ផ្ដើមពី ........ ទំព័រ ២៨
សួរដោយ លោក អាឡាំង វ៉ែនណឺ ផ្ដើមពី ........ ទំព័រ ៣២
សួរដោយ លោក ការ សាវុត្ថ ផ្ដើមពី ........ ទំព័រ ៣៨
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី ........ ទំព័រ ៤១

## បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សាវេស | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឈឹម សុធារ៉ា | ខ្មែរ |
| លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រូស | បារាំង |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកកាន់បន្ទប់សវនាការ)*

[០៩:០៨:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយតាមកាលវិភាគដំណើរការសវនាការដែលបានគ្រោងទុកនៅព្រឹកនេះយើងនឹងស្តាប់នូវសេចក្តីបង្ហាញរបស់សាក្សី និងជាអ្នកជំនាញ ផ្នែកខាងសុខភាពផ្លូវចិត្ត ឬខាងចិត្តសាស្ត្ររបស់-- ដែលស្នើឡើងដោយមេធាវីខាងអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

ក្រឡាបញ្ជី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន និងអវត្តមានភាគីនិងបុគ្គលដែលត្រូវកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ លោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា មានវត្តមាន ។ អ្នកជំនាញមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹង ជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ អ្នកជំនាញបានស្បថរួចហើយ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការអញ្ជើញវេជ្ជបណ្ឌិត ឈឹម សុធារ៉ា ចូលមកកាន់សាលសវនាការ ។

*(អ្នកជំនាញចូលមកក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

អញ្ជើញក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។ ជាថ្មីម្តងទៀតដោយរបាយការណ៍អម្បាញ់មិញនេះ មិនមានសំឡេង ឬក៏ការកត់ត្រាប្រតិចារឹកនៅក្នុងដំណើរការសវនាការទេ មូលហេតុដាច់ប្រព័ន្ធចរន្តអគ្គិសនី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅក្នុងថ្ងៃ នេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯអ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ លោកវេជ្ជ បណ្ឌិត ឈឹម សុធារ៉ា មានវត្តមាន ។ លោកវេជ្ជបណ្ឌិតមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ អ្នកជំនាញបានស្បថរួចហើយ ។

[០៩:១២:៤៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អរុណសួស្តី អ្នកជំនាញ! តើលោកមានឈ្មោះ ឈឹម សុធារ៉ា អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំមានឈ្មោះ ឈឹម សុធារ៉ា ពិតមែន ។

**ស៖** លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ៥៥ឆ្នាំ ។

**ស៖** លោកវេជ្ជបណ្ឌិត អាចបង្អង់បន្តិចនៅពេលដែលមានភ្លើងក្រហមនៅក្បាលមីក្រូ ចាំផ្តើមនិយាយទើបសំឡេងរបស់លោកចូលក្នុងប្រព័ន្ធនេះ ហើយនិងមានកំណត់ត្រានៅក្នុងប្រតិចារឹកនៅដំណើរការសវនាការនេះផង ។ តើលោកប្រកបមុខរបរអ្វីសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំជាវេជ្ជបណ្ឌិតឯកទេសខាងជំងឺផ្លូវចិត្ត ហើយគឺជានាយកប្រតិបត្តិនៃអង្គការ ចិត្តសង្គមអន្តរវប្បធម៌កម្ពុជា ហៅកាត់ថា អង្គការ *ធីភីអូ* (TPO) កម្ពុជា ។

**ស៖** តើលោករស់នៅទីកន្លែងណាសព្វថ្ងៃ?

**ឆ៖** ខ្ញុំបាទរស់នៅផ្ទះលេខ ៩៧E1 ផ្លូវហ្សាលដឺហ្គោល សង្កាត់អូរឫស្សីទី៣ ខណ្ឌ៧មករា ភ្នំពេញ ។

**ស៖** លោក ឈឹម សុធារ៉ា តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា លោកមិនមានចំណងញាតិលោហិត ញាតិពន្ធ ឬជាសហព័ទ្ធជាមួយនឹងភាគីនៅក្នុងរឿងក្តីនេះទេ ហើយមុននឹងចូលមកកាន់សាលសវនាការនេះថាលោកបានស្បថតាមជំនឿសាសនារួចហើយ តើជាការពិតមែនដែរឬទេ?

**ឆ៖** បាទ,គឺជាការពិត ។

**ស៖** តើលោកសព្វថ្ងៃនេះជាគ្រូបង្រៀនផ្នែកចិត្តសាស្ត្រ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រ សុខាភិបាលនៃប្រទេសកម្ពុជាពិតមែនដែរឬទេ?

**ឆ៖** បាទ, ពិតមែន ។

**ស៖** តើលោកបានបញ្ចប់ការសិក្សារបស់លោក និងទទួលសញ្ញាបត្រផ្នែកវេជ្ជបណ្ឌិតនៅប្រទេសកម្ពុជាពីឆ្នាំណាដែរ?

[០៩:១៥:៣៤]

**ឆ៖** នៅឆ្នាំ១៩៩២ ។

**ស៖** ក្រោយពីការបញ្ចប់ការសិក្សានៅកម្ពុជា តើលោកបានសិក្សាបន្តថ្នាក់អនុបណ្ឌិតផ្នែកចិត្តសាស្ត្រចិត្តវិទ្យានៅសកលវិទ្យាល័យ ញូវសៅវែល នៅប្រទេសអូស្ត្រាលី ពិតមែនដែរឬទេ?

**ឆ៖** បាទ, ពិតមែន ។

**ស៖** តើលោកប្រកបអាជីពជាវេជ្ជបណ្ឌិតផ្នែកសុខភាពផ្លូវចិត្តនេះ អស់រយៈពេលប៉ុន្មានឆ្នាំមកហើយ?

**ឆ៖** អស់រយៈពេលប្រហែលដប់ប្រាំឆ្នាំហើយ ។

**ស៖** តើវាមានមូលហេតុអ្វីខ្លះទៅដែលជំរុញឲ្យលោកសម្រេចចិត្តសិក្សាលើជំនាញមួយនេះ?

**ឆ៖** បាទ, តាំងពីដើមឡើយខ្ញុំបាទមិនដែលមានចិត្តចង់សិក្សាផ្នែកវិទ្យាពេទ្យ ឬក៏វេជ្ជបណ្ឌិតទេ ប៉ុន្តែក្រោយពីសម័យខ្មែរក្រហមមក ប្រទេសកម្ពុជាយើងត្រូវបានបំផ្លិចបំផ្លាញគ្រប់បែបយ៉ាង មានវេជ្ជ-បណ្ឌិតតិចណាស់ដែលនៅរស់ក្រោយពីសម័យសង្គ្រាម ។ នៅពេលនោះ ប្រសិនបើអ្នកណាដែលរងនូវការឈឺចាប់ ឬក៏អ្នកជំងឺ ឬក៏បងប្អូនខ្ញុំបាទ ក្តីដែលមានជំងឺគឺមានការពិបាកក្នុងការទៅទទួលការព្យាបាលមែនទែន ពីព្រោះប្រទេសយើងទាំងមូលខ្វះវេជ្ជបណ្ឌិតដែលផ្តល់ការថែទាំសុខភាព ។

ដូច្នេះ ទើបខ្ញុំសម្រេចចិត្តគិតថា សិក្សាវិជ្ជាពេទ្យ ។ ប៉ុន្តែនៅពេលដែលខ្ញុំបាទសិក្សាវិជ្ជាពេទ្យនៅឆ្នាំ១៩៨៦ ហើយបញ្ចប់នៅឆ្នាំ១៩៩២ ខ្ញុំបាទមិនដែលសិក្សាអំពីបញ្ហាផ្លូវចិត្តនៅក្នុងកម្មវិធីសិក្សារបស់មហាវិទ្យាល័យពេទ្យទេ ពីព្រោះមិនមានគ្រូ វេជ្ជបណ្ឌិតឯកទេសដែលជំនាញដែលនៅរស់ដែលបានមកបង្រៀនពួកនិស្សិតពេទ្យនៅជំនាន់នោះទេ ។ ប៉ុន្តែ នៅពេលដែលខ្ញុំបាទ ចេញធ្វើការនៅឆ្នាំ១៩៩២ ខ្ញុំបាទធ្វើជាគ្រូពេទ្យវះកាត់ ហើយពេលនោះខ្ញុំបានជួបនូវអ្នកជំងឺជាច្រើនដែលមានបញ្ហាផ្លូវចិត្ត ប៉ុន្តែ ពួកយើងមិនស្គាល់ថាហ្នឹងជាបញ្ហាអីទេ ។

ឧទាហរណ៍ថា៖ អ្នកជំងឺមួយចំនួនសម្លាប់ខ្លួនហើយយើងគិតថា ការសម្លាប់ខ្លួនប្រហែលជាឥទ្ធិពលនៃខ្មោចបិសាច ។ អ្នកជំងឺមានបញ្ហាវិកលចរិត ហើយយើងគិតថា ប្រហែលជាត្រូវអំពើ ។ ដូច្នេះខ្ញុំបាទឆ្លល់ថា តើបញ្ហានេះគឺជាបញ្ហាវេជ្ជសាស្ត្រដែលត្រូវការព្យាបាលដោយគ្រូពេទ្យ ឬមួយយ៉ាងណា ។

[០៩:១៨:៤៣]

រហូតដល់ឆ្នាំ១៩៩៤ ដែលសាកលវិទ្យាល័យ អូស្លូ នៃប្រទេសន័រវេ បានបង្កើតកម្មវិធីមួយដើម្បីបណ្តុះបណ្តាលឯកទេសដល់គ្រូពេទ្យកម្ពុជាក្មេងៗដែលមានចិត្តចង់រៀនឯកទេស ឲ្យសិក្សាអំពីផ្នែកជំងឺផ្លូវចិត្ត ។ អ៊ីចឹង ដល់ពេលដែលខ្ញុំបាទជួបនូវបញ្ហាផងហើយនិងមានកម្មវិធីសិក្សាមកផង ខ្ញុំបាទបានប្រលងចូលទៅសិក្សានៅផ្នែកឯកទេសខាងជំងឺផ្លូវចិត្តនោះនៅឆ្នាំ១៩៩៤ ហើយបញ្ចប់នៅឆ្នាំ១៩៩៨ ។ ហើយការសិក្សានេះគឺជាការសិក្សាកម្មវិធីរួមគ្នារវាងសាកលវិទ្យាល័យអូស្លូ នៃប្រទេសន័រវេនិងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលនៃប្រទេសកម្ពុជា ។ ហើយលោកសាស្ត្រាចារ្យនៅពេលនោះ មិនមានសាស្ត្រាចារ្យកម្ពុជាទេគឺសុទ្ធតែជាសាស្ត្រាចារ្យបរទេសដែលមកពីប្រទេសអឺរ៉ុប អាមេរិក និងប្រទេសអាស៊ី ពីព្រោះកម្ពុជាមិនមានអ្នកជំនាញ ឬក៏សាស្ត្រាចារ្យដើម្បីបង្រៀនពួកយើងខ្ញុំទេ ។

អ៊ីចឹងហើយបានខ្ញុំគិតថានេះគឺជាការសំខាន់ ពីព្រោះក្រោយពីរងនូវការប៉ះទង្គិចនៅសម័យសង្គ្រាមសម័យរបបខ្មែរក្រហមសម័យសង្គ្រាម ក្រោយពីរបបខ្មែរក្រហមប្រជាជនយើងរងនូវបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរដែលមិនមាន ទទួលបាននូវសេវាព្យាបាលទេ ។ អ៊ីចឹងហើយធ្វើឲ្យខ្ញុំបាទសម្រេចចិត្តចូលរៀននូវមុខវិជ្ជានេះ ។

**ស៖** លោកបាននិយាយរួចហើយថា លោកបច្ចុប្បន្នជានាយកអង្គការចិត្តសង្គមអន្តរវប្បធម៌ ដែលហៅថា ធីភីអូ ខេមបូឌា នៅប្រទេសកម្ពុជា ។ តើអង្គការធីភីអូ នេះបានបង្កើតឡើងនៅឆ្នាំណាដែរ? ហើយមានសកម្មភាពធ្វើអ្វីខ្លះទាក់ទងទៅនឹងបញ្ហាគាំទ្រសុខភាពផ្លូវចិត្ត ចំពោះជនរងគ្រោះជាពិសេសជនរងគ្រោះក្នុងរបបកម្ពុជាធិបតេយ្យ?

**ឆ៖** បាទ, អង្គការ ធីភីអូ កម្ពុជាហ្នឹងបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤ អ្នកបង្កើតអង្គការនេះគឺជាអង្គការធីភីអូ អន្តរជាតិដែលមានទីស្នាក់ការនៅទីក្រុងអាំស្ទែដាម ប្រទេសហូឡង់ដ៍។ គោលបំណងនៃការបង្កើតកម្មវិធីនេះគឺដើម្បីឆ្លើយតបទៅនឹងបញ្ហាផ្លូវចិត្ត ដើម្បីជួយផ្តល់ការព្យាបាលនិងអន្តរាគមន៍ខាងផ្នែកបញ្ហាផ្លូវចិត្តនិងបញ្ហាចិត្តសង្គមដល់ជនរងគ្រោះកម្ពុជាយើងក្រោយពីសម័យខ្មែរក្រហម ដែល

រងនូវបញ្ហាផ្សេងៗដូចជាបញ្ហាធ្លាក់ទឹកចិត្ត បញ្ហាវិកលចរិត បញ្ហាបាក់ស្បាត និងបញ្ហាផ្សេងៗ ដើម្បីឱ្យពួកគេនឹងអាចដោះស្រាយបញ្ហាផ្លូវចិត្ត ហើយនិងឱ្យពួកគេអាចប្រកបរបរទទួលទានបាន ។

ហើយអង្គការនេះបានក្លាយទៅជាអង្គការឯករាជ្យក្នុងស្រុកនៅឆ្នាំ២000 ដែលក្រោយពីឆ្នាំ២000 មក គឺអង្គការនេះត្រូវដឹកនាំដោយជនជាតិកម្ពុជាទាំងអស់ ហើយខ្ញុំបាទបានមកធ្វើជានាយកនេះនៅឆ្នាំ ២០០២ ។ ហើយកម្មវិធីយើងសំខាន់ៗ គឺយើងធ្វើការជួយអន្តរាគមន៍សុខភាពផ្លូវចិត្តនៅក្នុងសហគមន៍ ពីព្រោះប្រជាជនកម្ពុជាយើងភាគច្រើនជាង៨0ទៅ៩0ភាគរយរស់នៅក្នុងសហគមន៍ ។ ដូចនេះ គាត់មិនអាចមកទទួលសេវានៅក្នុងមន្ទីរពេទ្យ ឬក៏នៅទីប្រជុំជន អ៊ីចឹងហើយយើងត្រូវបង្កើតកម្មវិធីហ្នឹង ដើម្បីជួយដោះស្រាយ ជួយអន្តរាគមន៍ដល់គាត់ ។

ហើយកម្មវិធីនោះគឺការបណ្តុះបណ្តាលធនធានសំខាន់ៗនៅក្នុងសហគមន៍ ដើម្បីឱ្យគាត់អាចយល់ដឹងអំពីបញ្ហា ដើម្បីឱ្យគាត់អាចកំណត់អំពីបញ្ហាផ្លូវចិត្ត ហើយដើម្បីអាចឱ្យគាត់ព្យាបាល អាចជួយដោះស្រាយបញ្ហាផ្លូវចិត្តរបស់ប្រជាជនដូចគ្នានៅក្នុងសហគមន៍ ។ យើងធ្វើការផ្សព្វផ្សាយដល់ប្រជាជននៅសហគមន៍ឱ្យយល់ច្បាស់អំពីបញ្ហាផ្លូវចិត្ត និងអំពីផលវិបាកដែលការបង្កើតមកពីបញ្ហាផ្លូវចិត្តដើម្បីឱ្យគាត់បានយល់ ហើយនិងរកវិធីដោះស្រាយបាន ។

យើងជួយជួយបង្កើតក្រុមជួយខ្លួនឯងសម្រាប់ស្ត្រី ជាពិសេសស្ត្រីដែលរងនូវអំពើហិង្សាក្នុងគ្រួសារចំពោះបុរសដែលញៀនសុរា ជាពិសេសយើងឃើញថាអ្នកទាំងពីរហ្នឹង គឺវាមានទំនាក់ទំនងគ្នា ។ អ៊ីចឹងយើងជួយទាំងស្ត្រីទាំងបុរស ។ ហើយបញ្ហាទាំងអស់ហ្នឹង គឺសុទ្ធតែជាបញ្ហាដែលផលវិបាកដែលប្រជាជនយើងរងតាំងពីសម័យខ្មែរក្រហម និងសម័យសង្គ្រាមជាច្រើនទសវត្សរ៍មកទៀត ។ ហើយយើងក៏បានផ្តល់ប្រឹក្សាដល់ជនរងគ្រោះដែលមានបញ្ហាផ្លូវចិត្តនិងបញ្ហាចិត្តសង្គម ។

យើងបង្កើតសេវាព្យាបាលខាងផ្នែកសុខភាពផ្លូវចិត្ត ដោយៗផ្តល់ជាធ្វើរោគវិនិច្ឆ័យនិងផ្តល់ការព្យាបាលដោយយើងៗមានវេជ្ជបណ្ឌិតឯកទេសក្នុងការជួយ ។ ហើយអង្គការ ធីភីអូ មានគម្រោងផ្សេងៗទៀតជាច្រើនទៀតដែលក្នុងនោះគម្រោងសំខាន់មួយគឺគម្រោងដែលយើងផ្តល់ការគាំទ្របញ្ហាចិត្តសង្គមដល់សាក្សី និងជនរងគ្រោះដែលមកធ្វើសក្ខីកម្មនៅក្នុងសាលាក្តីអន្តរជាតិនេះ ។ សូមអរគុណ ។

[០៩:២៤:០៨]

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើការសិក្សាស្រាវជ្រាវអំពីជំនាញនេះ ក៏ដូចជានៅក្នុងអំឡុងពេលដែលលោកទទួលជានាទីជាប្រធានអង្គការធីភីអូ តើលោកធ្លាប់បានជួបសម្ភាសន៍ជាមួយនឹងជនរង

គ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ជាពិសេសថាតើលោកធ្លាប់បើបានធ្វើការសម្ភាសន៍ជាមួយនឹងជនរងគ្រោះនៃមន្ទីរសន្តិសុខស-២១ ដែរឬទេ?

**ផ៖** បាទ, ខ្ញុំដែល ។ ខ្ញុំបាទដែល ។

**ស៖** ផ្អែកតាមភាពជំនាញរបស់លោក និងការសិក្សារបស់លោក ក៏ដូចជាបទពិសោធន៍របស់លោកមាននៅលើវិស័យជំនាញរបស់លោកពាក់ព័ន្ធជាមួយនឹងសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ និងទិដ្ឋភាពនានាមានចំពោះជនរងគ្រោះដែលនៅ-- ដោយសាររបបកម្ពុជាប្រជាធិបតេយ្យ តើលោកមានអ្វីបង្ហាញដល់អង្គសវនាការអំពីស្ថានភាពនៃចិត្តសាស្ត្ររបស់ជនរងគ្រោះនោះដែរឬទេ? បើមានសូមលោកជួយបង្ហាញនូវហេតុផលទាំងឡាយដែលលោកបានជួបប្រទះចំពោះសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះ ឬក៏ដូចជាភាពភ័យខ្លាចរបស់គេ ឬក៏ភាពបាក់ស្បាតរបស់អ្នកទាំងនោះមានតាំងពីពេលមុនរហូតដល់ពេលបច្ចុប្បន្ននេះតាមជំនាញរបស់លោក ។ សូមអញ្ជើញ ។

[០៩:២៦:០៩]

**ផ៖** បាទសូមអរគុណ។ ជាបឋមខ្ញុំបាទសូមអនុញ្ញាតធ្វើការអត្ថាធិប្បាយជាទិដ្ឋភាពទូទៅបន្តិចមុននឹងចូលទៅដល់ លក្ខណៈពិសេសដែលទាក់ទងទៅនឹងជនរងគ្រោះ ពីព្រោះនេះគឺជាកត្តាសំខាន់ដើម្បីឲ្យយើងអាចយល់បានអំពីជម្រៅនិងកម្រិតនៃការឈឺចាប់ដែលជនរងគ្រោះបានទទួល ។

ខ្ញុំបាទសូមលើកពីបញ្ហាដើមបន្តិចថារបបខ្មែរក្រហមគឺជារបបមួយដែលបំផ្លាញដល់ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រជាជនយើង បំផ្លាញនូវ *សូស្យល ផាប់ប្លិក* (Social Public) របស់ប្រទេសកម្ពុជាយើងនៅក្នុងគ្រប់កម្រិត ខ្ញុំអាចបាននិយាយថាក្នុងកម្រិតសង្គម កម្រិតគ្រួសារនិងកម្រិតបុគ្គល ។

នៅក្នុងកម្រិតសង្គមគឺថា សម័យរបបខ្មែរក្រហមនោះបានបំផ្លិចបំផ្លាញនូវគ្រប់ស្ថាប័នផ្សេងៗរបស់រដ្ឋ សាលារៀន ទីផ្សារ មន្ទីរពេទ្យ សកលវិទ្យាល័យ អ្វីៗផ្សេងៗទាំងអស់ត្រូវបានកម្ទេច ហើយអ្នកបញ្ញវន្ត និងអ្នកមានចំណេះដឹងផ្សេងៗអ្នករស់នៅទីក្រុងត្រូវបានកម្ទេច ។ អ៊ីចឹង ប្រជាជនយើងគឺមិនមានលទ្ធភាពរស់នៅប្រកបដោយភាពសុខដុមរមនាទៀតទេ ព្រោះត្រូវគេជម្លៀសឲ្យចេញពីទីក្រុងធ្វើបាប បង្ខំឲ្យធ្វើការហួសកម្លាំង សម្លាប់ ហើយមិនមានផ្តល់នូវសេវាគ្រប់គ្រាន់ ដូចជាមិនមានជម្រកមិនមានអាហារ មិនមានការព្យាបាល ។ ការបែងចែកមនុស្សជាពីរក្រុម ប្រជាជនចាស់ ប្រជាជនថ្មីដែលបង្កើតឲ្យមានការមិនទុកចិត្តគ្នា បង្កើតឲ្យមានការមិនទុកចិត្តគ្នា បង្កើតឲ្យមានសងសឹកគ្នាក្នុងចំណោមប្រជាជន ដែលធ្វើឲ្យប្រជាជនខ្មែរយើងលែងទុកចិត្តគ្នារហូត ។

ការបំផ្លាញនូវវប្បធម៌ ការបំផ្លាញនូវសាសនា ការបំផ្លាញនូវពិធីបុណ្យ លុបបំបាត់ចោលនូវជំនឿ ការលុបបំបាត់ចោលនូវអារម្មណ៍ ឬក៏ជំនឿផ្សេងៗរបស់ប្រជាជនពលរដ្ឋ បញ្ហានេះគឺជាការប៉ះពាល់ដល់ធំធេងដល់បញ្ហាផ្លូវចិត្ត ពីព្រោះប្រជាជនយើងប្រើប្រាស់នូវជំនឿនេះជាវិធីមួយដើម្បីដោះស្រាយនូវបញ្ហា ដើម្បីផ្តល់នូវអត្ថន័យ នូវរឿងរ៉ាវដែលបានកើតឡើងនៅក្នុងសម័យខ្មែរក្រហមក្តី នៅក្នុងបញ្ហាអីផ្សេងៗដែលកើតឡើងចំពោះគេ ។ អ៊ីចឹងការបាត់បង់នូវជំនឿទាំងអស់នេះធ្វើឲ្យគេមានការឈឺចាប់ខាងផ្នែកផ្លូវអារម្មណ៍ ផ្លូវចិត្ត ពីព្រោះនៅពេលមានបញ្ហាគេមិនដឹងជារកនូវវិធីណាដោះស្រាយ ពីព្រោះខ្មែរក្រហមមិនបានអនុញ្ញាតឲ្យប្រជាជនយើងប្រើប្រាស់នូវជំនឿទាំងអស់នេះ ដើម្បីគោរពបូជា ។

នៅក្នុងកម្រិតគ្រួសារ ពួកខ្មែរក្រហមបានបង្ខំប្រជាជន ក្រុមគ្រួសារមិនឲ្យរស់នៅជាមួយគ្នា កូនត្រូវបានបង្ខំចេញពីឪពុកម្តាយ ។ យើងដឹងថាកុមារនៅក្នុងវ័យ-- នៅវ័យតូចៗ គឺត្រូវការភាពកក់ក្តៅ ការយកចិត្តទុកដាក់ ការថែរក្សាពីឪពុកម្តាយ ប៉ុន្តែខ្មែរក្រហមបានបំបែកកុមារចេញពីឪពុកម្តាយ បង្ខំឲ្យធ្វើការជាទម្ងន់ ធ្វើទារុណកម្ម មិនឲ្យហូបគ្រប់គ្រាន់ ។ អ៊ីចឹងបញ្ហានេះ គឺជាបញ្ហាផ្លូវចិត្តមួយ បញ្ហាមួយដែលប៉ះដល់ផ្លូវចិត្តកុមារដែលៗបញ្ហាហ្នឹងអាចនឹងបន្តរហូតដល់គេធំឡើង ប្រសិនបើមិនមានការដោះស្រាយសមស្រប ។

ពួកខ្មែរក្រហមបានបង្ខំឲ្យកុមារធ្វើយ៉ាងណាជា-- ដូចថាជា *ស្ប៉ាយ* (Spy) ជាអ្នកយកការណ៍ពីឪពុកម្តាយដើម្បីរាយការណ៍ទៅអង្គការ ។ ទាំងអស់នេះដែលជាលទ្ធផលយើងសង្កេតឃើញថា មានកុមារមួយចំនួន រហូតដល់អាចសម្លាប់ដល់ឪពុកម្តាយ ឬក៏រាយការណ៍រហូតដល់ឪពុកម្តាយត្រូវបានគេសម្លាប់ដែលវាបន្សល់នូវស្លាកស្នាមជូរចត់សម្រាប់ក្នុងបញ្ហាផ្លូវចិត្តរបស់កុមារទាំងនោះនៅពេលដែលគេធំឡើង ពីព្រោះគេនឹកឃើញនូវកំហុសដែលគេបានធ្វើកន្លងមក ។

នៅក្នុងកម្រិតបុគ្គល ខ្មែរក្រហមបានបំផ្លាញនូវសុខុមាលភាពរបស់បុគ្គលបង្ខំឲ្យធ្វើការយ៉ាងទម្ងន់មិនឲ្យ-- ទាំងថ្ងៃទាំងយប់មិនឲ្យហូប មិនឲ្យគេង មិនឲ្យមានកន្លែងស្នាក់នៅ ហើយប្រជាជនភាគច្រើនរស់នៅក្នុងក្តីភិតភ័យ ដែលទាំងនេះវាបញ្ចេញនូវបញ្ហាផ្លូវចិត្តផ្សេងៗ ដូចជាបញ្ហាចម្បង ដូចជាបញ្ហាបាក់ស្បាត ពីព្រោះប្រជាជនកម្ពុជាយើងជាពិសេសអតិថិជនដែលខ្ញុំបាទបានជួប ភាគច្រើនបានបង្ហាញនូវភាពបាក់ស្បាតដែលពួកគាត់បានមាន ដែលបន្សល់ពីសម័យខ្មែរក្រហមនោះ ។

ហើយនៅតាមការស្រាវជ្រាវក្រោយពីសម័យខ្មែរក្រហមមកយើងឃើញថា លោកសាស្ត្រាចារ្យលីយ៉ុង ដែលជានាយកអង្គការធីភីអូ អន្តរជាតិគាត់បានធ្វើការស្រាវជ្រាវនៅប្រទេសកម្ពុជាយើង ។ ក្នុង

ចំណោមប្រជាជនកម្ពុជាពីប្រាំនាក់ មានពីរនាក់ដែលមានបញ្ហាផ្លូវ និងវិបត្តិចិត្តសង្គម ដែលនេះគឺមានរហូតដល់ប្រហែលសែសិបភាគរយនៃប្រជាជនដែលជាតួលេខមួយខ្ពស់ ។

ហើយថ្មីៗនេះយើងឃើញមានការសិក្សាច្រើនដែលលោក សូនីស ឆ្នាំ២០០៩ យើងឃើញថាមានដប់បួនភាគរយនៃប្រជាជនកម្ពុជា ដែលមានអាយុលើសពី១៨ឆ្នាំ មានជំងឺ *ប៉ុស្តត្រូម៉ាទិច ស្ត្រេសឌីហ្សូតឌ័រ* (Post Traumatic Stress Disorder) ឬក៏ *ភីធីអេសឌី* (PTSD) (និយាយភាសារអង់គ្លេស) ដែលខ្មែរយើងហៅថា “បាក់ស្បាតនោះ” ។ ហើយនិងមានការសិក្សាផ្សេងៗដែលបញ្ជាក់ឲ្យឃើញថាមានអត្រានៃជំងឺផ្លូវចិត្តហ្នឹងខ្ពស់ក្នុងចំណោមប្រជាជនកម្ពុជា ។

[០៩:៣២:៤៣]

ដោយឡែក ជនរងគ្រោះដែលខ្ញុំបាទបានជួបប្រទះដែលជាអតិថិជន ដែលខ្ញុំបាទទទួលបានការព្យាបាល ឬក៏ផ្តល់សេវា យើងឃើញមានថាពួកគាត់នៅមានបញ្ហាផ្លូវចិត្ត នៅមានអារម្មណ៍ភ័យខ្លាចអំពីអតីតកាលហ្នឹងជាប់រហូតមកដល់សព្វថ្ងៃ ។ ជាក់ស្តែង អារម្មណ៍ទាំងអស់នោះបានត្រលប់មកគាត់វិញនៅពេលថ្ងៃដែលធ្វើឲ្យគាត់តែងតែនឹកឃើញ ដែលធ្វើឲ្យគាត់តែងចងចាំ ។ ជនរងគ្រោះខ្លះគាត់បាននឹកឃើញថានៅពេលដែលមានមេឃស្រទុំ នៅពេលដែលមានភ្លៀង ធ្វើឲ្យគាត់មានអារម្មណ៍ចង់យំពីព្រោះវាធ្វើឲ្យគាត់នឹកឃើញនៅពេលលំបាក ដែលគាត់ត្រូវគេធ្វើបាបនៅពេលភ្លៀង ត្រូវធ្វើទារុណកម្មទុកចោលនៅហាលភ្លៀង ។

ជនរងគ្រោះខ្លះមិនអាចធ្វើការងារប្រចាំថ្ងៃទៀតបានដោយសារតែអំពីបញ្ហាដែលគាត់បានរង ។ ជនរងគ្រោះខ្លះមានសុបិនអាក្រក់ជាប់ជារៀងរាល់ថ្ងៃ ។ ខ្ញុំបាទ-- ជនរងគ្រោះម្នាក់បានលើកឡើងថាគាត់យល់សប្តិឃើញប្រពន្ធ(ភរិយា) របស់គាត់ដែលស្លាប់ត្រលប់មកវិញជាទៀងទាត់ដើម្បីមកសុំឲ្យគាត់ជួយរកយុត្តិធម៌ ឬក៏អ្នកខ្លះទៀតមានបញ្ហាយល់សប្តិអាក្រក់ឃើញមានការដេញចាប់ ដេញតាមសម្លាប់ជាប់ជាប្រចាំដែលទាំងនេះគឺជាបញ្ហាមួយដែលបន្សល់ទុក ឬក៏ជាបញ្ហាដែលទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ជនរងគ្រោះខ្លះបានបង្ហាញថា គាត់យល់សប្តិអាក្រក់ឃើញតែគាត់ហាក់ដូចជានៅក្នុងកន្លែងមួយដែលជិតចង្អៀតពិបាកដកដង្ហើមដែលយើងអាចកាត់ស្មានថា ប្រហែលជាមានលក្ខណៈដូចទៅគុក ឬកន្លែងធ្វើទារុណកម្មរបស់ខ្មែរក្រហម ។

ទន្ទឹមនេះទៀត យើងឃើញមានប្រជាជនមួយចំនួន ជនរងគ្រោះមួយចំនួនធំដែលគាត់រងនូវបញ្ហាធ្លាក់ទឹកចិត្ត ដែលគាត់អស់សង្ឃឹមចំពោះជីវិតរស់នៅ គាត់មិនអាចប្រកបមុខរបរក្នុងជីវភាពរស់នៅបាន

ដែលបង្ខំឲ្យកូនរបស់គាត់មាន--ចាប់យកតួនាទីជាឪពុកម្ដាយដែលយើងឃើញថានេះ គឺជាបន្ទុកមួយសម្រាប់កូន ដោយគាត់នឹងខំធ្វើការហួសកម្លាំង ដើម្បីចិញ្ចឹមម្ដាយដែលមានបញ្ហាផ្លូវចិត្ត ។

ជនរងគ្រោះខ្លះទៀត មិនអាចធ្វើការងារកើត ដោយសារអារម្មណ៍ពីអតីតកាលបានត្រលប់មកវិញបំផ្លាញ តាមយាយីគាត់ជារៀងរាល់ថ្ងៃ ដែលធ្វើឲ្យគាត់មានអារម្មណ៍ភ័យខ្លាចរហូតដល់ពួកគាត់ទៅញៀំសុរា ឬក៏ពិសាបារីដែលទាំងនេះវាបន្ថែមទៅលើបញ្ហាផ្លូវចិត្ត ដែលគាត់មានតាំងពីមុនឡើង ពីមុនមកទៀត ។ ជាបន្ថែមទៀតក៏មានជនរងគ្រោះមួយចំនួនទៀតដែរ ដែលមានជំងឺរាងកាយ ដូចជាជំងឺលើសឈាម ជំងឺឈឺចាប់យ៉ាងរ៉ាំរ៉ៃដោយដែលជាស្លាកស្នាមនៃការធ្វើទារុណកម្មជាដើមនោះ ។

ខ្ញុំបាទសូមអរគុណ ។

[០៩:៣៦:០៥]

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីសួរដល់សាក្សីដែលជាអ្នកជំនាញរូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ ។

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោកវេជ្ជបណ្ឌិត សុធារ៉ា ខ្ញុំសូមជម្រាបសួរលោកអំពីប្រវត្តិជំនាញរបស់លោក ខ្ញុំមិនទាន់យល់ច្បាស់ ហើយអាចនឹងអាស្រ័យទៅលើការបកប្រែក៏មិនដឹង ខ្ញុំយល់ថា លោកជាវេជ្ជបណ្ឌិត ហើយលោកបានបន្តការសិក្សាជាអ្នកជំនាញបន្តមកទៀតនៅក្នុងថ្នាក់បណ្ឌិត ហើយជាពិសេសខាងផ្នែកចិត្តសាស្ត្រ តើមែនឬទេ?

**ឆ៖** បាទ, ខ្ញុំបាទចូលរៀនជាវេជ្ជបណ្ឌិតផ្នែកវេជ្ជសាស្ត្រនៅឆ្នាំ១៩៨៦ នៅមហាវិទ្យាល័យវេជ្ជសាស្ត្រសុខាភិបាលភ្នំពេញ ហើយជាប់សញ្ញាបត្រជាវេជ្ជបណ្ឌិតនៅឆ្នាំ១៩៩២ ។ នៅពេលឆ្នាំ១៩៩៤ ខ្ញុំបាទរៀនវេជ្ជបណ្ឌិតឯកទេស ជាផ្នែកឯកទេសនៃផ្នែកជំងឺផ្លូវចិត្តហ្នឹង *ស្ពេស្យាលីសអ៊ីនសេខាយទ្រី* (និយាយភាសាអង់គ្លេស) នៅហើយទទួលសញ្ញាបត្រនៅឆ្នាំ១៩៩៨ ។ ហើយក្នុងឆ្នាំ៩៩ ខ្ញុំបាទបានបន្តការសិក្សាថ្នាក់អនុបណ្ឌិតខាងផ្នែកវិទ្យាសាស្ត្រផ្លូវចិត្តនៅទីក្រុងស៊ីដនី សាកលវិទ្យាល័យញ៉ូវសៅវែលនៅទីក្រុងស៊ីដនីក្នុងរយៈពេលមួយឆ្នាំកន្លះ ។ ហើយសព្វថ្ងៃនេះខ្ញុំបាទកំពុងតែបន្តការសិក្សាខាងផ្នែក

បណ្ឌិត ខាងផ្នែកសុខភាពផ្លូវចិត្តហ្នឹងនៅសាកលវិទ្យាល័យម៉ូណាសទីក្រុងមែលប៊ន នៅប្រទេសអូស្ត្រាលី ដោយបានឧបត្ថម្ភអាហាររូបករណ៍ពី*អូស្ត្រាលានលីដឺស៊ីបអាវាដ៍ អេ.អិល.អេ* (និយាយភាសាអង់គ្លេស)។

[០៩:៣៨:២២]

**ស៖** ដូច្នេះជំនាញរបស់លោកបណ្ឌិតគឺនៅក្នុងផ្នែកជំងឺផ្លូវចិត្ត មិនមែនខាងវិកលចរិតទេ ។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំគិតថាប្រហែលជាបញ្ហាបកប្រែក៏មិនដឹង ប៉ុន្តែខ្ញុំអាចថា បញ្ហាជំងឺផ្លូវចិត្តជាបញ្ហា*សេខាយទ្រី* ។

**ស៖** សូមអរគុណ ។ លោកបានធ្វើការពេញពេលជាមួយនឹងជនរងគ្រោះនៃរបបខ្មែរក្រហម ហើយតាមពិតឥឡូវនេះ វាមានចំនួនកើនឡើងជាពិសេសជាពួកកុមារដែលសេសសល់ពីសម័យនោះ ។ តើត្រូវឬទេ?

**ឆ៖** ខ្ញុំប្រហែលជាអត់យល់សំណួរ សុំអញ្ជើញមួយសាទៀតបាទ ។

**ស៖** សូមអភ័យទោស ខ្ញុំចង់សុំឲ្យលោកបញ្ជាក់ថា លោកបានធ្វើការភាគច្រើននៅក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយនេះ ជាមួយនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ហើយមួយចំនួនអ្នកទាំងនោះ គឺមានកុមារផងដែរ តើមែនឬទេ?

**ឆ៖** ការងាររបស់ខ្ញុំបាទ ធ្វើការភាគច្រើនជាមួយនឹងមនុស្សចាស់ មិនសូវបានធ្វើការជាមួយនឹងកូនក្មេងទេ ។ សូមអរគុណ ។

**ស៖** តើខ្ញុំអាចយោងទៅរកសេចក្តីបង្ហាញរបស់លោក គឺថាបញ្ហាចម្បងដែលនាំឲ្យមានជំងឺបាក់ស្បាត ឬប៉ះទង្គិចផ្លូវអារម្មណ៍របស់ជនរងគ្រោះដែលរស់ឆ្លងកាត់របបខ្មែរក្រហមនោះ គឺកង្វះការថែទាំខាងផ្លូវពេទ្យ ខាងវេជ្ជសាស្ត្រ ហើយនិងផ្លូវចិត្តសម្រាប់ពួកគេនៅក្នុងសម័យនោះ ។ ហើយបន្ទាប់មកបន្ទាប់ពីសង្គ្រាមហ្នឹងចប់ទៅ ក៏គេកើតមានបញ្ហាហ្នឹង តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំគិតថា មិនវាជាផ្នែកមួយដែលបញ្ហាផ្លូវចិត្តធ្ងន់ធ្ងររបស់ប្រជាពលរដ្ឋ របស់ជនរងគ្រោះហ្នឹងមួយផ្នែកអាចបណ្តាលមកពីកង្វះនូវសេវាគ្រប់គ្រាន់សម្រាប់ជួយដល់ជនរងគ្រោះ ពីព្រោះក្រោយពីសម័យខ្មែរក្រហម មិនមានសេវាណាទៀតដើម្បីផ្តល់ដល់ប្រជាជន ហ្នឹងៗជាផ្នែកមួយ។ ប៉ុន្តែជាផ្នែកសំខាន់គឺបញ្ហាដែលប្រជាជនបានជួបប្រទះហ្នឹង គឺជាបញ្ហាធ្ងន់ធ្ងរហួសហេតុ យើងសង្កេតឃើញថា ខ្ញុំបានរៀបរាប់តាំងពីដើមហើយមក ការបំផ្លិចបំផ្លាញ ការកម្ទេចរបស់ពួកខ្មែរក្រហមនុ៎ង គឺកម្ទេចនៅ

គ្រប់ហេដ្ឋារចនាសម្ព័ន្ធជាន់ថ្នាក់របស់ប្រទេស តាំងពីផ្នែក *ខលិចទីវ* ជាធំរហូតដល់កម្រិតបុគ្គល ដែលទាំងនេះជាការបំផ្លាញនូវ រហូតដល់បញ្ហាមួយទៀតទាក់ទៅនឹងជំនឿ និងសាសនា និងវប្បធម៌ដែលវាប៉ះពាល់ធ្ងន់ធ្ងរពេក វាហួសពីលទ្ធភាពដែលឲ្យប្រជាជនយើងអាចជាសះស្បើយនៅក្នុងរយៈពេលដ៏ខ្លី ឬក៏រយៈពេលដ៏ឆាប់ ។

[០៩:៤២:៣១]

ខ្ញុំបាទគិតថា បងប្អូនមួយចំនួនជនបរទេសប្រហែលជាឆ្ងល់ថា ហេតុអីបាជាសម័យរបបខ្មែរក្រហមសាមសិបឆ្នាំមកហើយ ប្រជាជននៅតែរងគ្រោះ ពីព្រោះបញ្ហាហ្នឹងគឺជាបញ្ហាមួយដ៏ធ្ងន់ ហើយក្រោយពីសម័យខ្មែរក្រហម ប្រជាជនយើងមិនសូវមានឱកាសគ្រប់គ្រាន់នៅក្នុងការធ្វើយ៉ាងណា ដើម្បីដោះស្រាយ ឬដើម្បីព្យាបាលបញ្ហាផ្លូវចិត្ត ។ ទីមួយដោយសារខ្វះខាតនូវសេវាគ្រប់គ្រាន់ ។ ទីពីរ ដោយសារជីវភាពរស់នៅ ពីព្រោះជនរងគ្រោះយើងមួយចំនួនធំជាអ្នកដែលមានជីវភាពលំបាក ។ ហើយគាត់រវល់នឹងការរកទទួលទាន ដូច្នេះបញ្ហាឈឺចាប់គាត់ត្រូវបានទុក ដូចថា ត្រូវបានកប់ទុកមួយកន្លែង ប៉ុន្តែមិនមែនមានន័យថា គាត់មិនមានបញ្ហាផ្លូវចិត្ត បញ្ហាផ្លូវចិត្តគឺនៅមាន ប៉ុន្តែបញ្ហានោះត្រូវបានកប់ទុកមួយហើយវានឹងងាយនឹងកើតវិញនៅពេលដែលមានការរំឭក ឬក៏ការនឹកឃើញឡើងវិញនូវបញ្ហាអតីតកាល ។

បញ្ហាមួយទៀត ខ្ញុំបាទចង់លើកថា ក្នុងពេលដែលយើងកំពុងតែដូចថា មានអាសន្ន យើងមិនមានការឈឺចាប់ទេ ការឈឺចាប់អាចនៅមួយរយៈ អាចនៅទុក ឬក៏យើងនឹងមិនមានអារម្មណ៍ឈឺចាប់ ប៉ុន្តែ នៅពេលដែលភាពមានអាសន្ននោះ បានកន្លងផុតទៅការឈឺចាប់ អាចនឹងកើតមាន ជាក់ស្តែង ខ្ញុំបាទបានជួបជនរងគ្រោះ ឬក៏អតិថិជនដែលខ្ញុំបាទបានព្យាបាល គាត់បានគិតថា ក្រោយពីសម័យខ្មែរក្រហមគាត់មិនបានគិតគូរ គាត់មិនបានរវល់អំពីបញ្ហាខ្មែរក្រហមប៉ុន្មានទេ ពីព្រោះគាត់ធ្វើយ៉ាងណាដើម្បីចិញ្ចឹមក្រពះ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ប៉ុន្តែនៅពេលដែលគាត់បានទទួលនូវជីវភាពគ្រាន់បើជាងមុន បែរជាគាត់នឹកឃើញនូវរឿងអតីតកាល ហើយដែលបញ្ហានេះជាបញ្ហាលំបាក ។

ហើយជាពិសេសមួយទៀត គឺសាលាក្តីខ្មែរក្រហម បានធ្វើឲ្យគាត់រំឭកឡើងវិញនូវបញ្ហាផ្លូវចិត្តទាំងឡាយដែលគាត់ធ្លាប់ជួបប្រទះ ហើយបញ្ហាទាំងអស់ហ្នឹងមិនបានដោះស្រាយទេ ប្រជាជនយើងរវល់មិនមានឱកាសនៅក្នុង*គ្រីប្ហ* ឬក៏ *ម៉ូនីង* នៅក្នុងចំពោះបងប្អូនដែលបានស្លាប់ទៅក្នុងសម័យខ្មែរក្រហមទេ ។

[០៩:៥៥:៥៦]

ហើយចំណុចមួយទៀត គឺយើងគិតថា អ្វីទៅដែលជាតម្រូវការ អ្វីទៅដែលជាការចង់បានរបស់ជនរងគ្រោះ ជនរងគ្រោះគឺចង់បាននូវយុត្តិធម៌ ហើយនិងការពិត គឺទាំងនេះដែលអាចជួយឲ្យគាត់នៅមានអារម្មណ៍ស្ងប់បាន ប៉ុន្តែរហូតមកដល់នេះ គឺជាឱកាសមួយដែលគាត់កំពុងរង់ចាំ ហើយដែលគាត់គិតថាមិនទាន់ទទួលបានទេ ។ សូមអរគុណ ។

**ស៖** សូមអរគុណ ។ ហើយខ្ញុំក៏ចាប់អារម្មណ៍ចង់ដឹងអំពីផលប៉ះពាល់នៃរបបខ្មែរក្រហមទៅលើជនជំនាន់មួយ ដែលមិនរងការប៉ះពាល់ផ្ទាល់ អំពីរបបនោះ ឬក៏អ្នកដែលនៅវ័យក្មេងក្នុងសម័យនោះ តើលោកមានមតិយោបល់អ្វីដើម្បីបញ្ជាក់ អំពីផលប៉ះពាល់ទៅលើលក្ខខណ្ឌមួយចំនួន ទៅលើជនទាំងអស់នោះដើម្បីឲ្យគេបញ្ឈប់នូវការជំនឿសាសនាទៅជំនាន់ក្រោយមួយទៀត ហើយក៏ផលប៉ះពាល់ទៅលើជនដែលបានឆ្លងកាត់របបនោះ ដោយមិនមានការអប់រំថាតើផលប៉ះពាល់អ្វី ដែលប៉ះពាល់ទៅដល់លើជនជំនាន់ក្រោយរបស់ជនទាំងនោះ នោះ?

**ឆ៖** ផលប៉ះពាល់ដែលជនមិនបានទទួលឬរស់នៅ នៅក្នុងសម័យខ្មែរក្រហមក៏មានការប៉ះពាល់អំពីបញ្ហាផ្លូវចិត្តអំពី *ត្រូម៉ា* ដែលមានទៅលើក្រុមគ្រួសាររបស់គេដែរ ។ តាមការសិក្សានៅប្រទេសផ្សេងជាពិសេសដែលទាក់ទងទៅនឹងរបប *ហូឡូកូស* ។ យើងឃើញថា កូនចៅជំនាន់ក្រោយរបស់ជនរងគ្រោះមានបញ្ហាផ្លូវចិត្ត ដែលបញ្ជូនពីឪពុកម្តាយ ឬក៏បងប្អូនរបស់គេដែលមាន ។

នៅក្នុងប្រទេសកម្ពុជាយើងមិនទាន់មានធ្វើការសិក្សាណាមួយ ដើម្បីចង់ដឹងអំពីផលប៉ះពាល់ទៅលើជនជំនាន់ក្រោយទេ ។ មានការសិក្សាខ្លះៗដែលធ្វើ ប៉ុន្តែមាននៅក្នុងកម្រិតតូចតាច ដែលយើងមិនអាចធ្វើអត្ថាធិប្បាយកំណត់ថាវាជាបញ្ហាទូទៅ ប៉ុន្តែខ្ញុំបាទសូមបញ្ជាក់ថា វាអាចមាននូវការឆ្លងការបញ្ជូននូវបញ្ហាផ្លូវចិត្តពីជំនាន់នេះ ឪពុកម្តាយជំនាន់នេះ ទៅកូនចៅជំនាន់ក្រោយ ។ ឧទាហរណ៍ ឪពុកម្តាយដែលមាន-- ប្រទេសកម្ពុជាប្រជាជនយើងរស់នៅក្នុងគ្រួសារមួយ ដែលមានបងប្អូនកូនចៅរស់នៅជុំគ្នា *អ៊ិចស្តិនឌីដ ហ្វាមីលី (extended family)*។ ហើយអ៊ីចឹងឧទាហរណ៍ថា ប្រសិនបើបញ្ហាផ្លូវចិត្តហ្នឹងកើតមាននៅលើឪពុក ឬក៏ម្តាយ អ៊ីចឹងកូនចៅហ្នឹងត្រូវធ្វើយ៉ាងណា*ថេករោល* ជា *ឃែរហ្គីវ័រ* ជាអ្នកថែទាំងដើម្បីធ្វើការឲ្យលើសទម្ងន់ ។

បញ្ហាផ្លូវចិត្តខ្លះទៀត ដែលអាចកើតមាន ដូចថា ការធ្វើការលើសទម្ងន់ដែលជាបន្ទុកធ្ងន់សម្រាប់គាត់ សម្រាប់ក្មេងដែលត្រូវធ្វើអ្វីៗជំនួសនូវតួនាទីរបស់ឪពុក ។

បញ្ហាមួយទៀត ឧទាហរណ៍ថា ការប៉ះទង្គិច ឬក៏*ត្រូម៉ា* ដែលនៅលើក្រុមគ្រួសារឪពុកដែលគាត់ញ៉ាំសុរា ។ អ៊ីចឹងនៅពេលផលវិបាករបស់សុរា វាប៉ះពាល់ទៅលើកូនប៉ះពាល់ទៅលើប្រពន្ធប៉ះពាល់ទៅលើគ្រប់ៗគ្នានៅក្នុងគ្រួសារ ដែលទាំងអស់គ្នាហ្នឹងគឺរងនូវបញ្ហាផ្លូវចិត្ត ដែលជាបញ្ហាផ្លូវចិត្តរបស់គាត់ ថ្វីត្បិតតែពួកគាត់មិនបានរស់នៅក្នុងរបបខ្មែរក្រហមដោយផ្ទាល់ក្តី ។ សូមអរគុណ ។

[០៩:៤៩:00]

**ស៖** សង្គមភាគច្រើននៅពេលដែលគេរងនូវជម្លោះធ្ងន់ធ្ងរក៏មានអំពើហិង្សាផងដែរក្រោយមក ជាពិសេសគឺ ជាអំពើហិង្សាដែលមាននៅក្នុងក្រុមគ្រួសារ លោកបានសិក្សាពីចំណុចនេះ តើក្នុងការងាររបស់លោក តើលោកសង្កេតឃើញចំណុចនេះរបៀបម៉េចដែរ? តើលោកមានព័ត៌មានអ្វីខ្លះ? អំពីការសិក្សាស្រាវជ្រាវរបស់លោក ឬការសង្កេតរបស់លោកដែលអាចនិយាយបានអំពីកម្រិតនៃអំពើហិង្សាដែលរាប់ទាំងអំពើហិង្សានៅក្នុងគ្រួសារផងដែរ នៅក្នុងសម័យកម្ពុជាបច្ចុប្បន្នថ្មីៗនេះ ។

**ឆ៖** អង្គការធីភីអូ នៅពេលដែលចុះធ្វើអន្តរាគមន៍នៅសហគមន៍យើងបានធ្វើការប៉ាន់ប្រមាណបរិបទសង្គមដោយយើងថា *សូស្យលខនថិក អាសេសមិន* ។ ការធ្វើការប៉ាន់ប្រមាណបរិបទសង្គមនេះគឺមូលហេតុដើម្បីចង់ដឹងអំពីបញ្ហាដែលមាននៅក្នុងសហគមន៍ ចង់អំពីមូលហេតុដែលមានបញ្ហា ចង់ដឹងអំពីធនធាន ចង់ដឹងអំពីប្រវត្តិនៅក្នុងសហគមន៍ ។ បញ្ហាដែលយើងឃើញជាញឹកញាប់ ដែលយើងឃើញថាមានលក្ខណៈថេរគ្រប់គ្នាគឺអំពីបញ្ហាហិង្សា និងបញ្ហាសុរា ដែលបញ្ហាទាំងពីរនេះ តំណាងឲ្យប្រហែលជាងសែសិបភាគរយនៃបញ្ហា ដែលយើងបានរកឃើញនៅក្នុងសហគមន៍ ។ ហ្នឹងគឺជាបញ្ហាដែលយើងបានឃើញនៅក្នុងការធ្វើអន្តរាគមន៍របស់យើង ។ ហើយយើងឃើញមានការស្រាវជ្រាវរបស់អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ។

ក្នុងចំណោមប្រាំមួយនាក់ មានស្ត្រី មានស្ត្រីពីរនាក់ ដែលរងនូវអំពើហិង្សាក្នុងគ្រួសារ ។ ដូច្នេះបញ្ហានៃអំពើហិង្សាក្នុងគ្រួសារនេះ គឺមានកម្រិតខ្ពស់ ។ ហើយជាបញ្ហាមួយដែលយើងដោះស្រាយ ជាប់ជាប្រចាំនៅក្នុងសហគមន៍របស់យើង ។

**ស៖** លោកបានបញ្ជាក់ថា នៅក្នុងថាគោលនយោបាយមួយរបស់របបខ្មែរក្រហមនោះគឺបំបែកសមាជិកក្រុមគ្រួសារចេញពីគ្នា ដើម្បីឲ្យគេនៅឆ្ងាយពីគ្នា ដូចថាកូនរស់នៅឆ្ងាយពីឪពុកម្តាយ ហើយនិងឲ្យគេធ្វើការមួយចំនួន ដូចជាតាមដានរាយការណ៍ពីឪពុកម្តាយ ដែលថាមិនមែនជាដំណើរការធម្មតារបស់ក្រុមគ្រួសារនោះទេ ។ តើលោកបានពិនិត្យឃើញផលវិបាក ដែលកើតចេញអំពីការបំបែកសមាជិកក្រុម

គ្រួសារបែបនេះទេ បន្ទាប់ពីការបញ្ចប់នូវរបបនោះទៅនោះ? ហើយនិងដែលជីវិតធម្មតាដែលគេបន្តរស់នៅជុំគ្នាឡើងវិញ តើអ្វីជាផលប៉ះពាល់មកនោះ?

**ឆ៖** ខ្ញុំបាទកត់សម្គាល់ឃើញនូវបញ្ហាមួយ ។ យើងសង្កេតឃើញថា កុមារត្រូវរស់នៅជាមួយឪពុកម្តាយ ។ កុមារត្រូវមានការបីបាច់ពីឪពុកម្តាយ ជាពិសេសនៅក្នុងសង្គមគ្រួសារកម្ពុជា យើងមាននូវទម្លាប់សីលធម៌ក្នុងការគោរពចាស់ទុំ សីលធម៌នៅក្នុងការទំនាក់ទំនងផ្សេងៗ ។ ហើយប៉ុន្តែនៅក្នុងសម័យខ្មែរក្រហម កុមារត្រូវបានគេបំបែកចេញពីគ្រួសារ ។ កុមារត្រូវបានគេអប់រំថា ជាកូនរបស់អង្គការ មិនមែនជាកូនក្រុមគ្រួសារទៀតទេ ។ អ៊ីចឹង កុមារបានបាត់បង់នូវអត្តសញ្ញាណខ្លួនឯងថា តើខ្លួនឯងជាអ្នកណា? ជាបុគ្គលដែល-- ជាកម្មសិទ្ធិរបស់គ្រួសារ? ឬក៏កម្មសិទ្ធិរបស់អង្គការ?

នៅពេលនោះគឺពួកគេ បង្ខំឲ្យយើងជឿថា កុមារជាកម្មសិទ្ធិរបស់អង្គការ ។ អ៊ីចឹង កុមារអាចធ្វើអ្វីៗទាំងអស់ ទៅតាមការអង្គការប្រើ ។ កុមារត្រូវបានគេបំប៉ន បំពាក់បំប៉ន ដូចថាដើម្បីឲ្យសម្លាប់ ឬក៏ដើម្បីឲ្យធ្វើអ្វីៗផ្សេងៗ ។ កុមារត្រូវគេបានចិញ្ចឹមបីបាច់ថែរក្សា តាមរបៀបឃោរឃៅ របៀបយកការណ៍ របៀបគំរាមកំហែង ។ ប៉ុន្តែ ខ្ញុំបាទសូមកត់សម្គាល់ថាកុមារសម័យនោះ នៅពេលបច្ចុប្បន្ននេះគាត់ជាឪពុកម្តាយរបស់គេហើយ ។ អ៊ីចឹងបញ្ហាមួយដែលយើងអាចជួបប្រទះគឺថា ការចិញ្ចឹមបីបាច់ថែរក្សាកូនរបស់គាត់ហ្នឹង គឺស្ថិតនៅក្នុងលក្ខណៈប្រហាក់ប្រហែល ឬក៏របៀបដែលគាត់ត្រូវបានគេចិញ្ចឹមបីបាច់នៅក្នុងសម័យខ្មែរក្រហម ។ នេះគឺជាបញ្ហាដែលលំបាក ។ នេះគឺជាបញ្ហាប៉ះពាល់ធ្ងន់ធ្ងរ ។

សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីជូនទៅអ្នកជំនាញទៀតទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ។

[០៩:៥៤:៥៤]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមជម្រាបសួរលោកវេជ្ជបណ្ឌិត! ខ្ញុំមានសំណួរមួយចំនួនតូចសួរទៅលោក ។ ខ្ញុំបានឮលោកបញ្ជាក់ថាពលរដ្ឋកម្ពុជា ដែលថាសែសិបភាគរយនៃពលរដ្ឋដែលមានអាយុខ្ពស់ជាង១៨ឆ្នាំ ដែលទទួលបានជំងឺបាក់ស្បាត ។ លោកបញ្ជាក់ថា ជំងឺបាក់ស្បាតបែបនេះ មនុស្សមួយចំនួនគឺថាអាចនឹងមាន

អារម្មណ៍រំជើបរំជួលឡើងវិញ នៅពេលដែលរំឭកពីអតីតកាល ជាឧទាហរណ៍នោះ គឺគេអាចមានសុបិនអាក្រក់ ។ ខ្ញុំចង់ដឹងបន្តទៅទៀត ថាតើអ្វីជាផលប៉ះពាល់នៃ-- ដែលយើងសវនាការរបស់ពេលយើងពេលនេះ ឧទាហរណ៍ថា វាអាចមានផលប៉ះពាល់អ្វីទៅលើជនរងគ្រោះ ដែលយើងបានឱ្យបុគ្គលមួយចំនួនមកបង្ហាញអំពីការឈឺចាប់ ហើយនិងជំងឺបាក់ស្បាតរបស់គាត់ ឬក៏អាចជាការបង្កឱ្យមានងើបឡើងវិញនៃជំងឺហ្នឹងដែរទេ? ឬក៏អាចធ្វើឱ្យជនរងគ្រោះទាំងអស់នោះ អាចរំងាប់ដែលគេមានក្នុងចិត្តហ្នឹងបាន?

**ឆ៖** បាទ, សូមអរគុណលោកចៅក្រម ។ ខ្ញុំបាទសូមបញ្ជាក់ថា វាមានករណីទាំងពីរ គឺថាការកាត់ទោសមេដឹកនាំខ្មែរក្រហម វាជាឱកាសដែលធ្វើឱ្យជនរងគ្រោះ ដែលៗទុកនូវការឈឺចាប់កន្លងមកជាយូរឆ្នាំមកហើយ បានទទួលនូវការជាសះស្បើយនៃបញ្ហាផ្លូវចិត្តរបស់គាត់ តាមរយៈយុត្តិធម៌ដែលពួកគាត់នឹងទទួលពីតុលាការ តាមរយៈការពិត ដែលពួកគាត់បានស្តាប់ឮពីសាក្សី និងអំពីជនជាប់ចោទ ឬក៏ភាគីពាក់ព័ន្ធផ្សេងៗទៀត ។

ដូច្នេះ ប្រសិនបើដំណើរការនៃការកាត់ទោស ដំណើរការនៃការរកយុត្តិធម៌បានប្រព្រឹត្តទៅដែលគាត់អាចទទួលបាន ។ ខ្ញុំជឿថា វាការមួយដែលធ្វើឱ្យបញ្ហាផ្លូវចិត្តដែលដក់ទុកយូរណាស់ហើយហ្នឹងអាចជាសះស្បើយ ឬក៏អាចធ្វើដំណើរឆ្ពោះទៅរកការជាសះស្បើយ ពីព្រោះវាអាចមាននូវដំណើរការច្រើនទៀតដើម្បីជួយគាត់ក្នុងការជាសះស្បើយពីរបប អំពីការប៉ះទង្គិចផ្លូវចិត្តនុ៎ង ។

ប៉ុន្តែ ដូចខ្ញុំបានជម្រាបពីមុនមកហើយថា ជងរងគ្រោះក្នុងសម័យខ្មែរក្រហម ដែលយើងឃើញថាអ្នកខ្លះគិតថាគាត់មើលទៅហាក់ដូចជាមិនមានបញ្ហាអីទេកន្លងមក ពីព្រោះគាត់ធ្វើការបាន គាត់រស់នៅបានមកដល់សព្វថ្ងៃ ប៉ុន្តែសូមបញ្ជាក់ថាបញ្ហាផ្លូវចិត្តរបស់គាត់នៅក្នុងកប់ទុកនៅក្នុងកម្រិតមួយ កម្រិត *អាន់ខនស្យើស* មួយ ហើយកម្រិតនឹងវាងាយនឹងកើតឡើងៗវិញ ប្រសិនបើមានការរំឭកនឹកឃើញមាន *ទ្រីកហ្គឺ* អ្វីដែលៗធ្វើឱ្យគាត់ជួប ។ ឧទាហរណ៍ ជនរងគ្រោះមួយចំនួនដែលជា *ខ្លាយអិន* របស់ខ្ញុំ ខ្ញុំបានជួបហ្នឹង គាត់ថា បញ្ហារបស់គាត់បានធូរស្រាលជាយូរមកហើយ ប៉ុន្តែនៅពេលដែលការសវនាការកាត់ទោសនេះ គាត់មើលនូវកាត់ទោសនេះ គឺធ្វើឱ្យគាត់ឈឺចាប់ឡើងវិញ ។ អ៊ីចឹង ការឈឺចាប់ហ្នឹង វាកើតមានវាចៀសមិនផុតទេ បងប្អូនជនរងគ្រោះជាច្រើនណាស់ ដែលនឹងរងនូវការឈឺចាប់ដោយសារការនឹកឃើញនូវអតីតកាលឡើងវិញនោះ ។

ដូច្នេះ វាអាចជាការឈឺបាច់មួយ ដែលមុនឈានរហូតទៅដល់ការជាសះស្បើយ ។ ហើយអ៊ីចឹង

ហើយបានជាអង្គការ ធីភីអូ យើងខ្ញុំបានបង្កើតជាសេវាមួយ ដើម្បីអប់រំផ្សព្វផ្សាយឲ្យគាត់យល់អំពីបញ្ហាផ្លូវចិត្តដែលគាត់អាចនឹងកើតមាន ។ អ៊ីចឹង នៅពេលដែលគាត់ដឹង នៅពេលដែលគាត់យល់អំពីបញ្ហាផ្លូវចិត្តអាចគាត់មាន ចំពោះខ្លួនគាត់ ធ្វើឲ្យគាត់នឹងមិនសូវមានការភ័យ មិនសូវការព្រួយបារម្ភ ហើយក៏យើងមានជាសាវាទូរស័ព្ទ *ហតឡាញ* ដើម្បីជួយឲ្យគាត់ហ្នឹង អាចទូរស័ព្ទមករកយើង ឬក៏ផ្តល់សេវាផ្តល់ប្រឹក្សាតាមទូរស័ព្ទ ចំពោះគាត់នៅឆ្ងាយ ឬក៏សេវាផ្តល់ប្រឹក្សានៅនឹងការិយាល័យ ឬក៏សេវាព្យាបាលផ្សេងៗទៀត ដើម្បីជួយគាត់ ។

[០៩:៥៩:៣៣]

អ៊ីចឹងយើងគិតថាវាមានការប៉ះពាល់ ក្រោយពីសវនាការកើតឡើង ប៉ុន្តែ យើងក៏បានត្រៀមខ្លះដើម្បីជួយគាត់ដែរ ។ សូមអរគុណ បាទ ។

**ស៖** ថាតើការប៉ះទង្គិចផ្លូវចិត្តដែលប្រជាជនកម្ពុជារងគ្រោះនោះ តើវាមានជាប់ពាក់ព័ន្ធទៅនឹងប៉ះទង្គិចផ្លូវចិត្តដែលវាទាក់ទងទៅនឹងអង្គការដែរឬទេ? បានន័យថា តើការប៉ះទង្គិចផ្លូវចិត្តនេះជាប់ទៅនឹងអង្គភាព ឬក៏អង្គការមួយដែលមិនមានអត្តសញ្ញាណច្បាស់លាស់? អ្វីដែលយើងរៀបរាប់ នឹងពិភាក្សាគ្នាទៅលើអង្គហេតុនេះ គឺវាទាក់ទងទៅនឹងអត្តចរិតបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ថាតើវាបានបង្កើតជារូបភាពណាមួយ? ហើយថាការជាប់ទាក់ទងគ្នារវាងចំណុចទាំងអស់នេះ វាអាចឲ្យយើងជួយដោះស្រាយបានទៅលើបញ្ហាប៉ះទង្គិចផ្លូវចិត្តដែរឬទេ?

**ឆ៖** ខ្ញុំស្តាប់សំណួរអត់បាន សុំទោស ។

**ស៖** ចំពោះខ្ញុំៗយល់ឃើញថា លក្ខណៈពិសេសនៃការឈឺចាប់ប្រជាជនកម្ពុជាទទួលនោះ គឺវាទាក់ទងទៅនឹងការឈឺចាប់ ដែលអង្គការអរូបិយមួយធ្វើចំពោះគាត់ បានន័យថា អង្គការបានប្រព្រឹត្តចំពោះគាត់ ហើយខ្ញុំចង់សួរថា ខ្ញុំចង់សួរលោក តើលោកអាចឆ្លើយបានដែរឬទេ? អ្វីដែលពិភាក្សាដេញដោលគ្នានៅទីនេះ គឺមិនត្រឹមតែអង្គហេតុនោះទេ គឺវាទាក់ទងនៅនឹងការសារភាពរបស់ជនជាប់ចោទផង ហើយនិងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ។

ដូច្នេះ ការដែលយើងពិភាក្សាដេញដោលទៅលើចំណុចទាំងអស់នេះ តើវាអាចផ្តល់ជារូបភាពមួយទៅលើបញ្ហានៃការប៉ះទង្គិចផ្លូវចិត្តដែរឬទេ? ហើយវាអាចជួយព្យាបាលបញ្ហាផ្លូវចិត្តដែរឬទេ? ហើយបញ្ហានេះវាអាចជម្រះចេញនូវការភ័យខ្លាចផ្សេងៗដែរឬទេ ដែលវាប៉ះទង្គិចចំពោះប្រជាជនកម្ពុជានោះ?

[០៩:០២:៥៧]

**ឆៈ** បាទ, សូមអរគុណ ។ វាជាបញ្ហាពិបាកនៅឯការឆ្លើយថា តើបញ្ហានេះ វានឹងជួយជម្រះបញ្ហាផ្លូវចិត្ត ឬក៏យ៉ាងណា? គឺជាការ-- ជាសំណួរមួយដែលលំបាក ។ ប៉ុន្តែ ខ្ញុំបាទ សូមចង់បង្ហាញថា យើងដឹងហើយក្នុងសម័យខ្មែរក្រហម គេប្រើពាក្យ "អង្គការ" "អង្គការថ្នាក់លើ" ។ អង្គការថ្នាក់លើជាអ្នកបញ្ជា ។ អង្គការថ្នាក់លើ ជាអ្នកបង្ខំឲ្យធ្វើនេះធ្វើនោះ ។ យើងមិនដឹងថាអង្គការថ្នាក់លើហ្នឹង ជាអ្នកណា? មិនដឹងជាមេដឹកនាំមួយណា?

អ៊ីចឹងវាបង្កើតជាប្រព័ន្ធមួយដែលមានភាពអរូបិយ ដែលមានភាពមិនច្បាស់លាស់ ។ ដល់ពេលក្នុងធ្វើសវនាការទៀត យើងបានឮមេដឹកនាំ អតីតមេដឹកខ្មែរក្រហមមួយចំនួនធំហើយ ដែលគាត់ឆ្លើយទៅលើអង្គការថ្នាក់លើ ដែលគាត់ឆ្លើយទៅលើអ្នកដែលមួយអរូបិយដែលគាត់ ដូចថាគាត់ប្រកែកនឹងទទួលការខុសត្រូវនូវរឿងរ៉ាវដែលកើតឡើង ទោះបីជាយើងដឹងថាគាត់នៅក្នុងតំណែងដ៏ធំៗនៅក្នុងសម័យនោះក៏ដោយ ។ ទាំងអស់នេះ វាធ្វើឲ្យជនរងគ្រោះយើងហ្នឹង មានការឈឺចាប់រឹតតែខ្លាំងឡើង មានការពិបាកទ្រាំ ពិបាកមើលចំពោះអាកប្បកិរិយាប្រកែក ចំពោះនូវភាពមិនទទួលខុសត្រូវរបស់គាត់ ។

ដូច្នេះ ដំណើរការនៃការជាសះស្បើយនៃការកាត់ទោសនេះ វាអាស្រ័យទៅលើ ដូចថា *វិលីងណេស* របស់ជនជាប់ចោទក្តី ដើម្បីបង្ហាញនូវការពិត ដើម្បីបើកឲ្យច្បាស់មើលថា តើអ្នករូបិយ អរូបិយហ្នឹងជាអ្នកណានៅក្នុងការទទួលខុសត្រូវអំពី អំពើប្រល័យពូជសាសន៍នៅសម័យខ្មែរក្រហម? ប្រសិនបើការបើកបង្ហាញនេះ មិនឃើញទេ ខ្ញុំជឿថារបួសផ្លូវចិត្ត ដំបៅរបស់ប្រជាជនទុំង មិនបានជាសះស្បើយទេ ។ យើងឃើញហើយថា សាក្សី ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលគាត់មិនទទួលយកពីព្រោះគាត់គិតថា វាជារឿងមួយដែលមិនសមស្រប ដែលជារឿងមួយដែលមិនមែនជាការពិត ។ អ៊ីចឹងអាការជាសះស្បើយហ្នឹងក៏មិនអាចមានដែរ ថ្វីដ្បិតតែការឡើងធ្វើសក្ខីកម្មនេះ អាចជួយបន្ធូរសម្រាលបន្ទុកនៃបញ្ហាផ្លូវចិត្តខ្លះក៏ដោយ ។ សូមអរគុណ ។

**សៈ** ចំពោះការព្យាបាលទៅហ្នឹងការប៉ះទង្គិចផ្លូវចិត្តនេះ គឺវាមានលក្ខណៈសំខាន់ណាស់ដូចដែលលោកបានរៀបរាប់ ។ លោកបានជម្រាបយើងខ្ញុំថា អង្គការរបស់លោក បើកលទ្ធភាពប្រឹក្សាទៅដល់អ្នកប៉ះទង្គិចផ្លូវ ហើយគឺអង្គការរបស់លោកមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។ ហើយលោកក៏ចង់ធ្វើការពង្រីកទៅលើអង្គការរបស់លោក ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ ភាពចាំបាច់ពិតប្រាកដនោះគឺជាអ្វី ដើម្បីធានាទៅដល់ការព្យាបាល ការប៉ះទង្គិចផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជានោះ?

**ឆ៖** បាទ, ការព្យាបាលនៃការប៉ះទង្គិចផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជានុំង ត្រូវចាំបាច់ធ្វើឡើងដោយមានការរួមគ្នាពីស្ថាប័នជាច្រើន ។ ការស្វែងរកយុត្តិធម៌ ស្ថាប័នតុលាការ ការផ្សះផ្សា និងការអប់រំ ឬក៏បញ្ហាអីផ្សេងៗទៀតដែលទាក់ទងទៅនឹងរបបប្រល័យពូជសាសន៍នេះ ត្រូវកើតមានទន្ទឹមគ្នាជាមួយនឹងការព្យាបាលខាងផ្នែកចិត្តសាស្ត្រ ។

ខ្ញុំបាទមិនគិតថា ការផ្តល់អន្តរាគមន៍ខាងផ្នែកចិត្តសាស្ត្ររបស់អង្គការយើងខ្ញុំ គឺជាវិធីមួយដើម្បីជួយជនរងគ្រោះនៅក្នុងសម័យខ្មែរក្រហម ឲ្យជាសះស្បើយអំពីបញ្ហាផ្លូវចិត្តទេ ។ ដូច្នេះ ចាំបាច់ត្រូវមានស្ថាប័នផ្សេងជាច្រើន រួមមានទាំងស្ថាប័នតុលាការនេះឯង រួមមានការផ្សះផ្សា ឬក៏យុទ្ធសាស្ត្រផ្សេងៗដែលសម្រួលឲ្យមានការសន្ទនា ឲ្យមានការអភ័យទោសឲ្យមានការទទួលស្គាល់នូវរឿងរ៉ាវ ដែលកើតឡើង ហើយនុំងហើយរួមផ្សំនឹងសេវាសុខភាពផ្លូវចិត្តហ្នឹងហើយ ដែលជួយឲ្យប្រជាជនយើងអាចជាសះស្បើយអំពីបញ្ហាផ្លូវចិត្តបាន ។

[១០:០៧:៥៧]

**ស៖** នៅក្នុងលក្ខណៈជាក់ស្តែងពិតប្រាកដ តើលោកអាចជម្រាបយើងដែរឬទេ? តើលោកមានសម្ព័ន្ធភាពជាមួយនឹងគ្លីនិក ហើយនិងមន្ទីរពេទ្យដែរឬទេ? ហើយថាជនរងគ្រោះមិនត្រឹមតែអាចទាក់ទងទៅនឹងអង្គភាពរបស់លោកទេ ហើយអាចទាក់ទងទៅនឹងស្ថាប័នផ្សេងៗទៀត ។ ជាពិសេសចំពោះអ្នកដែលនៅរស់នៅក្នុងទីប្រជុំជនឆ្ងាយៗ ដូចជាតាមជនបទផ្សេងៗ តើពួកគេអាចទំនាក់ទំនងយ៉ាងម៉េច?

**ឆ៖** សេវាសុខភាពផ្លូវចិត្តរបស់អង្គការ ធីភីអូ គឺមាននៅក្នុងភ្នំពេញ ហើយនិងនៅក្នុងខេត្តចំនួនបួនទៀត គឺពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ កំពង់ធំ ។ ក្រៅពីសេវាសុខភាពផ្លូវចិត្តរបស់អង្គការធីភីអូ គឺមានសេវាពិគ្រោះជំងឺផ្លូវចិត្តរបស់រដ្ឋាភិបាលនៅក្នុងមន្ទីរមិត្តភាពខ្មែរ-សូវៀត នៅក្នុងមន្ទីរពេទ្យព្រះកុសមៈនៅរាជធានីភ្នំពេញ ។ ហើយនៅតាមខេត្តក៏មានសេវាសុខភាពផ្លូវចិត្តរបស់រដ្ឋាភិបាលនៅក្នុងមន្ទីរពេទ្យបង្អែកផ្សេងៗ ដូចជានៅក្នុងមន្ទីរពេទ្យបង្អែកខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តតាកែវ អាចមាននៅខេត្តផ្សេងទៀត ប៉ុន្តែផ្តល់សេវាដោយគ្រូពេទ្យទូទៅ ដូចជាខេត្តកំពង់ឆ្នាំង ខេត្តកំពត ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកវេជ្ជបណ្ឌិត ដែលលោកបានឆ្លើយបំភ្លឺនូវចំណុចទាំងអស់នេះ ។

សូមអរគុណលោកប្រធាន ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១០:២៥]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះអ្នកជំនាញរូបនេះ ប្រសិនបើមានសំណួរ ។ ហើយពេលវេលាសម្រាប់តំណាងសហព្រះរាជអាជ្ញាគឺដប់ប្រាំមីនុត ហើយក្នុងករណីចាំបាច់គឺអាចសំណើសុំមកអង្គជំនុំជម្រះ ដើម្បីអាចបន្ថែមឲ្យបាន ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** បាទ, សូមអរគុណប្រធាន ។ ជម្រាបសួរលោកវេជ្ជបណ្ឌិត! ជាទូទៅចំពោះជនរងគ្រោះដែលបាក់ស្បាតក្នុងរបបខ្មែរក្រហម ហើយត្រូវបានគេបង្ខំឲ្យធ្វើការជាទម្ងន់ ដោយមិនបានទទួលនូវការតបស្នងជាវិជ្ជមានអ្វីទាល់តែសោះនោះ។ តើបញ្ហាទាំងនេះវាអាចប៉ះពាល់ទៅដល់ការអភិវឌ្ឍក្រុមគ្រួសារ ឬក៏ ក៏ដូចជាការអភិវឌ្ឍសង្គមយ៉ាងម៉េចដែរ? ព្រោះថាកន្លងមកពួកគេធ្វើការដោយមិនបានទទួលអ្វីតបស្នងជាវិជ្ជមានទាល់តែសោះ ក្រៅពីការបំភិតបំភ័យ ឬក៏ជាការគម្រាមកំហែងជាដើម ។ អ៊ីចឹងថាតើប៉ះពាល់យ៉ាងម៉េចខ្លះចំពោះការអភិវឌ្ឍប្រទេស ក៏ដូចជាក្រុមគ្រួសាររបស់គេហ្នឹង?

**ឆ៖** បាទ, សូមអរគុណ ។ ចំពោះការប៉ះពាល់នេះ ខ្ញុំបាទ សូមងាកទៅខាងក្រោយបន្តិចថាជនរងគ្រោះមួយចំនួន យើងគិតថាគាត់ជាកុមារ ឬក៏សមាជិកគ្រួសារ នៅពេលដែលសព្វថ្ងៃនេះ នៅពេលដែលខ្មែរក្រហមសម្លាប់បងប្អូនគាត់ចោល សម្លាប់ឪពុកម្ដាយ ។ ឧទាហរណ៍ថា គ្រួសារខ្លះ ឪពុក គឺជាមនុស្សសំខាន់ដែលជាអ្នករកចំណូលនូវថវិកាចិញ្ចឹមគ្រួសារ ឬក៏ឱកាសណាមួយដែលគាត់បាត់នៅក្នុងសម័យ-- គេសម្លាប់ចោល ដូចថាគេសម្លាប់ចោលឪពុកហ្នឹង វាធ្វើឲ្យបាត់ឱកាសសម្រាប់គាត់ ។ អ៊ីចឹងគាត់នៅតែស្រមៃថា ប្រសិនបើឪពុកគាត់នៅរស់ ឬក៏បងប្អូនគាត់នៅរស់ គាត់មិនមែនលំបាកវេទនា ឈឺចាប់ដូចសព្វថ្ងៃនេះទេ ។

ហើយអ៊ីចឹង គាត់ចិញ្ចឹមគាត់ចិត្តនៅការឈឺចាប់ ចិញ្ចឹមចិត្តនូវការសោកស្ដាយ ដែលទាំងនេះវាប៉ះពាល់ដល់ការគិត ការរស់នៅប្រចាំថ្ងៃរបស់គាត់ ដែលប៉ះពាល់នូវការប្រកបមុខងាររបស់គាត់ បូកទាំងការរៀនសូត្រ និងការរកទទួលទាន ។ អ៊ីចឹងធ្វើឲ្យជីវភាពគ្រួសារគាត់អាចចុះថយ ។

អ្នកដែលមានបញ្ហាផ្លូវចិត្តមួយចំនួនទៀត រងនូវសុរា ដូចយើងសម្រាប់ហើយ គាត់ញៀនសុរា អ៊ីចឹងទៅគាត់មិនទៅប្រកបមុខរបបបាន ។ អ៊ីចឹងហើយវាប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ ហើយការប៉ះពាល់ដល់សេដ្ឋគ្រួសារក្នុងកម្រិតច្រើនទៅ វាអាចប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមជាតិ ។

យើងមើលថាប្រសិនបើតួលេខដែលលោកសាស្ត្រាចារ្យ យោក លីយ៉ុង បានបង្ហាញក្នុងចំណោមពីរនាក់ មានប្រាំនាក់មានបញ្ហាផ្លូវចិត្តហ្នឹង ជាតួលេខពិត ហើយអាចប្រើប្រាស់ជាទូទៅក្នុងប្រទេសកម្ពុជា ។ យើងឃើញថា គឺជាការមួយធ្ងន់ ដែលប្រជាជនរងនូវបញ្ហាផ្លូវចិត្តនៅក្នុងប្រទេស ហើយទាំងនេះវាប៉ះពាល់ដល់កម្លាំងប្រកបបង្កើនសេដ្ឋកិច្ចរបស់ជាតិយើង ។

ហើយខ្ញុំបាទសូមលោកមួយទៀថា ចំពោះកុមារនៅក្នុងសម័យខ្មែរក្រហម ដែលជំនាក់ហ្នឹងគាត់ជាកុមារណ៎ា ហើយឥឡូវគាត់ជាឪពុកម្ដាយ ហើយគាត់អប់រំកូនចៅតាមរបៀបដែលគាត់ទទួលការអប់រំក្នុងសម័យខ្មែរក្រហម ។ អាន៎ុង វាប៉ះពាល់ដល់ៗកុមារ ហើយមើលថា-- ប៉ះពាល់ដល់កូនចៅរបស់គាត់។ ហើយមើលថា នៅក្នុងសម័យឥឡូវនៅក្នុងប្រទេសកម្ពុជាយើង បើយើងមើលអាយុនៅក្នុងជំរឿន យើងឃើញថា ភាគីច្រើននៃប្រជាជនយើង អាយុម្ភៃឆ្នាំ ឬក្រោមម្ភៃ គឺមានចំនួនច្រើនណាស់ជាងសែសិបភាគរយ ។ យើងមើលតែក្នុងកម្រិតដប់ ឬក៏ម្ភៃឆ្នាំទៅមុខទៀត គាត់នឹងមានអាយុដល់សែសិប ហើយនៅពេលហ្នឹង គាត់ជាការកម្លាំងអូសទាញសម្រាប់កម្លាំងចលករនៃសេដ្ឋកិច្ចរបស់កម្ពុជាយើង ។ ចុះបើគាត់ប៉ះទង្គិចផ្លូវចិត្តហើយ ហើយបញ្ហាប៉ះទង្គិចផ្លូវចិត្តមិនបានដោះស្រាយ ។ អ៊ីចឹងអាហ្នឹង វាជាការប៉ះពាល់ផ្លូវចិត្តមួយសម្រាប់ប្រទេសជាតិយើងទាំងមូល ។ សូមអរគុណ ។

[១០:១៥:២០]

**សួរដោយលោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

លោកប្រធាន! ខ្ញុំប្រហែលជាមានសំណួរប្រាំពីរទៀតចង់សួរ ប្រសិនបើលោកប្រធានអនុញ្ញាត ហើយខ្ញុំគិតថា យើងអាចនឹងចំណាយពេលលើសពេលកំណត់ ។ វាអាស្រ័យទៅលើចម្លើយជាក់លាក់របស់លោកវេជ្ជបណ្ឌិត ហើយប្រសិនបើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបញ្ចប់នោះ គឺថាសូមលោកប្រធានបញ្ជាក់ខ្ញុំ ។

**ស៖** ខ្ញុំចង់សួរថា ចំពោះជនរងគ្រោះដែលបានតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណី ថាតើវាមានសារសំខាន់យ៉ាងម៉េចចំពោះគាត់ ដែលគាត់មកចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខសាធារណជន? ថាតើជនរងគ្រោះអាចដើរតួនាទីជាកត្តាមួយជួយទៅដល់បញ្ហាផ្លូវចិត្តដែរឬទេ ដែលវាអាចជួយសង្គ្រោះ

ទៅលើការប៉ះទង្គិចការឈឺចាប់ និងការផ្លូវចិត្តរបស់គាត់នៅក្នុងប្រទេសកម្ពុជានោះ?

**ឆ៖** បាទ, ដូចខ្ញុំបាទបានលើកតាំងពីដើមមក ការកាត់ក្តីនេះ វាអាចជាឱកាសមួយដល់ជនរងគ្រោះបានទទួលនូវព័ត៌មានអំពីការពិតទៅលើឧក្រិដ្ឋកម្ម ដែលបានកើតមានទៅលើបងប្អូនរបស់គាត់ ឬក៏ទៅលើគាត់ ឬក៏សាច់ញាតិអីផ្សេងៗទៀត ។ អ៊ីចឹង គឺជាឱកាសមួយដែលគាត់បានដឹង ហើយការបានដឹងនេះ វាអាចជួយបន្ធូរការធូរស្រាលនៅក្នុងផ្នែកតានតឹងផ្លូវចិត្ត ។

កាលដែលគាត់ឡើងមកបំភ្លឺ កាលដែលគាត់ដំណើរការនៅក្នុងការដាក់ពាក្យបណ្តឹង ហើយនិងឡើងមកបំភ្លឺ ប្រាកដណាស់គឺជាវេទិកាមួយ គឺជាបរិយាកាសមួយ ជាឱកាសមួយដែលគាត់នឹងបានបញ្ចេញនូវរឿងរ៉ាវដែលគាត់លាក់ទុកតាំងពីយូរឆ្នាំមកហើយ ដើម្បីឲ្យសាធារណជនបានដឹង ។ ពីព្រោះថា នៅក្នុងសង្គមកម្ពុជាយើង សម័យការពិភាក្សានៅក្នុងរបបខ្មែរក្រហម មិនត្រូវបានកើតមានឡើងនៅក្នុងកម្រិតគ្រួសារ ឬក៏កម្រិតសហគមន៍ ឬក៏ក្នុងកម្រិតណាមួយណាទេ ។ យើងឃើញថា ការសិក្សាអំពីរបបប្រល័យពូជសាសន៍មិនបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅក្នុងប្រវត្តិសាស្ត្ររបស់សាលារៀនហ្នឹងទេ ។

[១០:១៨:០១]

យើងឃើញថា ប្រជាជនចៀសវៀងនូវការនិយាយ នូវការពិភាក្សា យើងហាក់ដូចជាមានជា *ខនស្ពារ៉េស៊ី អហ្វ សាយឡិន* ឬក៏ *ខនស្ពារ៉េស៊ី អហ្វ អ៊ីហ្វយដិន* (និយាយភាសាអង់គ្លេស) ដែលពួកគាត់ហ្នឹង គឺរួមគ្នានៅក្នុងការមិនចង់បញ្ចេញយោបល់ រួមគ្នាក្នុងការគេចវេះចៀសវាងមិនចង់ពិភាក្សាអំពីបញ្ហា ។ ប៉ុន្តែ ការចៀសវាងនេះវាមិនបានជួយដល់គាត់ទេ ។ អ៊ីចឹង ការឡើងមកឡើងមកពិភាក្សាក្នុងការសក្ខីកម្មនេះ ដែលជាឱកាសមួយជួយនូវបញ្ហាផ្លូវចិត្តរបស់គាត់ ។ ជាការពិតបាទ ។

**ស៖** សូមអរគុណ ។ សំណួរទីពីររបស់ខ្ញុំ ថាតើលោកអាចពន្យល់តាមរបៀបណា តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននៅក្នុងតុលាការនេះ ជាជាង-- ទោះបីជាការកន្លងទៅពេលនៃពេលវេលាក៏ដោយ ការបាត់បង់នូវញាតិលោហិត និងញាតិពន្ធរបស់គេ និងសមាជិកគ្រួសាររបស់គេអាចកើតឡើងពីពេលមួយទៅពេលមួយ ទោះបីជាពេលវេលានោះវាយូរទៅហើយ ។ ជាពិសេស ចំពោះអ្នកដែលរស់នៅខាងក្រៅប្រទេស នៅក្នុងប្រទេសផ្សេងៗដែលពួកគេបាត់បង់នូវក្រុមគ្រួសារ ទោះបីជាពួកគេទទួលនូវការព្យាបាលផ្លូវចិត្តក៏ដោយ ។ ថាតើលោកយល់យ៉ាងម៉េចចំពោះការគិតពិចារណា និងយល់ឃើញរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏អ្នកមួយចំនួនដែលគេរស់នៅឆ្ងាយ? ហើយគេយល់យ៉ាងម៉េច

ចំពោះការឈឺចាប់របស់គេ ដែលបានបាត់បង់គ្រួសារនោះ?

[១០:១៩:៥៧]

**ផ៖** ខ្ញុំបាទសូមបញ្ជាក់ថា បញ្ហាវប្បធម៌ បញ្ហាជំនឿ សាសនា ទំនៀមទម្លាប់ប្រពៃណី ដែលពួកខ្មែរក្រហមព្យាយាមកម្ទេចចោលនោះ វាគឺជាបញ្ហាមួយដែលជួយជនរងគ្រោះឲ្យបានជាសះស្បើយអំពីបញ្ហាឈឺចាប់ផ្លូវចិត្ត ឬក៏ការទារុណកម្មដែលគាត់បានជួបប្រទះ ។

ខ្ញុំបាទបានលើកហើយថា ប្រជាជនយើងនៅពេលដែលមានការឈឺចាប់បានព្យាយាមរកនូវវិធីសាស្ត្រមួយដើម្បីពន្យល់ដោយផ្តល់អត្ថន័យនៅអ្វីដែលកើតឡើង ហើយអត្ថន័យដែលគាត់ផ្តល់ឲ្យទៅលើអ្វីដែលកើតឡើងនោះ វាអាចមានអត្ថប្រយោជន៍ក្នុងការជួយគាត់ ឬមួយឲ្យមានជាសះស្បើយអំពីបញ្ហាផ្លូវចិត្ត ឬមួយក៏អាចបន្តនៅបញ្ហាផ្លូវចិត្ត ឬក៏វដ្តនៃអំពើហិង្សាតទៅទៀត ។

ចំពោះជនរងគ្រោះ ដែលរស់នៅក្រៅប្រទេស ខ្ញុំគិតថាវាជាការលំបាក ពីព្រោះគាត់បានរស់នៅឆ្ងាយអំពីវប្បធម៌ អំពីទំនៀមទម្លាប់ អំពីប្រពៃណី អំពីអ្វីៗដែលកើតមាននៅក្នុងប្រទេសកម្ពុជា ។ ដូច្នេះគាត់ហាក់ដូចជាការបាត់បង់នូវអ្វីមួយ ទោះបីជាគាត់ទៅដល់ប្រទេសខាងលិច ដែលគាត់មានជីវភាពធូរធារជាងមុន គាត់នៅក្នុងសង្គមមួយដែលមានសន្តិសុខល្អគ្រប់គ្រាន់ជាងមុន សុវត្ថិភាពជាងមុន ។ ប៉ុន្តែគាត់បាត់បង់នូវលក្ខណៈជំនឿ សាសនា ទំនៀមទម្លាប់ប្រពៃណី ម្ហូបអាហារ ទំនាក់ទំនងខាងផ្នែកភាសាដែលទាំងអស់នេះ គឺមានការពន្យារនៅការជាសះស្បើយរបស់គាត់ ដែលទុកឲ្យការឈឺចាប់ហ្នឹងនៅតែមានបន្ត ។

ខ្ញុំបាទលើកឧទាហរណ៍អតិថិជនខ្ញុំម្នាក់ដែលបានជួបនៅទីក្រុងស៊ីដនី ដែលខ្ញុំចុះធ្វើកម្មសិក្សា ។ គាត់ឃើញថា គាត់មានជីវភាពគ្រប់គ្រាន់ សព្វបែបយ៉ាងទាំងអស់ ។ ប៉ុន្តែ គាត់នៅមានការឈឺចាប់រ៉ាំរ៉ៃមួយ ដែលគ្រូពេទ្យមិនអាចរកថា ជាៗបញ្ហាអ្វីមួយ មូលហេតុអ្វីមួយច្បាស់លាស់ ។ ហើយដែលនៅទីនោះ គាត់ពិបាកក្នុងការគោរពបូជា ពីព្រោះមិនមានគ្រប់គ្រាន់ដូចនៅប្រទេសខ្មែរយើង ។ ប៉ុន្តែ នៅពេលដែលគាត់ត្រឡប់មកដល់ស្រុកខ្មែរ គាត់ចាប់ផ្តើមធ្វើបុណ្យរំឭកវិញ្ញាណក្ខន្ធ គាត់គោរពបូជាទៅដល់អ្នកដែល ឪពុកម្តាយដែលស្លាប់ ។ អ៊ីចឹង វាធ្វើឲ្យគាត់ធូរស្រាលក្នុងផ្លូវចិត្តមួយចំនួន ហើយនៅពេលគាត់ត្រឡប់ទៅវិញ បញ្ហារបស់គាត់ហ្នឹង បានថយចុះជាបន្តិចម្តងៗ ។ អ៊ីចឹងនេះ គឺជាការពន្យល់នូវអ្វីដែលកើតឡើង ។

**ស៖** លោកអ្នកជំនាញ ចំពោះកត្តាទាំងឡាយដែលអាចបង្កឱ្យមានការកើតឡើងចំពោះការប៉ះទង្គិចផ្លូវចិត្តនៅក្នុងចំណោមជនរងគ្រោះជាទូទៅ ។ យើងអាចធ្វើការសង្កេតទៅលើសេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះមួយចំនួននៅចំពោះមុខតុលាការនេះ ហើយជនរងគ្រោះមួយចំនួនយើងអាចកំណត់ឃើញតាមអ្វីដែលគាត់អះអាង ។

ជាបឋម ចំពោះរបៀបដែលបងប្អូនរបស់គេស្លាប់ ។ ឧទាហរណ៍ថា ការស្លាប់ដោយហិង្សាបន្ទាប់ពីឃុំខ្លួននៅស-២១ ការធ្វើទារុណកម្មនិងការខ្វះអាហារ ។ ហើយកត្តាមួយទៀតនោះ គឺគាត់មិនបានដឹងអំពីទម្រង់នៃការស្លាប់របស់សមាជិករបស់គ្រួសាររបស់គាត់ ។ បញ្ហានេះ គឺដោយសារតែកង្វះនៅមូលហេតុក្នុងការពន្យល់ចំពោះការស្លាប់របស់អ្នកទាំងអស់នោះ ហើយដោយសារតែមិនមានការពន្យល់ឱ្យបានច្បាស់លាស់ ។ ជាពិសេសអ្នកដែលគាត់បានលើកឡើងនោះ គឺគាត់លើកឡើងអំពីការដែលគាត់មិនបានដឹងអំពីការឈឺចាប់ ដែលទទួលរងគ្រោះ ដោយអ្នកទាំងអស់នោះ ហើយខ្ញុំជឿថា ទាំងអស់នេះ គឺវាជាកត្តាជំរុញឱ្យមានប៉ះទង្គិចផ្លូវចិត្តកើនឡើង ប៉ុន្តែតើលោកយល់ថា តើមានកត្តាណាផ្សេងទៀត ដែលវារុញច្រានទូវការប៉ះទង្គិចផ្លូវចិត្តនេះ?

[១០:២៤:២៨]

**ឆ៖** បាទ, កត្តាដែលមិនបានដឹងនូវរឿងរ៉ាវ មិនបានដឹងការពិត កត្តាផ្សេងៗ ចំពោះអ្វីដែលកើតឡើងហ្នឹង គឺជាកត្តាមួយដែលបន្តនូវការឈឺចាប់ នូវបញ្ហាផ្លូវចិត្ត ដែលបន្តឱ្យគាត់មានជាប់ជាប្រចាំ ។ បញ្ហាខ្វះខាតសេវាក្នុងការផ្តល់ដល់ជនរងគ្រោះ គឺជាបញ្ហាមួយទៀតដែលបន្ត ។ សូមបញ្ជាក់ថា នៅសព្វថ្ងៃនេះក្នុងប្រទេសកម្ពុជាយើង មានវេជ្ជបណ្ឌិតឯកទេសផ្លូវចិត្តចំនួនតែសាមសិបនាក់ប៉ុណ្ណោះទេ ដែលកាលពីខ្ញុំបាទ ចាប់ផ្តើមរៀនសូត្រនោះ គឺមានដប់នាក់ នៅឆ្នាំ៩៤-៩៨ ។

ដូច្នេះ បើប្រៀបធៀបជាមួយនឹងចំនួនប្រជាជនយើងដប់បួនលាននាក់ ដែលរងនូវការប៉ះទង្គិចដែលម្នាក់ៗសុទ្ធតែឆ្លងកាត់នូវការប៉ះទង្គិចសម័យខ្មែរក្រហមនោះ សេវាហ្នឹង គឺនៅតូចណាស់ បើប្រៀបធៀបទៅនឹងទំហំនៃការឈឺចាប់ ។ នៅក្នុងប្រទេសយើង កម្មវិធីសេវាផ្នែកសុខភាពផ្លូវចិត្ត មានតែខេត្តធំៗមួយចំនួន មិនមានដល់តំបន់ដាច់ស្រយាល ហើយអង្គការដែលផ្តល់សេវាសុខភាពផ្លូវចិត្តនេះគឺមានតិចណាស់ គឺអង្គការ ធីភីអូ មួយ និងអង្គការមួយ ឬពីរប៉ុណ្ណោះ ដែលធ្វើការងារក្នុងទំហំតូចទៅតាមសមត្ថភាព និងថវិកា ។

ហើយកត្តាមួយទៀត ដែលបន្តឱ្យការឈឺចាប់ហ្នឹងនៅតែបន្ត ខ្ញុំបាទនៅតែគិតថា ជនរងគ្រោះ

យើងមួយចំនួនធំ មានជីវភាពយ៉ាប់យ៉ឺនលំបាក ។ ដូច្នេះ គាត់នៅតែរវល់ គាត់នៅតែពិបាកជាមួយនឹងបញ្ហាដោះស្រាយជីវភាព រួមផ្សំនឹងការឈឺចាប់ដែលកន្លងមក ។ ចួនកាលការឈឺចាប់ ដែលធ្វើឲ្យគាត់ដោយសារខ្វះខាតខាងជីវភាព ។ នេះហើយដែលធ្វើឲ្យគាត់ហ្នឹង ពន្យារពេលក្នុងការស្វែងរកការជំនួយ។ អ៊ីចឹងចង់ មិនចង់ក៏ទ្រាំឈឺចាប់ក្នុងមួយរយៈ ដែលការឈឺចាប់ហ្នឹង វានៅតែបន្តឲ្យមានតទៅទៀត ។

ហើយករណីមួយទៀត ខ្ញុំបាទគិតថាជាកត្តាទូទៅ ដែលបងប្អូនយើងមួយចំនួនធំ ដោយសារការខ្វះខាតខាងជីវភាពហ្នឹងហើយ ដែលគាត់មិនបានធ្វើនៅពិធីបុណ្យ ឬក៏ពិធីសាសនាណាត្រឹមត្រូវដើម្បីបួងសួងផ្តល់គោរពវិញ្ញាណក្ខន្ធ ជូនដល់អ្នកដែលបានស្លាប់នោះបានគ្រប់គ្រាន់នៅឡើយទេ ។ ដូច្នេះហើយអានេះក៏ជាកត្តាមួយទៀតដែរ ដែលជំរុញឲ្យការឈឺចាប់ហ្នឹង នៅតែមានបន្ត ។ សូមអរគុណ ។

[១០:២៧:២២]

**ស៖** សូមអរគុណលោកច្រើន ។ មុនហ្នឹងបន្តិច លោកបានលើកឡើងដោយសង្ខេបអំពីកង្វះនៃការអត់ឱន ដែលដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនគាត់បានលើកឡើង ។ ថាតើយើងអាចពន្យល់យ៉ាងម៉េចចំពោះបុគ្គលម្នាក់ដែលគាត់មិនអាចអត់ឱនឲ្យបុគ្គលមួយទៀត ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន គឺគាត់មិនអាចអត់ឱនឲ្យជនចាប់ចោទនោះទេ ហើយអវត្តមាននៃការអត់ឱននេះគឺវាទាក់ទងទៅនឹងការសម្តែងចេញនៅវិប្បដិសារីរបស់ជនជាប់ ។ ដូច្នេះហើយ យើងត្រូវរកយុត្តិធម៌ទៅបញ្ហាទាំងអស់នេះ ដើម្បីយើងលុបចោលនៅនិទ្ទណ្ឌភាពផ្សេងៗ មុនពេលដែលយើងទទួលយកទៅលើការសុំទោសផ្សេងៗ និងការផ្សះផ្សាជាតិ។ ហើយមួយទៀតនោះ គឺយើងកំពុងតែស្ថិតនៅក្នុងដំណាក់កាលមួយដែលវាទាក់ទងទៅនឹងការផ្សះផ្សាជាតិ ដែលមានរយៈពេលយូរ ។

**ឆ៖** ខ្ញុំបាទគិតថា យើងត្រូវយល់នូវអ្វីទៅដែលជាតម្រូវការរបស់ជនរងគ្រោះ ។ ខ្ញុំបាទសូមបញ្ជាក់មុននឹងបន្តិចថា ទីមួយ មូលហេតុអ្វីដែលធ្វើឲ្យបញ្ហាផ្លូវចិត្តហ្នឹង វាមិនជាសះស្បើយ? បញ្ហាផ្លូវចិត្ត ដែលមិនជាសះស្បើយ អាចមានកត្តាច្រើន ។

ទីមួយ អាចកត្តាខួរក្បាលរបស់យើងតែម្តង ពីព្រោះការប៉ះទង្គិចផ្លូវចិត្តហ្នឹង វាអាចធ្វើឲ្យប៉ះពាល់នៅខួរក្បាល ប្រែប្រួលនៅសារជាតិគីមី អ្វីៗរ៉េផ្លិចអីនៅក្នុងខួរក្បាលហ្នឹង ដែលធ្វើឲ្យខួរក្បាលយើងហ្នឹងទុកជាប់ជាប្រចាំនៅរឿងរ៉ាវដែលកើតមាន ។

ទីពីរ ខ្ញុំបាទចង់និយាយទៅលើអត្តន័យ ប្រព័ន្ធអត្តន័យ ។ តើបញ្ហាឈឺចាប់ហ្នឹង វាអាចនៅមានឬក៏បាត់ វាអាស្រ័យទៅលើជនរងគ្រោះ ផ្តល់នៅអត្តន័យចំពោះអ្វីដែលបានកើតឡើងចំពោះគាត់ ។

ទីបី ខ្ញុំចង់និយាយថា *នីដ (Need)* តម្រូវការរបស់គាត់ តើជនរងគ្រោះចង់បានអ្វី? ទីមួយ គឺទាក់ទងទៅនឹងសុវត្ថិភាព ជីវភាពរស់នៅ ប្រសិនបើគាត់នៅតែមានបញ្ហាអ៊ីចឹង គឺគាត់នៅតែនឹកឃើញនូវការលំបាក គាត់នៅតែនឹកឃើញជីវភាពរស់នៅល្អ គាត់នៅតែនឹកឃើញបងប្អូនដែលស្លាប់ទៅ ។ បើកុំតែបងប្អូនស្លាប់ជីវភាពគាត់មិនលំបាក ។ អ៊ីចឹង នៅតែបញ្ហាហ្នឹងវានៅតែបន្តឲ្យគាត់ ។

ទីពីរ ទាក់ទងទៅនឹងយុត្តិធម៌ ។ យុត្តិធម៌ បើសិនជាផ្តល់យុត្តិធម៌បាន ផ្តល់ការពិតបាន ខ្ញុំជឿថា បងប្អូនដែលជាដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលស្គាល់ និងមានឱកាសក្នុងការផ្តល់នូវការអភ័យទោស ដែលការអភ័យទោសនេះទៀត គឺជាគន្លឹះមួយសំខាន់ដើម្បីបើកផ្លូវឲ្យមានការជាសះស្បើយនៅក្នុងចិត្តរបស់គាត់ ។ ប្រសិនបើការភ័យទោសនឹងមិនកើតមានទេ ការឈឺចាប់នៅតែមាននៅក្នុងខ្លួនដដែល ។ ដែលនេះ គឺជាកត្តាមួយដែលរាំងស្ទះទៅដល់ការផ្សះផ្សាជាតិកម្ពុជានៅថ្ងៃមុខ ។

ដូច្នេះ វាអាស្រ័យទៅលើភាពស្មោះស្ម័គ្ររបស់បុគ្គលទាំងសងខាង ទាំងជនជាប់ចោទ ទាំងដើមបណ្តឹង ទាំងយើងទាំងអស់គ្នា ដើម្បីធ្វើយ៉ាងណាដើម្បីឲ្យបានការពិតកើតមានឡើង ដែលឲ្យជនរងគ្រោះហ្នឹងអាចទទួលយកបាន ។ សូមអរគុណ ។

[១០:៣១:០៨]

**ស៖** ខ្ញុំមានពីរសំណួរទៀតទាក់ទងទៅនឹងការប្រឈមមុខដែលកើតមានឡើងនៅទីនេះ នៅក្នុងអង្គជំនុំជម្រះរវាងជនរងគ្រោះហើយនិងជនជាប់ចោទនោះ ។ តើលោកអាចជម្រាបយើងបានទេថា តើជនជាប់ចោទ តាមរយៈការបញ្ជាក់នៅក្នុងសេចក្តីថ្លែងរបស់គាត់ តើគាត់បានបញ្ជាក់ជូនជនរងគ្រោះថា គាត់ក៏រងគ្រោះដែរ ពីផ្លូវស្ថានភាពចិត្តគំនិតរបស់គាត់ ផ្លូវចិត្តរបស់គាត់នោះ គឺធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីយល់ច្រឡំថា ពីបំផុតនោះគឺថាអ្នកពេជ្ឈឃាដនោះក៏ជាជនរងគ្រោះដែរ ហើយជនរងគ្រោះ ក៏ថាអាចនឹងក៏ជាអ្នកធ្វើឃាតគេ បើខ្លួនមិនធ្វើឃាតទៅលើអ្នកដទៃ តើលោកយល់ដូចម្តេចអំពីវដ្តនៃគំនិតបែបនេះ?

**ឆ៖** បាទ, សូមអរគុណចំពោះសំណួរដែលជាសំណួរសំខាន់ ។ អង្គការធីភីអូ យើងខ្ញុំបានបង្កើតសេវាមួយនៅឆ្នាំ២០០៣, ២០០៤, ២០០៥ ដើម្បីជួយជនរងគ្រោះនិងជនជាប់ចោទនៅក្នុងគុកទួលស្លែង។

នៅពេលនោះយើងបង្កើតសេវាមួយចំនួន សេវាផ្តល់ប្រឹក្សា និងការព្យាបាលផ្លូវចិត្តចំពោះអ្នកយាមគុកទួលស្លែងមួយចំនួន ហើយយើងឃើញថា បើយើងមើលពីប្រវត្តិពីអតីតកាល ខ្ញុំបាទគិតឃើញថា ពួកខ្មែរក្រហមបានចាប់គាត់ឲ្យធ្វើជាទាហានតាំងពីគាត់អាយុ១២, ១៣ឆ្នាំ ។ ដូច្នេះ ករណីទាំងអស់

ហ្នឹង ១២, ១៣ឆ្នាំ គឺគាត់ក្នុងវ័យមួយ ដែលចង់នៅជាមួយគ្រួសារ ប៉ុន្តែពួកខ្មែរក្រហមបានចាប់ពង្រត់ពួកគាត់ឲ្យទៅធ្វើជាទាហាន ដើម្បីច្បាំង ។ ប៉ុន្តែ ជនរងគ្រោះមួយចំនួន បានធ្វើជាអ្នកទោស ធ្វើជាអ្នកយាម ដើម្បីធ្វើបាប ធ្វើទារុណកម្ម ។ មួយចំនួនទៀត ក៏ត្រូវបានគេធ្វើទារុណកម្ម រហូតដល់ដាក់គុកខ្លួនឯងទៀត ។

ដូច្នេះ បើយើងមើលករណីនេះ យើងហាក់ដូចជាឃើញថាគាត់ពីមុនហាក់ដូចជាជនរងគ្រោះ ។ ប៉ុន្តែ ក្រោយឡើងគាត់ក្លាយទៅជាជនដៃដល់ ។ ដូច្នេះ វាមានវដ្តមួយ វដ្តនៃអំពើហិង្សា ជនរងគ្រោះ ជនរងគ្រោះក្លាយទៅជាជនដៃដល់ នៅពេលដែលជនរងគ្រោះក្លាយទៅជាជនដៃដល់ ហើយជនដៃដល់ធ្វើទារុណកម្ម ធ្វើអំពើរំលោភអី គាត់ក្លាយទៅជាជនរងគ្រោះ ។ ដូច្នេះ វាហាក់ដូចជាវដ្តមួយដ៏ស្មុគស្មាញដែលមានការលំបាក ។ ខ្ញុំបាទយល់ ហើយក៏សូមអភ័យទោសចំពោះដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងមកថា ពួកគាត់ជាជនជាប់ចោទ ប៉ុន្តែ ប្រសិនបើយើងមើលទៅអតីតកាលបន្តិច យើងគិតថាយើងនឹងអាចយល់បាន ។ អ៊ីចឹង ប្រសិនបើយើងព្យាយាមយល់អំពីបញ្ហាហ្នឹង ប្រហែលជាអាចមានការផ្លាស់ប្តូរនូវទស្សនៈវិស័យរបស់យើងខ្លះ ។ មានអ្នកចិត្តវិទ្យាមួយ ដែលគាត់បានលើកឡើងថា ជនរងគ្រោះ ថ្ងៃនេះភាគច្រើនគឺ-- ជនដៃដល់ថ្ងៃនេះ ភាគច្រើនគឺជាជនរងគ្រោះពីថ្ងៃម្សិលមិញ ។ អ៊ីចឹង មានន័យថាវាជាវដ្តមួយដែលធ្វើឲ្យគាត់ឆ្លងពីជនរងគ្រោះទៅជាជនដៃដល់ ដៃដល់មកជាជនរងគ្រោះ ។

ខ្ញុំបាទមិនបាននិយាយទៅមេដឹកនាំថ្នាក់កំពូលទេ ។ ដូច្នេះ ខ្ញុំបានទុកចម្លើយនៅត្រឹមមេដឹកនាំថ្នាក់ក្រោម ។

[១០:៣៥:២៨]

**ស៖** សូមអរគុណលោកបណ្ឌិត ។ ខ្ញុំមានសំណួរចុងក្រោយមួយ គឺជាសំណួរមកពីជនបរទេសម្នាក់ដែលមិនមែនជាពុទ្ធសាសនាទេ ។ គាត់បាននិយាយជាមួយយើង អំពីការផ្ទុយគ្នារវាងការឈឺចាប់រវាងខ្លួនឯងនិងកម្មផល ហើយគាត់ក៏បានបញ្ជាក់ផងដែរ អំពីការផ្ទុយគ្នារវាងយុត្តិធម៌នៃមនុស្សលោកហើយនិងយុត្តិធម៌ផ្លូវពុទ្ធសាសនា ។ តើលោកអាចបំភ្លឺបន្តិចបានទេ អំពីតាមគោលការណ៍នៃចិត្តសាស្ត្រ ឬក៏ជំងឺផ្លូវចិត្ត ថាតើអ្វីជាកត្តាសំខាន់ចម្បងនៅក្នុងប្រទេសមួយដែលជាពោរពេញដោយពុទ្ធសាសនិកជន ហើយបើសិនជាជនរងគ្រោះមិនអាចចូលរួម ឬក៏មិនប៉ានចូលរួមក្នុងដំណើរការស្វែងរកយុត្តធម៌ ពីព្រោះថា នេះជាដំណើរការក្នុងផ្លូវលោក មិនមែនផ្លូវធម៌? បើសិនជាគាត់ពឹងផ្អែកទៅលើវប្បធម៌មួយផ្សេង តើវាអាចនឹងផ្តល់ផលដូចម្តេចដែរ?

**ឆ៖** ខ្ញុំបាទគិតថា ប្រជាជនកម្ពុជាភាគច្រើនដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ព្រះពុទ្ធសាសនាអប់រំមនុស្សអំពីកម្ម អំពីផល អំពីបាប អំពីបុណ្យ អំពីការមិនសងសឹក អំពីការអត់ឱន ។ ដូច្នេះ វាជាកត្តាមួយដែលធ្វើឲ្យជនរងគ្រោះអាចប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីពន្យល់នូវរឿងរ៉ាវ នូវអ្វីដែលបានកើតឡើងចំពោះគាត់ ។ ប៉ុន្តែ យើងក៏ត្រូវតែឲ្យមានការថ្លឹងថ្លែងគ្នាដែរ អំពីខាងផ្នែកផ្លូវលោក ហើយនិងផ្លូវធម៌ ។ ខ្ញុំគិតថា ប្រសិនបើខាងផ្នែកផ្លូវលោក ការស្វែងរកការពិត ការស្វែងរកយុត្តិធម៌ ប្រព្រឹត្តទៅបានល្អ ការនិយាយការពិត ភស្តុតាងដែលបង្ហាញហ្នឹងវាសមស្របក្នុងការទទួលយកបាន ។

ចំពោះពុទ្ធសាសនិកជនកម្ពុជាដែលកាន់ពុទ្ធសាសនា ខ្ញុំជឿថា គាត់មិនមែនរហូតដល់មានចិត្តថាមិនអត់ឱនចំពោះអ្វីដែលកើតឡើងទេ ។ ពីព្រោះតាមបែបព្រះពុទ្ធសាសនា តាមបែបជំនឿ គឺវាអប់រំឲ្យគាត់ហ្នឹងផ្តល់នៅការអត់ឱន រស់នៅក្នុងសេចក្តីសុខ ការគោរព ការស្រឡាញ់ យល់ដឹងពីបុណ្យបាប និងកម្មផល ។ ដូច្នេះ គឺវា ខ្ញុំបាទ គិតថា វាជាការទាក់ទងគ្នា អំពីបញ្ហាផ្លូវលោក ហើយនិងបញ្ហាពុទ្ធចក្រ ។

ចំពោះការបំបែកទៅសាសនាផ្សេងទៀត ការយកសាសនាផ្សេងទៀតជាការដើម្បីពន្យល់អំពីអ្វីដែលកើតឡើងហ្នឹង ខ្ញុំបាទគិតថាវាអាស្រ័យទៅលើការយល់ដឹងរបស់បុគ្គល អាស្រ័យទៅលើអត្ថន័យដែលគាត់យល់ ប្រសិនបើគាត់យកនៅការពន្យល់តាមបែបសាសនាផ្សេងទៀត សម្រាប់មកដោះស្រាយពីបញ្ហាគាត់បើគាត់យល់ គាត់គិតថានេះជាអត្ថន័យសំខាន់សម្រាប់គាត់ ខ្ញុំគិតថាអាហ្នឹងគឺជារឿងរបស់គាត់ ។ សូមអរគុណ ។

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្បាឯល៖**

សូមអរគុណលោកអ្នកជំនាញ ។ សូមលោកប្រធានជ្រាប ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំពីរនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ ។ ហើយមន្ត្រីតុលាការរៀបចំផ្តល់នៅកន្លែងសម្រាកសមរម្យ សម្រាប់អ្នកជំនាញរូបនេះ ហើយនិងអញ្ជើញគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងបានកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៤០នាទី ដល់ម៉ោង ១១:០៥នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ដើម្បីឲ្យមានឱកាសក្នុងការសាកសួរដល់សាក្សីដែលជាអ្នកជំនាញរូបនេះ ។ ហើយបញ្ជាក់ថាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាសាមសិបនាទីក្នុងការសួរ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយ លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំបាទក៏សូមគោរពលោកប្រធាន លោកស្រី លោកចៅក្រមអង្គសវនាការនៃអ.វ.ត.ក ជាទីគោរព ។ ខ្ញុំបាទ មេធាវី ហុង គឹមសួន ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ក្រុមទីមួយ ទីពីរ ទីបី ទីបួន ។ មានន័យថា ខ្ញុំបាទតំណាងនៅក្នុងពេលនេះ ធ្វើការតាំងសំណួរទៅលោកវេជ្ជបណ្ឌិត ដោយបន្ទាប់ពីខ្ញុំបាទ និងមានលោកមេធាវីអន្តរជាតិម្នាក់ទៀត ។ ហើយខ្ញុំបាទក៏សូមអនុញ្ញាតពីលោកប្រធានផងដែរ ប្រសិនជាមានពេលវេលាដែលត្រូវបន្ថែមបន្តិចបន្តួចសូមលោកប្រធានអនុញ្ញាតថែមផង ។

[១១:០៦:០៣]

**ស៖** តទៅនេះខ្ញុំបាទសូមជម្រាបសួរទៅលោកវេជ្ជបណ្ឌិត ។ សំណួរដំបូង ខ្ញុំបាទសូមសួរថាតាមការរៀបរាប់របស់លោកទាក់ទងនឹងការឈឺចាប់ ឬហៅថា វិបត្តិផ្លូវចិត្តដែលអង់គ្លេសហៅថា *"ត្រូម៉ា"* នោះ តើការឈឺចាប់របស់ជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយដែលក្នុងសំណុំរឿងនេះទាក់ទងនឹងមន្ទីរស-២១ ដែលសព្វថ្ងៃយើងហៅថា សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

សំណួរថាតើការឈឺចាប់របស់ជនរងគ្រោះសល់ពីរបបនោះ ប្រភេទនៃការឈឺចាប់ដូចលោកវេជ្ជបណ្ឌិតរៀបរាប់មកប្រាំមួយដែលខ្ញុំបានកត់ទុកនេះ ។ ប្រភេទណាដែលធ្វើការឈឺនោះវានៅតែឈឺចាប់ ហើយឮឡើងនៅតែឈឺខ្លាំងជាងដើមទៅទៀត?

**ឆ៖** បាទ,សូមអរគុណ ។ ចំពោះការឈឺចាប់ដែលបងប្អូនជាជនរងគ្រោះនៅក្នុងស-២១ បានហ្នឹង ខ្ញុំបាទមិនអាចបញ្ជាក់ថា ការឈឺចាប់ណាដែលរឹតតែខ្លាំងជាងគេទេ ។ ប៉ុន្តែ គ្រាន់តែថា បញ្ជាក់ថាជាទូទៅថា បងប្អូននៅតែមានការឈឺចាប់។ បងប្អូននៅតែនឹកឃើញនូវរឿងរ៉ាវដែលកើតមាន។ បងប្អូនតែងតែមានការយល់សុបិនអាក្រក់ ។ បងប្អូនតែងតែនៅមានការធ្លាក់ទឹកចិត្ត តែងតែងមានការលំបាក

ហើយការលំបាកទាំងអស់នេះហើយដែលវាជាកត្តាមួយដែលធ្វើឲ្យគាត់ហ្នឹងវាមិនងាយនៅក្នុងការជាសះស្បើយ ។ ហើយការលំបាកផ្សេងទៀតវាអាចទាក់ទងនឹងជំងឺហ្នឹងផង ហើយវាអាចទាក់ទងទៅនឹងដោយសារការជំងឺហ្នឹង ដោយសារការលំបាកហ្នឹងវាធ្វើឲ្យគាត់ហ្នឹងមិនអាចនឹងប្រកបរបស់ចិញ្ចឹមជីវិតដែលធ្វើឲ្យគាត់ហ្នឹងមិនធ្វើសកម្មភាពផ្សេងៗដោយសេរី ដែលធ្វើឲ្យគាត់មានការលំបាកនៅក្នុងការគ្រប់គ្រងគ្រួសារ ហើយទាំងអស់នេះវាជាការលំបាកជាទូទៅដែលយើងឃើញថា ជនរងគ្រោះហ្នឹងនៅបន្តមាន ។

[១១:០៨:៣៦]

**ស៖** បាទសូមអរគុណ ។ ទាក់ទងនឹងមន្ទីរស-២១ ឬក៏សព្វថ្ងៃយើងហៅថា សារមន្ទីរបទប្រល័យពូជសាសន៍ទួលស្លែងដដែលនេះ ភាគច្រើនជនរងគ្រោះជាសាច់ឈាមរបស់អ្នកដែលបានត្រូវគេសម្លាប់នៅក្នុងមន្ទីរស-២១ ឬក្រៅមន្ទីរស-២១ ។ តើហេតុផលភាគច្រើនយ៉ាងម៉េច ដែលមនុស្សឬក៏ជនរងគ្រោះគាត់នៅតែចង់ដឹងថា កន្លែងដែលបងប្អូន ឬសាច់ឈាមគាត់ស្លាប់នៅកន្លែងណា? កន្លែងនេះសូមលោកវេជ្ជបណ្ឌិតបញ្ជាក់ថា ការចង់ដឹងចង់ឮកន្លែងហ្នឹងវាហេតុផលទាក់ទងនឹងផ្លូវចិត្តយ៉ាងម៉េច?

**ឆ៖** បាទ,សូមអរគុណចំពោះសំណួរនេះ។ គឺថា ខ្ញុំបាទសូមបញ្ជាក់ថាទីមួយខ្ញុំចង់សំដៅទៅលើសង្គមគ្រួសារកម្ពុជាម្តងទៀត ។ សង្គមគ្រួសារកម្ពុជា គឺជាសង្គមគ្រួសារដែលបងប្អូនរស់នៅជាមួយគ្នាអ៊ីចឹងវាមានដូចថា ទំនាក់ទំនងខាងផ្នែកផ្លូវអារម្មណ៍ ផ្លូវចិត្តហ្នឹងវាមានខ្លាំង វាមានច្រើន ។ ហើយទំនាក់ទំនងនេះហើយ ដែលធ្វើឲ្យដោយមានការជិតស្និតរវាងអាចជាជនរងគ្រោះជាមួយនឹងអ្នកដែលបានស្លាប់ទៅ ។ ហើយចួនកាលខ្ញុំអាចគិតបានថា អ្នកស្លាប់ទៅនឹងគឺជាអ្នកដែលអាចមានគុណសម្បត្តិ ឬគុណស្រ័យអ្វីមួយសម្រាប់គាត់ ជាអ្នកសាច់ឈាមដែលសំខាន់នៅក្នុងគ្រួសារគាត់ ។ អ៊ីចឹង ការប៉ះពាល់ការស្លាប់ដល់-- ការស្លាប់របស់បងប្អូនគាត់ហ្នឹង ទុក្ខព្រួយរបស់បងប្អូនគាត់គឺជាទុក្ខព្រួយរបស់គាត់ដែរ ។

នៅក្នុងទ្រឹស្តី ខ្ញុំបាទសូមបញ្ជាក់មួយទៀតថា គឺថា*សិខិនដារី ត្រូម៉ាថាយសេសិន* (Secondary Traumatization) គឺជាការប៉ះពាល់ទង្គិចផ្លូវចិត្ត ។ ទោះបីជាការប៉ះទង្គិចផ្លូវចិត្តហ្នឹង អ្នកហ្នឹងមិនបានរងនូវបញ្ហាផ្លូវចិត្ត មិនរងនូវទារុណកម្មដោយផ្ទាល់មែន ប៉ុន្តែដោយសារការភាពជិតស្និតទំនាក់ទំនងជិតស្និទ្ធរវាងគាត់និងអ្នកដែលបានស្លាប់ទៅហ្នឹងហើយដែលជាកត្តាមួយដែលនាំឲ្យមាន *សិខិនដារី ត្រូម៉ាថាយសេសិន* ជាការឮនូវទារុណកម្ម ជាការស្តាប់ឮ ជាការមើលឃើញ ជាបញ្ហាអ្វីផ្សេងទៀតដែលទាក់ទងទៅនឹងអ្នកដែលគាត់ស្លាប់ទៅហ្នឹងហើយ ដែលធ្វើឲ្យគាត់ហ្នឹងរងនូវបញ្ហាឈឺចាប់ស្រដៀង ឬក៏

របៀបដែលៗបងប្អូនឬក៏ជនរងគ្រោះនុ៎ងដែលបានទទួលដែរ អាហ្នឹងគឺជាបញ្ហា ។

[១១:១១:៣៤]

**ស៖** សូមអរគុណ ។ សំណួរបន្តទៅទៀត ទាក់ទងជាមួយនឹងភាពជាអ្នកទទួលខុសត្រូវ ឬក៏អ្នកដឹកនាំ ហើយក្នុងនេះគឺខ្ញុំសំដៅទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ឬរបបដែលយើងហៅសាមញ្ញថាពួកខ្មែរក្រហម ។ មានការឆ្លើយនៅក្នុងសវនាការពីមុនមកហើយថា ជាពិសេសគឺខាងលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ជនជាប់ចោទគាត់ឆ្លើយមកអំពីអង្គការ ឬថ្នាក់លើ ឬអចិន្ត្រៃយ៍បក្សដែលជាអ្នកបង្គាប់បញ្ជា ។ ប៉ុន្តែ សំណួរដែលខ្ញុំចង់សួរទាក់ទងថា ការបង្កើតរបបមួយគឺជាមនុស្សបង្កើតទោះរបបកុម្មុយនីស្តក៏ដោយ របបសេរីក៏ដោយមនុស្សចេះដឹងភាគច្រើននាំគ្នាបង្កើត ។ ការបង្កើតរបបមួយដែលមានគោលការណ៍សម្លាប់មនុស្សចោល និងការបង្កើតរបបមួយមិនយកមនុស្សទៅសម្លាប់ចោលដោយគ្មានការកាត់ទោស ។ តើទស្សនៈរបស់របបមួយគឺជាពិសេស គឺរបបកម្ពុជាប្រជាធិបតេយ្យដែលយកគំនិតសម្លាប់មនុស្សចោលហ្នឹង លោកគិតថាជាគំនិតត្រឹមត្រូវរបស់គេនៃការបង្កើតរបបមួយខុសពីបុព្វ-កាល និងជឿនលឿន សម័យជឿនលឿនដែរឬទេ?

**ឆ៖** ខ្ញុំបាទអាចឆ្លើយបានថា ទីមួយ ខ្ញុំបាទមិនមែនជាជំនាញនៅក្នុងការវិភាគនៅក្នុងបញ្ហាហ្នឹងទេ ពីព្រោះខ្ញុំបាទគិតបន្តិចថាវាជាខុសចាកពីជំនាញអ្វីដែលខ្ញុំមាន ។ ប៉ុន្តែ ខ្ញុំបាទគិតថា ការដែលរបបខ្មែរក្រហមធ្វើហ្នឹងគឺជាការដែលមិនត្រូវត្រូវទាល់តែសោះបាទ ។

**ស៖** សូមអរគុណ ។ ការសម្លាប់មនុស្សនៅក្នុងរបប ប៉ុល ពត បន្សល់ទុកនូវភាពឈឺចាប់របស់ជនរងគ្រោះមកដល់សម័យនេះ ដូចលោករៀបរាប់ហើយ ។ សំណួរខ្ញុំសួរថា ការឆ្លើយរបស់អ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ ឬអ្នកទទួលខុសត្រូវឆ្លើយមិនដឹង អ្នកណាបង្កើតគំនិតសម្លាប់ ឬរឹតតែធ្វើឲ្យជនរងគ្រោះឈឺចាប់ទៀត ឬក៏ជនរងគ្រោះបានធូរស្រាល មិនសំដៅទៅអ្នកនោះ?

**ឆ៖** បាទ, ដូចខ្ញុំបានជម្រាបជូនពីមុនៗមកហើយថា ការជាសះស្បើយបញ្ហាផ្លូវចិត្តនៃជនរងគ្រោះពីសម័យខ្មែរក្រហមនុ៎ង វាអាស្រ័យទៅលើភាពស្មោះត្រង់ដែលជនជាប់ចោទ មេដឹកនាំ អតីតមេដឹកនាំខ្មែរក្រហមហ្នឹងបានបញ្ចេញ ។ យើងទាំងអស់គ្នាគឺដឹងគ្រប់ៗគ្នាហើយថា អ្នកណាជាអ្នកទទួលខុសត្រូវក្នុងការសម្លាប់រង្គាល ។ ដូច្នេះ កាលដែលគាត់ប្រកែក ដែលគាត់ដូចជាបង្ហាញអាកប្បកិរិយាមិនទទួលខុសត្រូវ ខ្ញុំគិតថា គឺជាទម្ងន់មួយថែមទៀតដែលបន្ទុកទៅលើជនរងគ្រោះយើងទាំងអស់ មិនគ្រាន់តែដើមបណ្តឹងរដ្ឋប្បវេណីទេ គឺប្រជាជនកម្ពុជាទូទាំងប្រទេសហ្នឹង មានការមិនសប្បាយចិត្ត និង

មានការខឹងចំពោះការប្រកែកដោះសាយករួចខ្លួននេះ ។

[១១:១៥:២២]

**ស៖** សូមអរគុណ ។ ដូច្នេះសំណួរដែលទាក់ទងគ្នា គឺសួរទៅលើវេជ្ជបណ្ឌិតថា ប្រជាពលរដ្ឋទោះជាអ្នករងគ្រោះសល់ពីរបបខ្មែរក្រហមក៏ដោយ និងជាកូនចៅដែលទើបនឹងកើតឡើងនៅក្នុង ក្រោយរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយដែលគាត់បានដឹងឮ ហើយគាត់នៅមានអារម្មណ៍ឈឺចាប់បន្តគ្នានោះ។ តើការចូលរួមនីតិវិធីសវនាការនៅទីនេះ ឬក៏ការតាមដានមើលអាចជួយរំលួស ឬក៏ជួយបន្ធូរការឈឺចាប់គាត់ដែរឬទេ?

**ឆ៖** បាទ, ចំពោះពួកគាត់ការតាមដានវាអាចមានផលពីរ ដូចខ្ញុំបាទបានលើកឡើងពីមុនមក ។ ការតាមដាន ការស្តាប់ឮហ្នឹងវាអាចធ្វើឲ្យការអារម្មណ៍ បញ្ហាអតីតកាលហ្នឹងបានកើតមាន ធ្វើឲ្យគាត់ហ្នឹងចាប់ផ្តើមសុបិនអាក្រក់ហ្នឹងឡើងវិញ ធ្វើឲ្យគាត់ហ្នឹងអាចមានអារម្មណ៍ខឹងមួរម៉ៅដោយមិនដឹងខ្លួន ធ្វើឲ្យគាត់នឹងអាចមានការពិបាកក្នុងការផ្តោតអារម្មណ៍ ។ ប៉ុន្តែក៏វាអាចជួយដែរ ប្រសិនបើពួកគាត់អាចមកបញ្ចេញ មកបង្ហាញពីអំពីទស្សនៈ អំពីការពិត អំពីការផលពិបាកដើម្បីដែលគាត់អាច-- ដែលគាត់បានទទួលបានរងកម្មហ្នឹងក៏វាអាចជួយមួយកម្រិតដែរ ។ ប៉ុន្តែ ខ្ញុំបាទមិនទាន់ប៊ាននថាវាហ្នឹងនាំឲ្យជួយទាំងស្រុងក្នុងការជម្រះ ឬក៏បញ្ចប់នូវបញ្ហាផ្លូវចិត្តរបស់គាត់ទេ ។

[១១:១៦:៥៩]

**ស៖** សូមអរគុណ ។ សំណួរបន្តទៅទៀតសូមសួរលោកវេជ្ជបណ្ឌិតថា ជនរងគ្រោះ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអង្គជំនុំជម្រះវិសាសមញ្ញក្នុងតុលាការកម្ពុជានេះ គាត់បានដឹងអំពីបំណង ហើយគាត់ក៏បានដាក់ពាក្យ និងសរសេរអំពីពាក្យថា "ស្វែងរកយុត្តិធម៌ដល់ខ្លួនគាត់ ឬដល់បងប្អូនសាច់ឈាមគាត់ដែលបានស្លាប់ និងស្វែងរកការពិត" ។ តើដើម្បីជាការឲ្យអស់ចិត្ត ឬយើងនិយាយថា ឲ្យបាត់ទៅវិញនៅការឈឺចាប់ផ្លូវចិត្តរបស់គាត់នោះ តាមលោកវេជ្ជបណ្ឌិតមានបទពិសោធន៍ ថាមានអ្វីលើសពីនោះទៀតទេ ដើម្បីឲ្យប្រជាពលរដ្ឋដែលជាជនរងគ្រោះពីរបបខ្មែរក្រហមគាត់បានធូរស្បើយ កាន់តែច្រើនលើសពីបំណងពីរនេះទៀត?

**ឆ៖** ការដឹងការពិត ការទទួលបានយុត្តិធម៌ដ៏ត្រឹមត្រូវ ការសូមអភ័យទោស ទាំងអស់នេះគឺជាកត្តាសំខាន់មួយដើម្បីជួយឲ្យជនរងគ្រោះបានជាសះស្បើយ ។ ប៉ុន្តែ ជំងឺផ្លូវចិត្តដែលកើតមាន គឺចាំបាច់ត្រូវមានសេវាគ្រប់គ្រាន់សម្រាប់ជួយពួកគាត់ ដើម្បីដោះស្រាយ ដើម្បីព្យាបាលនូវជំងឺ ឬក៏បញ្ហាធ្ងន់ធ្ងរ

ទាំងនោះ ដែលគាត់កំពុងតែមានសព្វថ្ងៃ ។

យើងដឹងហើយថានៅប្រទេសកម្ពុជាយើងសព្វថ្ងៃសេវាសុខភាពផ្លូវចិត្តហ្នឹង គឺមានតិចតួចណាស់ អ្នកជំនាញខាងផ្នែកសុខភាពផ្លូវចិត្តមានតិចតួចណាស់ ។ ដូច្នេះ ការជួយរបស់គាត់ហ្នឹងទៅលើជនរងគ្រោះ ក៏មិនទាន់មានលក្ខណៈគ្រប់គ្រាន់ដែរ ។

ជាបន្ថែមទៀតខ្ញុំគិតថា សម័យខ្មែរក្រហមវាបានបំផ្លិចបំផ្លាញអ្វីៗសព្វបែបយ៉ាង។ វាធ្វើឲ្យគាត់បាត់បង់នូវអ្វីៗច្រើនណាស់ ។ បាត់បង់អ្នកជាទីស្រឡាញ់ បាត់បង់ឱកាស អ្នកខ្លះគិតថា ប្រសិនបើកុំមានខ្មែរក្រហមគាត់មិនមែនជាអ្នកធ្លាក់ខ្លួនមករៀន មិនមានចំណេះវិជ្ជា ។ អ៊ីចឹងបានន័យថា គាត់បាត់បង់ឱកាសរៀនសូត្រដើម្បីអាចធ្វើការទៅមានលក្ខណៈខ្ពង់ខ្ពស់ គាត់បាត់បង់នូវជីវភាព គាត់បាត់បង់នូវអត្តសញ្ញាណផ្ទាល់ខ្លួន គាត់បាត់បង់នូវជំនឿទុកចិត្តរបស់ខ្លួនគាត់ ។ អ៊ីចឹង ទាំងអស់ហ្នឹងងហើយដែលៗជាកត្តាមួយធ្ងន់ធ្ងរទៀត ដែលយើងធ្វើយ៉ាងណាជួយឲ្យគាត់ហ្នឹងដោះស្រាយបញ្ហាទាំងអស់ហ្នឹងដើម្បីឲ្យគាត់នឹងឈានទៅរកការជាសះស្បើយបន្ថែមទៅលើការពិត ឬក៏យុត្តិធម៌ផ្សេងៗទៀតបាទ ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកវេជ្ជបណ្ឌិត ។ ជាបន្តទៅទៀត ខ្ញុំសូមអនុញ្ញាតលោកប្រធានឲ្យខាងមេធាវីអន្តរជាតិបន្តសំណួរពីខ្ញុំបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ ។

[១១:២០:00]

**សួរដោយលោក អាឡាំង វែនណឺ៖**

**ស៖** សូមអរគុណលោកប្រធាន សូមសួស្តីលោកវេជ្ជបណ្ឌិត ។ ជាបឋមខ្ញុំសូមសម្តែងនូវអំណរអរគុណចំពោះការទទួលយករបស់លោកមកផ្តល់សក្ខីកម្មនៅទីនេះ ។ ខ្ញុំចង់សួរសំណួរទីមួយ ថាតើវាជាករណីដែរឬទេ ដែលថា លោកក៏ផ្តល់ប្រឹក្សាដោយផ្ទាល់ទៅដល់អ្នកដែលរស់រានមានជីវិតពីមន្ទីរស-២១ ផងដែរ?

**ឆ៖** បាទ, ពិតមែន ។

**ស៖** លោកវេជ្ជបណ្ឌិត ថាតើវាមានជំងឺជាក់លាក់ណាមួយដែរឬទេ ជាប់ពាក់ព័ន្ធទៅនឹងអ្នករស់រានមានជីវិតនៅមន្ទីរស-២១ តាមជំនាញ និងការយល់ដឹងរបស់លោក?

**ឆ៖** ខ្ញុំបាទសូមបែងចែកជំងឺនៅក្នុងកម្រិតពីរ ។ ទីមួយ ខ្ញុំបាទចង់និយាយអំពីជំងឺនៅក្នុងកម្រិត ផ្នែកផ្លូវចិត្ត ផ្នែកវេជ្ជសាស្ត្រ ដែលពួកទាំងអស់នោះ ជនរងគ្រោះយើងទាំងអស់នោះ គឺសុទ្ធតែរងនូវជំងឺ ផ្លូវចិត្តផ្សេងៗដូចជា ជំងឺ *ប៉ុស្តត្រូម៉ាទិច ស្រ្តេស ឌីហ្សតឌ័រ* ឬ *ភីធីអេសឌី* នៅតាមបែបលោកខាងលិច ជំងឺធ្លាក់ទឹកចិត្ត ជំងឺថប់បារម្ភ ជំងឺឈឺចាប់ខាងរាងកាយ ជំងឺគេហៅ ចិត្តកាយវិបល្លាសនុំង ឬក៏អាច មានជំងឺទូទៅផ្សេងៗទៀត ដូចជា ជំងឺលើសឈាម ជំងឺឈឺចាប់រ៉ាំរ៉ៃ ជំងឺទឹកនោមផ្អែម ដែលទាក់ទង ទៅនឹងការធ្វើបាបទាំងអស់នោះ ។ ប៉ុន្តែ ក៏ខ្ញុំសូមបញ្ជាក់ដែរថា អានុំងវាជាផ្នែកជំងឺ ប៉ុន្តែវាមានការ ប៉ះពាល់ផ្សេងទៀត ដែលខ្ញុំចង់លើកអំពីបញ្ហាបាក់ស្បាត ព្រោះមានការបកប្រែយើងថា *ប៉ុស្តត្រូម៉ាទិច ស្រ្តេស ឌីហ្សតឌ័រ* ឬ *ភីធីអេសឌី* ហ្នឹង គឺជាជំងឺបាក់ស្បាត ហើយបើយើងគិតឲ្យមែនទែនទៅវាមិនមាន លក្ខណៈដូចគ្នាទេ *ភីធីអេសឌី* វាមានលក្ខណៈទៅលើផ្នែកវេជ្ជសាស្ត្រច្រើន ។

ចំណែកអ្វីដែលខ្ញុំចង់និយាយ គឺបញ្ហាបាក់ស្បាត ដែលមានប៉ះពាល់ក្នុងផ្នែកវេជ្ជសាស្ត្រផង ដែល ប្រជាជនមានការឈឺ ចាប់សុបិន្តអាក្រក់ ឈឺចាប់អីផ្សេងៗ ប៉ុន្តែវាប៉ះពាល់ទៅនឹងបញ្ហាទូទៅ ។ ប្រសិន បើយើងសួរប្រជាជន យើងទូទាំងដែលសល់ពីរបបខ្មែរក្រហមម្នាក់ៗសុទ្ធតែបាននិយាយថា ពួកគេមាន ការបាក់ស្បាតពីបញ្ហាខ្មែរក្រហម ។ អ៊ីចឹង ការបាក់ស្បាតមួយម៉ាត់ហ្នឹងបានបង្ហាញនូវការភ័យខ្លាច ភ័យ រន្ធត់ ឈឺចាប់ ការចៀសវាង ការខឹងសម្បា ការគេចវេស ការមិនចង់ធ្វើអ្វីៗផ្សេងៗទៀត ដែលការមិន ទុកចិត្តគ្នាទៅវិញទៅមក ដែលទាំងអស់នេះប្រជាជនយើងសុទ្ធតែរង ហើយកម្រិតនេះដែលខ្ញុំអាចនិយាយ ថា ជាបញ្ហាបាក់ស្បាតមួយនៅក្នុងកម្រិតសង្គម ដែលប្រជាជនយើងទូទាំងប្រទេសក្តី ឬក៏ជនរងគ្រោះ នៅក្នុងគុកទួលស្លែងក្តី ដែលគាត់រងរហូតមកដល់សព្វថ្ងៃនេះ ។

ដូច្នេះ បញ្ហាវេជ្ជសាស្ត្រខាងផ្នែកផ្លូវចិត្តហ្នឹងមួយ ប៉ុន្តែបញ្ហាសង្គម បញ្ហាផ្លូវចិត្តដែលប៉ះពាល់នៅ ក្នុងកម្រិតសង្គម គឺជាបញ្ហាមួយទៀតដែលមានលក្ខណៈធ្ងន់ធ្ងរបាទ ។

[១១:២៤:០៩]

**ស៖** សូមអរគុណច្រើនលោកវេជ្ជបណ្ឌិត ។ នៅពេលនេះ ទាក់ទងទៅនឹងក្រុមទីពីរ គឺអ្នកដែល ជាញាតិលោហិត ញាតិពន្ធ ដែលជាប់ពាក់ព័ន្ធទៅនឹងអ្នករងគ្រោះនៅស-២១ ។ ដូចដែលលោកបានដឹង ហើយគឺស-២១ មានលក្ខណៈពិសេស ។ ហើយអ្នកជំនាញមួយ គឺបានលើកឡើងថា មិនមែនត្រឹមតែ មានលក្ខណៈជាមន្ទីរឃុំឃាំងធ្ងន់ធ្ងរនោះប៉ុណ្ណឹងទេ ហើយវាបានបំបាក់ស្មារតីទៅលើអ្នកជាប់ឃុំផងដែរ ហើយអ្នកជំនាញក៏បាននិយាយអំពីភាពសាហាវនៃការធ្វើទារុណកម្ម និងវិធីធ្វើទារុណកម្មនៅស-២១

ហើយវាមានលក្ខណៈផ្ទុយពីមន្ទីរសន្តិសុខផ្សេងៗ ។

ចំពោះញាតិលោហិតនិងញាតិពន្ធដែលជាប់នៅស-២១ តើលោកសង្កេតឃើញនូវរោគសញ្ញាជាក់លាក់ណាមួយ ដែលវាប៉ះពាល់ទៅដល់ក្រុមគ្រួសារដែលមានសមាជិកគ្រួសាររបស់គាត់ជាប់នៅមន្ទីរស-២១ នោះ ។

**ឆៈ** បាទ, សូមអរគុណ ។ សំណួរនេះក៏ស្រដៀងហ្នឹងលោកមេធាវីមុនដែរ គឺថាយើងសង្កេតឃើញថា វាមាន *ខន់សិប*(Concept) មួយដែលបញ្ជាក់ថា *សេខិនដេរី ត្រូម៉ាថាយហ្សេ*សិន (Secondary Traumatization) ។ នោះវាមានន័យថា ជនរងគ្រោះគាត់មិនបានជួបប្រទះនូវព្រឹត្តិការណ៍ហ្នឹងដោយផ្ទាល់ទេ ។ គឺគាត់គ្រាន់តែស្តាប់ឮ ឬក៏គាត់ គ្រាន់តែជាសាច់ញាតិ នៅពេលនោះគាត់អាចរងនូវបញ្ហាផ្លូវចិត្តនោះដែរ ។ ដូច្នេះ យើងបានសុទ្ធតែបាន ដឹងហើយថាមានការស្រាវជ្រាវនៅក្នុងប្រទេសលោកខាងលិចដែលបញ្ជាក់ថា កូនចៅជំនាន់ក្រោយរបស់ជនរងគ្រោះ គឺរងនូវប៉ះពាល់នូវបញ្ហាផ្លូវចិត្ត ។ អ៊ីចឹងយើងគិតថា ចំពោះករណីនេះ ជាកូនចៅ ជំនាន់ក្រោយក្តី ឬក៏ជាសាច់ញាតិក្តី ចង់មិនចង់ គឺត្រូវរងនូវបញ្ហាផ្លូវចិត្តដែរ ។

ខ្ញុំបាទលើកឧទាហរណ៍ថា ឪពុកម្តាយដែលគាត់មានបញ្ហាផ្លូវចិត្តដោយសារ ឧទាហរណ៍ អំពើទារុណកម្មក្នុងសម័យខ្មែរក្រហមហ្នឹង អ៊ីចឹងបញ្ហាផ្លូវចិត្តហ្នឹងវាអាចបង្ហាញចេញទៅដល់កូនចៅ កូនចៅអាចទទួលរងនូវការឈឺចាប់ ដោយឃើញនូវការឈឺចាប់របស់ឪពុកម្តាយ ។ កូនចៅត្រូវរងនូវការឈឺចាប់ដោយខំប្រឹងធ្វើការលើសកម្លាំង ដើម្បីធ្វើយ៉ាងណាជួយឪពុកម្តាយ ដើម្បីឲ្យឪពុកម្តាយបានធូរស្រាល។

ចំណុចមួយទៀត គឺថា ការគិត ការអាកប្បកិរិយារបស់ឪពុកម្តាយ ឬក៏ជនរងគ្រោះ វាអាចមានឥទ្ធិពលទៅលើការគិតរបស់កូនចៅ បងប្អូនរបស់ជនរងគ្រោះ ។ អ៊ីចឹងហើយអាលក្ខណៈហ្នឹង វាហាក់ដូចជាលក្ខណៈមួយឆ្លងនូវបញ្ហាផ្លូវចិត្ត ដែលកើតមានចំពោះជនរងគ្រោះទៅលើបងប្អូនរបស់គាត់ដែលដោយខ្ញុំបាននិយាយពីមុនថាជា *សេខិនដេរី ត្រូម៉ាថាយហ្សេសិន* ។ ហើយរឿងនេះ គឺជារឿងមួយដែលគេបានស្រាវជ្រាវបញ្ជាក់ថា ជាការពិតមែនបានកើតឡើង ។

[១១:២៧:៤៦]

**សៈ** សូមអរគុណលោកវេជ្ជបណ្ឌិត ។ កូនក្តីរបស់យើងខ្ញុំជាហូរហែនិយាយ និងសម្តែងនៅចំពោះមុខតុលាការអំពីភាពមានទោស ដែលថាពួកគាត់មិនអាចធ្វើការការពារអ្នកដែលជាសមាជិករបស់គាត់នៅពេលដែលគាត់ជាប់ឃុំនៅស-២១ ។ នៅពេលដែលលោកធ្វើការសង្កេត និងប្រឹក្សាទៅដល់ អ្នក

ទាំងអស់ដែលជាជនរងគ្រោះនោះថា តើលោកមានបានសង្កេតឃើញអំពីការសម្ដែងនូវអ្វីដែលគាត់ធ្វើការ ដែលបញ្ជាក់ថាគាត់មានកំហុស ដែលមិនបានការពារទៅលើសមាជិកគ្រួសាររបស់គាត់ដែរឬទេ?

**ឆៈ** បាទ, យើងឃើញមានសញ្ញាជាច្រើនដែលបង្ហាញហ្នឹង គឺថាសញ្ញាណនៃការសោកស្ដាយនូវ *ហ្គីល* (Guilt) ដែលពួកគាត់មាន គឺថាជាតាមទ្រឹស្ដីយើងឃើញថាជនដែលរងគ្រោះនូវអំពើទារុណកម្ម គឺគាត់ស្ថិតនៅក្នុងសភាពមួយដែលមានអារម្មណ៍ថា មិនអាចធ្វើអ្វីកើតដើម្បីកែប្រែស្ថានការណ៍ហ្នឹង ។ អ៊ីចឹងអារម្មណ៍ហ្នឹងហើយវាអាចគ្របដណ្ដប់ទៅលើគាត់ វាអាចធ្វើឲ្យគាត់នឹងមានសភាពគាំងកក ដែលគាត់ហ្នឹងមិនអាចធ្វើអ្វីៗដើម្បីកែប្រែស្ថានការណ៍ឲ្យបាន ។ ហើយយើងសង្កេតឃើញថា យើងឃើញមានអារម្មណ៍បែបនេះកើតមានទៅលើពួកគាត់ ពីព្រោះគាត់មានអារម្មណ៍ថាគាត់មិនអាចជួយបាន ។

ឧទាហរណ៍ ជនរងគ្រោះមួយ ដែលគាត់ជាប់ទារុណកម្មទាំងពីរនាក់ប្ដីប្រពន្ធ ហើយប្រពន្ធគាត់បានស្លាប់ ហើយអារម្មណ៍ហ្នឹងវាដក់ទៅលើគាត់ដែលគាត់មិនអាចធ្វើអ្វីដើម្បីជួយប្រពន្ធគាត់បាន ។

ដូច្នេះ គឺជាអារម្មណ៍មួយសោកសៅ ដែលគាត់មាននៅក្នុងចិត្តគាត់តាំងពីពេលនោះរហូតមកដល់ពេលសព្វថ្ងៃ រហូតដល់គាត់យល់សប្ដិឃើញប្រពន្ធត្រឡប់មកអំពាវនាវឲ្យគាត់ សុំឲ្យគាត់ជួយចំពោះគាត់ជាដើម ។

**សៈ** លោកវេជ្ជបណ្ឌិតសំណួរបានសួរលោករួចហើយ ប៉ុន្តែសុំឲ្យលោកបញ្ជាក់លម្អិតបន្តិចទាក់ទងទៅនឹងកូនក្ដីរបស់យើងគាត់ថា មិនមានលទ្ធភាព ដើម្បីសម្ដែងទុក្ខសោកចំពោះអ្នកដែលស្លាប់ដែលថាអ្នករងគ្រោះមិនត្រូវបានធ្វើពិធីបញ្ចុះអីត្រឹមត្រូវ ។ តើលោកអាចបញ្ជាក់ត្រឹមត្រូវបានទេ តើភាពតានតឹងនៃការឈឺចាប់នោះវាកម្រិតប៉ុនណា ដែលថានៅតែបន្តមានរហូតដល់ថ្ងៃនេះ ដែលថាគេមិនបានរៀបចំពិធីសម្ដែងទុក្ខសោក រំឭកខួបរបស់គេឲ្យបានត្រឹមត្រូវនោះ?

[១១:៣០:៥១]

**ឆៈ** ខ្ញុំបាទសូមបញ្ជាក់ថា មិនមានបងប្អូនយើងច្រើនប៉ុន្មានទេដែលបានធ្វើពិធីត្រឹមត្រូវតាមបែបព្រះពុទ្ធសាសនាក្ដី ឬក៏តាមបែបគ្រិស្តសាសនាក្ដីក្នុងការជួយដល់វិញ្ញាណក្ខន្ធបងប្អូនដែលបានស្លាប់ ។ ខ្ញុំជឿថាមានតិចណាស់ដែលបានដឹង ដែលបានគាស់សពបងប្អូនដែលស្លាប់ទៅ យកឆ្អឹងមកបូជាឲ្យបានត្រឹមត្រូវ ។

ដូច្នេះ វិធីទាំងអស់នេះ គឺជាស្ថិតនៅក្នុងលក្ខណៈមួយដែលខ្ញុំបាទជឿថាមិនទាន់បានកើតមាន ជាទូទៅនៅឡើយទេ ។ ជនរងគ្រោះជាច្រើនដែលជាអតិថិជនដែលខ្ញុំបានជួប គឺពួកគាត់មិនមានលទ្ធភាព

នៅក្នុងការធ្វើ ហើយណាមួយទៀតមិនដឹងថាតើបងប្អូននោះស្លាប់នៅកន្លែងណា? មិនដឹងថាបងប្អូននោះកប់នៅកន្លែងណា? មិនដឹងថាឆ្អឹងរបស់គាត់ ធាតុរបស់គាត់នៅកន្លែងណា?

ដូច្នេះ អាកត្តាទាំងអស់ហ្នឹងហើយ ដែលជាកត្តាមួយដែលពន្យារនូវការឈឺចាប់របស់គាត់ឲ្យកាន់តែមានឡើង ។ ដូចខ្ញុំបាទបាននិយាយហើយថា ពិធីព្រះពុទ្ធសាសនា ពិធីប្រពៃណីនេះ គឺជាវិធីមួយដើម្បីជួយឲ្យបងប្អូនយើងហ្នឹងបានបន្ធូរស្រាលពីការតានតឹងផ្លូវចិត្ត ។ ដើម្បីជួយឲ្យវិញ្ញាណក្ខន្ធរបស់អ្នកដែលស្លាប់ទៅបានរស់នៅក្នុងសេចក្តីស្ងៀមស្ងប់ ។ នៅពេលណាដែលវិញ្ញាណក្ខន្ធគាត់បានរស់នៅក្នុងភាពស្ងប់ស្ងាត់ គឺសុខភាពផ្លូវចិត្ត បញ្ហាផ្លូវចិត្តរបស់គាត់នឹងមានសភាពស្ងប់ស្ងាត់ដែរ ។ ប៉ុន្តែ មកដល់ពេលនេះខ្ញុំជឿថានៅមានបងប្អូនយើងតិចនៅឡើយដែលបានធ្វើបែបនេះ ។

**ស៖** លោកប្រធាន! ខ្ញុំមានសំណួរពីរទៀត ខ្ញុំសូមអនុញ្ញាតបន្ត ។ បាទ, សូមអរគុណ ។

លោកវេជ្ជបណ្ឌិត យើងជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី យើងមានការលំបាកណាស់ក្នុងការពន្យល់កូនក្តីរបស់យើង ដើម្បីឲ្យពួកគាត់មកនិយាយចំពោះមុខតុលាការនេះ ។ ទោះបីជានៅពេលចុងក្រោយក៏ដោយពួកគាត់មានអារម្មណ៍ថា គាត់មានការងាយរងគ្រោះដើម្បីសម្តែងនូវបញ្ហានេះ ។ កូនក្តីរបស់យើងចុងក្រោយគាត់មិនគិតថា គាត់អាចមកផ្តល់សក្ខីកម្មបានទេ ។ តើលោកអាចបញ្ជាក់ប្រាប់យើងខ្ញុំបានទេថា ថ្ងៃនេះមនុស្សភាគច្រើននៅតែមានអារម្មណ៍ថាមានការភ័យខ្លាច ថាពួកគេមិនមានលទ្ធភាពនឹងផ្តល់សក្ខីភាពមិនអាចប្រឈមមុខនៅចំពោះមុខការឈឺចាប់របស់គេក្នុងផ្លូវចិត្តនោះ ។ តើលោកអាចពន្យល់បានដូចម្តេច?

**ឆ៖** បាទ, មានកត្តាច្រើនដែលខ្ញុំអាចពន្យល់បាននៅក្នុងករណីនេះ ។

ទីមួយ គឺកត្តាឈឺចាប់ផ្លូវចិត្តដែលគាត់មិនបានដោះស្រាយហ្នឹង ។ នៅពេលដែលគាត់ដាក់ពាក្យបណ្តឹងដើម្បីមកធ្វើសក្ខីកម្មនេះ ។ បញ្ហានេះគឺជាបញ្ហាមួយធ្ងន់ហើយបងប្អូនដែលបានធ្វើ គឺជាទឹកចិត្តដ៏ក្លាហានដែលបងប្អូនបានធ្វើនោះ ។ ចំណែក បងប្អូនមួយចំនួនទៀតនៅតែមានការឈឺចាប់ ពីព្រោះវារំឭកឡើងវិញនូវការឈឺចាប់ទាំងឡាយជាច្រើន ដែលគាត់បានជួបពីអតីតកាល ។ បងប្អូនខ្លះក៏បាននិយាយហើយថា នៅពេលដែលគាត់ឡើង មកមើលនៅសវនាការគាត់បានឃើញជនជាប់ចោទ វាធ្វើឲ្យអារម្មណ៍គាត់ឈឺចាប់ អារម្មណ៍ឆ្លួលបានកើតមានឡើងចំពោះគាត់ឡើងវិញ ។ វាធ្វើឲ្យគាត់មានការពិបាកទ្រាំ វាធ្វើឲ្យគាត់នឹកឃើញឡើងវិញនូវអ្វីទាំងអស់ ។

ដូច្នេះ កត្តាទាំងអស់នេះ វាអាចជាកត្តាមួយដែលទប់ស្កាត់គាត់នៅក្នុងការឡើងមកបំភ្លឺជាសាក្សី

ដូច្នេះយើងសង្កេតឃើញថាបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរនៅតែកើតមានចំពោះគាត់ ។ យើងដឹងគ្រប់គ្នាហើយថា នៅក្នុងសម័យខ្មែរក្រហមមិនមែនជាសម័យមួយដែលធម្មតានៅក្នុងប្រវត្តិនៃប្រទេសកម្ពុជាទេ គឺជាសម័យ ដែលបំផ្លាញខ្ទេចខ្ទីដល់ឫសគល់ពីក្នុងផ្លូវពុទ្ធចក្រ និងអាណាចក្រ រចនាសម្ព័ន្ធផ្សេងៗគ្រប់បែបយ៉ាង ទាំងអស់ ដែលពួកខ្មែរក្រហមត្រូវបំផ្លិចបំផ្លាញ រាប់បញ្ចូលទាំងទារុណកម្មដល់មនុស្សក្នុងកម្រិតបុគ្គល រហូតដល់កម្រិតសហគមន៍ ។ ទាំងនេះគឺវាប៉ះធ្ងន់ធ្ងរទៅដល់ការរស់នៅ ដែលអារម្មណ៍របស់ប្រជាជន ថាមិនមានសុវត្ថិភាពនិងសន្តិសុខផ្ទាល់ខ្លួនរបស់គាត់ ។ ដែលវាប៉ះពាល់ដោយអារម្មណ៍ហ្នឹង គាត់នៅតែ មាន ដូចនេះគាត់នៅតែមានអារម្មណ៍ខ្លាចចំពោះការដែលគាត់ធ្វើអ្វីមួយដែលអាចនឹងមានគ្រោះថ្នាក់ចំពោះ ខ្លួនគាត់ទៀត ។

ករណីមួយទៀតយើងដឹងហើយថា ចំណុចមួយនៅក្នុងសម័យខ្មែរក្រហមដែលវាបង្ហាត់មនុស្ស មិនឲ្យទុកចិត្តគ្នា បង្ហាត់មនុស្សឲ្យតាមដានគ្នាទៅវិញទៅមក អ៊ីចឹងវាបង្កើតឲ្យមានប្រព័ន្ធមួយដែលៗធ្វើ ឲ្យមនុស្សមិនទុកចិត្តគ្នា ។ អ៊ីចឹង ការមិនទុកចិត្តនេះនឹងកើតមានបន្តរហូតដល់ប្រជាជនកម្ពុជាសព្វថ្ងៃ គឺ ម្នាក់ៗមិនសូវទុកចិត្តចំពោះបញ្ហាទេ ដូចបងប្អូនដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលខ្ញុំបានជួប គាត់ បាននិយាយថាគាត់មិនទុកចិត្ត ពីព្រោះគាត់ខ្លាចវាអាចមានគ្រោះថ្នាក់ដល់ជីវិតរបស់គាត់ម្តងទៀត ។ អ៊ីចឹងហើយការមិនទុកចិត្តនេះហើយ ដែលធ្វើឲ្យគាត់រុញរារហូត ។ ហើយនេះគឺជាផលវិបាកនៃការ បញ្ហាផ្លូវចិត្តដែលគាត់បានទទួលពីសម័យខ្មែរក្រហម ។

**ស៖** សូមអរគុណ ។ សំណួរចុងក្រោយរបស់ខ្ញុំ កូនក្តីខ្លះរបស់ខ្ញុំមិនត្រឹមតែបាត់បង់ម្តាយ ឬក៏ បងប្អូន ឬក៏ឪពុកទេ ប៉ុន្តែត្រូវបាត់បង់បងប្អូនជីដូនមួយ ឬក៏ជីដូនជីតា ឬក៏បងប្អូនថ្លៃផង ។ អ្នកដែលគេ ចាត់ទុកថានៅក្នុងវប្បធម៌ផ្សេងគឺថានៅសាច់ឆ្ងាយ ប៉ុន្តែ នៅក្នុងអង្គជំនុំជម្រះក្នុងនីតិវិធីនេះ កូនក្តីរបស់ យើងមានការឈឺចាប់គឺវាមានលក្ខណៈធ្ងន់ធ្ងរ ។ តើលោកអាចពន្យល់បានទេអ្នកដែលបាត់បង់ជីដូនជីតា ឬក៏បងប្អូនថ្លៃ ថាតើមានការឈឺចាប់ក្នុងទំហំណាដែរ សាច់ញាតិដែលមិនជាប់ផ្ទាល់នោះ?

[១១:៣៧:៤៩]

**ឆ៖** ក្នុងករណីនេះគឺវាអាស្រ័យទៅលើ *អាថាច់មិន* (Attachment) ទៅលើចំណងរវាងគាត់ ហើយនិងអ្នកដែលស្លាប់ទៅ ។ ចំពោះសង្គមគ្រួសារកម្ពុជា យើងឃើញថា ជាសង្គមគ្រួសារមួយពីដើម ដែលមានការគោរពចាស់ទុំ មានការដឹងគុណ មានការសងគុណ ហើយចំពោះអ្នកដែលជាកូនជាចៅជា បងប្អូនជីដូនមួយជាដើមហ្នឹង គាត់អាចមាននូវទំនាក់ទំនងអ្វីមួយនៅក្នុងជាមួយអ្នកដែលស្លាប់ ។

ឧទាហរណ៍ អ្នកដែលស្លាប់អាចជាអ្នកចិញ្ចឹមបីបាច់ថែរក្សាគាត់ អ្នកដែលស្លាប់អាចជាអ្នកដែលផ្តល់ដំបូន្មានល្អសម្រាប់គាត់ ។

ឧទាហរណ៍ អ្នកដែលស្លាប់អាចជាអ្នកដែលមានគំរូល្អសម្រាប់គាត់ ដែលជាអ្នកត្រួសត្រាយផ្លូវជីវិតសម្រាប់គាត់ ។

អ៊ីចឹងករណីទាំងអស់នេះ វាជាចំណងមួយដ៏ជិតស្និទ្ធដែលធ្វើឲ្យគាត់មិនអាចបំភ្លេចបាន ។ អ៊ីចឹងហើយគាត់ត្រូវធ្វើយ៉ាងណាដើម្បីសងគុណចំពោះអ្នកដែលស្លាប់ ប៉ុន្តែដោយសារការសងគុណហ្នឹងមិនអាចធ្វើបានដោយសារគាត់ស្លាប់ ។ អ៊ីចឹងគាត់ត្រូវធ្វើយ៉ាងណាដើម្បីសងគុណគាត់ តាមវិធីសាស្ត្ររកយុត្តិធម៌ អ៊ីចឹងហើយបានខ្ញុំជឿថាការសងគុណនេះ ការដឹងគុណនេះ ការចែករំលែកការឈឺចាប់នេះ ហើយដែលធ្វើឲ្យពួកគាត់ដាក់មកប្តឹងនៅតុលាការដើម្បីរកយុត្តិធម៌ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកវេជ្ជបណ្ឌិតដែលលោកបានឆ្លើយសំណួររបស់ខ្ញុំ។ ខ្ញុំអស់សំណួរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសួរដល់អ្នកជំនាញរូប ហើយមេធាវីការពារក្តីមានពេលវេលាសាមសិបនាទីនៅក្នុងការសួរនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយ លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ ។

**ស៖** សូមគោរពលោកវេជ្ជបណ្ឌិត! តាមរយៈការកាត់ទោសខ្មែរក្រហម លោកវេជ្ជបណ្ឌិតបានមានប្រសាសន៍ថាការកាត់មេដឹកនាំខ្មែរក្រហមនេះ អាចធ្វើឲ្យជនរងគ្រោះទាំងអស់នោះបានជាសះស្បើយផ្លូវចិត្ត ។ ខ្ញុំបាទសូមសួរលោកវេជ្ជបណ្ឌិតថា នៅតាមមូលដ្ឋានក៏ដូចជានៅតាមគុកទាំងអស់ ពីររយគុកក្នុងស្រុកខ្មែរ ប្រជាជនគេស្គាល់ថាអ្នកដែដល់នៅកាលសម័យខ្មែរក្រហម ដូចនៅតាមមូលដ្ឋានគេស្គាល់ច្បាស់ថា នែ៎! អ្នកនេះចងឪអញយកទៅសម្លាប់ អ្នកនេះចងកូនអញយកទៅសម្លាប់ ហើយគុកទាំងអស់អ្នកដែដល់ បានសេចក្តីថាអ្នកដែដល់គេអត់យកមកកាត់ទោសនៅទីនេះទេ អ្នកដែដល់នៅគ្រប់ទាំងពីររយគុកក្នុងស្រុកខ្មែរក៏គេអត់យកមកកាត់ទោសដែរ ។

អ៊ីចឹង ខ្ញុំសូមសួរលោកវេជ្ជបណ្ឌិត សូមលោកវេជ្ជបណ្ឌិតជួយបញ្ជាក់មើលថា តើត្រូវព្យាបាល

ផ្លូវចិត្តយ៉ាងណាខ្លះ ដើម្បីឲ្យជនរងគ្រោះទាំងអស់នោះឈប់នឹងអ្នកដៃដល់ ដែលបានសម្លាប់គ្រួសាររបស់គេ? សូមអរគុណ សូមលោកវេជ្ជបណ្ឌិតមេត្តាបញ្ជាក់ ។

**ឆៈ** បាទ, សូមអរគុណ ។ ជាការពិតណាស់ ការស្វែងរកយុត្តិធម៌ ជាពិសេសគឺសាលាក្ដីនេះគឺកាត់ទោសត្រឹមតែមេដឹកនាំកំពូលៗប៉ុណ្ណោះ ។ ចំណែកឯជនដៃដល់ផ្ទាល់-- ដែលការដឹកនាំ-- កាត់ទោសជនកំពូលៗដែលជាថ្នាក់ដឹកនាំកំពូល ក្បាលម៉ាស៊ីនរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ចំពោះអ្នកដែលដៃដល់ដោយផ្ទាល់នោះគឺជាអ្នកនៅក្នុងមូលដ្ឋាន នៅក្នុងសហគមន៍ដែលគាត់បានសម្លាប់ដោយផ្ទាល់ ដែលគាត់បានធ្វើទារុណកម្មដោយផ្ទាល់ ។ នៅក្នុងករណីនេះ វាជាការលំបាកសម្រាប់ជនរងគ្រោះពីព្រោះពួកគេនៅក្នុងសហគមន៍ជាមួយគ្នា ពួកគេបានទៅវត្តជាមួយគ្នា នៅក្នុងវត្តតែមួយនៅក្នុងសហ-គមន៍ ប្រើប្រាស់ធនធាននៅសហគមន៍ដូចគ្នា ពួកគេធ្វើអ្វីៗចែករំលែកដូចថា ប្រើប្រាស់ធនធាននៅក្នុងសហគមន៍ជាមួយគ្នា ។ ដូច្នេះ ការឃើញគ្នារាល់ថ្ងៃគឺជាការមួយដែលលំបាក ហើយដែលជាការមួយបន្តអាចជាការបន្តនិងការឈឺចាប់របស់ពួកគាត់ ។

ប៉ុន្តែ ខ្ញុំបាទសូមបញ្ជាក់ថា យើងត្រូវធ្វើយ៉ាងណាដើម្បីឲ្យវាមានការរកយុត្តិធម៌ ឬក៏ការផ្សះផ្សាតាមដំណាក់កាល ។ យុត្តិធម៌ដែលយើងឃើញនៅតុលាការនេះ វាអាចជាយុត្តិធម៌មួយដែលនិមិត្តរូបមួយ ពីព្រោះវាជាការធ្វើការកាត់ទោសនៅក្នុងមេដឹកនាំកំពូល។ ប៉ុន្តែ ខ្ញុំបាទគិតថាដើម្បីព្យាបាលផ្លូវចិត្តចំពោះជនដែលនៅសហគមន៍ យើងគួរគិតអំពីយន្តការណាផ្សេងទៀតដែលធ្វើយ៉ាងណាអាចឲ្យមានការផ្សះផ្សា ដែលការផ្សះផ្សាហ្នឹងអាចនឹងមានឈានទៅរកការព្យាបាលផ្លូវចិត្ត អាចជាសះស្បើយផ្លូវចិត្ត ហើយចំពោះការផ្សះផ្សាយ៉ាងណានោះ ខ្ញុំបាទមិនទាន់គិតឃើញថាត្រូវធ្វើយ៉ាងណាទេ ប៉ុន្តែវាជាការមួយដែលយើងទាំងអស់គ្នា ទាំងរដ្ឋាភិបាល ទាំងអង្គការសង្គមស៊ីវិល ទាំងអជ្ញាធរពាក់ព័ន្ធ ដែលគួររួមគ្នាបង្កើតជាវេទិកាអ្វីមួយដើម្បីជជែក ឬក៏មួយដើម្បីបង្កើតជាវេទិកាផ្សះផ្សា ឬក៏យ៉ាងណាទៀតក៏ខ្ញុំបាទមិនទាន់ច្បាស់ដែរ ប៉ុន្តែខ្ញុំគិតថានេះគឺជាវិធីមួយដែលយើងអាចធ្វើ ឬមួយក៏យើងអាចបង្កើតជាតុលាការនៅមូលដ្ឋាន ឬមួយក៏យ៉ាងណាក៏អាចជា *អុបសិន* (Option) ដែលៗគិតហើយអាចជាអ្វីដែលយើងទាំងអស់គ្នាគឺគិតទាំងអស់គ្នាបាទ ។

[១១:៤៤:៤៤]

**សៈ** សូមអរគុណលោកវេជ្ជបណ្ឌិត។ សំណួរទីពីរ គឺខ្ញុំគ្រាន់តែសូមឲ្យលោកវេជ្ជបណ្ឌិតបញ្ជាក់ឡើងវិញទេ ពីព្រោះសំណួរនេះវាហាក់ដូចជាវាស្រដៀងៗនឹងសំណួរដែលលោកសហព្រះរាជអាជ្ញា

អន្តរជាតិបានសួរ ដូច្នេះខ្ញុំសូមឲ្យលោកវេជ្ជបណ្ឌិតមេត្តាគ្រាន់តែបញ្ជាក់ឡើងវិញ ព្រោះថាកន្លងមកដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះសុទ្ធតែបានដឹងថាជនជាប់ចោទទទួលបញ្ជាពីថ្នាក់លើ សុទ្ធតែបានដឹងថាជនជាប់ចោទបានបញ្ជាទៅថ្នាក់ក្រោមតៗគ្នា ហើយដើមបណ្ដឹងរដ្ឋប្បវេណី ជនរងគ្រោះ សុទ្ធតែបានដឹងថា ជនជាប់ចោទមិនដែលបានសម្លាប់ជនរងគ្រោះណាម្នាក់ដោយផ្ទាល់ដៃនោះទេ ហើយក៏បានដឹងដែរថា ជនជាប់ចោទមិនដែលបានធ្វើទារុណកម្ម ដល់ជនរងគ្រោះណាម្នាក់ដោយផ្ទាល់ដៃនោះដែរ ។ ហើយជនជាប់ចោទ ក៏បានលើកដៃសំពះសូមទោសដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាវិញ្ញាណក្ខន្ធជនរងគ្រោះដែលបបាត់បង់ជីវិតទៅ ។

តែដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ជនរងគ្រោះដែលនៅរស់នៅតែមិនទទួលការសូមទោសនេះ អ៊ីចឹងសូមលោកវេជ្ជបណ្ឌិតមេត្តាបញ្ជាក់ឡើងវិញ ។ តើត្រូវព្យាបាលជំងឺផ្លូវចិត្តជនរងគ្រោះ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីតាមវិធីណាខ្លះ ដើម្បីឲ្យជនរងគ្រោះ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះបានជាសះស្បើយផ្លូវចិត្ត ហើយអនុគ្រោះដល់ជនជាប់ចោទ សូមលោកវេជ្ជបណ្ឌិតមេត្តាបញ្ជាក់ ។ សូមអរគុណ ។

**ឆៈ** បាទ, សូមអរគុណ ។ សំណួរនេះគឺជាសំណួរល្អហើយក៏ជាសំណួរពិបាកដែរ ។ ប៉ុន្តែ ខ្ញុំបាទសូមបញ្ជាក់ថា ខ្ញុំបាទសូមទទួលស្គាល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីមានការឈឺចាប់បញ្ហាផ្លូវចិត្តជាប់ជាប្រចាំជាយូរមកហើយ ហើយនេះគឺជាឱកាសមួយដែលគាត់បានបញ្ចេញនូវកំហឹងនូវអារម្មណ៍របស់គាត់ទាំងប៉ុន្មាន ។ ទៅតាមទ្រឹស្ដីថាការបញ្ចេញនូវអារម្មណ៍នូវកំហឹងទាំងឡាយដែលគាត់មាននោះវាអាចជាដំណើរការមួយដែលអាចឈានទៅរកការផ្សះផ្សា ឬក៏ការជាសះស្បើយ។ ប៉ុន្តែ ខ្ញុំមិនទាន់កំណត់ថាវាជាការជាសះស្បើយទេ វាអាចដំណើរការ វាអាចជាការបើកផ្លូវមួយជាង ។

ក្រោយពីការជាបញ្ចេញកំហឹង ជាការធម្មតានៅពេលជនរងគ្រោះជួបជនដៃដល់ កំហឹងអារម្មណ៍ភាពអវិជ្ជមានទាំងឡាយអាចកើតមានចំពោះជនដៃដល់ ។ ដូច្នេះ អាហ្នឹងវាអាចជាការបើកទ្វារសម្រាប់ឈានទៅរកការជាសះស្បើយ ។ ហើយចំពោះជនដៃដល់ខ្ញុំគិតថាវាជាបញ្ហាមួយ វាអាស្រ័យទៅលើភាពស្មោះត្រង់របស់ពួកគាត់ អាស្រ័យទៅលើលទ្ធភាព ឬក៏សមត្ថភាពរបស់គាត់ដែលអាចពន្យល់ ដែលអាចបង្ហាញទៅជនរងគ្រោះថា អ្វីដែលគាត់និយាយហ្នឹងជាការពិត ។ ដើម្បីឲ្យជនរងគ្រោះអាចទទួលស្គាល់ ដើម្បីឲ្យជនរងគ្រោះអាចទទួលយកបាននូវអ្វីដែលគាត់និយាយហ្នឹងថាជាការពិត។

ប្រសិនបើអាចបង្ហាញបាន ខ្ញុំជឿថា ដំណើរការនៃការជាសះស្បើយវានឹងចំណាយពេលវេលា ហើយវាមានលក្ខណៈបុគ្គល បុគ្គលខ្លះគាត់អាចទទួលយកបាន ប៉ុន្តែក៏មានបុគ្គលខ្លះមិនទទួលយកបាន

ក្នុងមួយជីវិតរបស់គាត់ដែរ ។ ដូច្នេះគឺជាចម្លើយដែលខ្ញុំអាចឆ្លើយប៉ុណ្ណឹងបាទ ។

[១១:៤៩:០៧]

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកវេជ្ជបណ្ឌិត ។ ហើយសូមលោកប្រធាន មេត្តាអនុញ្ញាតឲ្យមេធាវីអន្តរជាតិ មេត្តាសួរបន្ត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**សួរដោយលោក ហ្រ្វង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមអរគុណលោកវេជ្ជបណ្ឌិត ។ លោកបានបញ្ជាក់ពីបញ្ហាមួយចំនួនច្រើនហើយ ហើយលោកក៏បានផ្តល់វិភាគទានដ៏ច្រើនដល់ដំណើរការនីតិវិធីនេះ ខ្ញុំក៏អរគុណលោកវេជ្ជបណ្ឌិតដែរ ។

ខ្ញុំប្រហែលជាមានសំណួរមួយចំនួនតូច ។ តាមពិត យើងបានឆ្លងកាត់បញ្ហាមួយចំនួនដែលកើតឡើងនៅស-២១ ពីព្រោះថាយើងបានលើកឡើងពីបញ្ហាមួយចំនួនតាំងពីចាប់ផ្តើមព្រឹកនេះ គឺអំពីជំងឺបាក់ស្បាត ឬក៏ផ្លូវចិត្តដែលពលរដ្ឋកម្ពុជាបានទទួលរង ។ លោកទើបតែបាននិយាយអំពីអ្វីដែលយើងអាចប្រមើលមើលឃើញក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាថា ជាលទ្ធផលមួយថាអ្វីអាចនឹងកើតមានឡើង ជាលទ្ធផលនៃការជំនុំជម្រះនេះ អាចជានិមិត្តរូប ។

**ស៖** សំណួរទីមួយរបស់ខ្ញុំចំពោះលោកនោះ ថាតើលោកមានព័ត៌មានអ្វី អំពីអ្វីដែលខ្ញុំហៅថាជាការពិតតូចមួយ ហើយជាដែលត្រូវកើតមានឡើងនៅក្នុងតំបន់ភូមិភាគផ្សេងៗនៃកម្ពុជា។ តើលោកមានបរិបទអ្វីក្នុងអង្គការរបស់លោកដែលត្រូវយកទៅអនុវត្ត ដើម្បីដោះស្រាយនូវបញ្ហាប្រឈមមុខរវាងជនរងគ្រោះ ហើយនិងអ្នកដែលរស់នៅតាមជនបទផ្សេងៗនៅកម្ពុជានោះ?

**ឆ៖** បាទ សូមអរគុណ ។ ចំពោះការអន្តរាគមន៍ផ្នែកផ្លូវចិត្ត ដែលអង្គការធីភីអូ បានធ្វើ គឺមិនបាន មកដល់ថ្ងៃនេះ គឺមិនទាន់បានផ្តោតចិត្តទុកដាក់ ជាសកម្មទៅលើការអន្តរាគមន៍រវាងជនដែលរស់ និងជនរងគ្រោះនៅក្នុងសហគមន៍ទេ ពីព្រោះថាបញ្ហាផ្លូវចិត្តដែលកើតមាននោះ សម្រាប់ប្រជាជនវាមានលក្ខណៈធំធេង។ ហើយអ្វីដែលយើងធ្វើគឺយើងការផ្តោតទៅលើការផ្តល់អន្តរាគមន៍ជាលក្ខណៈទូទៅ បញ្ហាផ្លូវចិត្តជាទូទៅ យើងមិនទាន់មានលទ្ធភាពទាំងថវិកា ទាំងធនធានមនុស្សនៅក្នុងការធ្វើការផ្តល់

អន្តរាគមន៍នៅក្នុងលក្ខណពិសេសដូចជា ភាពផ្សះផ្សារវាងជនរងគ្រោះ ឬក៏ជនដែលរស់នៅក្នុងសហគមន៍នៅឡើយទេ ។

ប៉ុន្តែ យើងក៏បានគិតដែរថា នៅពេលការបញ្ចប់នៃសាលាក្តីនេះ យើងក៏បានគិតថានឹងធ្វើអ្វីមួយដើម្បីជួយឲ្យមានផ្សះផ្សានៅក្នុងកម្រិតកម្រិតសហគមន៍ទៅថ្ងៃមុខទៀត ដោយយើងគិតថាសាលាក្តីនេះអាចផ្តល់ជាយុត្តិធម៌ជានិមិត្តរូបនៅក្នុងកម្រិតជាតិ។ ប៉ុន្តែ យើងត្រូវគិតអំពីយុត្តិធម៌នៅក្នុងកម្រិតសហគមន៍ដែរ ។

[១១:៥៣:១១]

**ស៖** សូមអរគុណចំពោះចម្លើយរបស់លោក ។ ឥឡូវសំណួរផ្សេងមួយទៀតជូនលោក។ យើងបាននិយាយជាច្រើនអំពីការអភ័យទោស ការលើកលែងទោសក្នុងដំណើរការដែលយើងបានអនុវត្តកន្លងមក ប៉ុន្តែខ្ញុំនឹងសួរសំណួរមួយជូនលោកក្នុងខណៈលោកជាពលរដ្ឋខ្មែរ ហើយនិងជាអ្នកជំនាញ តើលោកអាចពន្យល់យើងខ្ញុំបានទេ តើក្នុងវប្បធម៌ខ្មែរ តើការអត់ឱនទោសនោះ មានលក្ខណៈសំខាន់ដូចម្តេចក្នុងវប្បធម៌ខ្មែរ? ខ្ញុំជឿថា ប្រហែលជាសញ្ញាណមួយប្លែកខុសពីអ្វី ដែលយើងយល់បាននៅក្នុងបស្ចិមប្រទេសនោះ ។

[១១:៥៤:៣៣]

**ឆ៖** បាទ, សូមអរគុណចំពោះសំណួររបស់លោក ។ ចំពោះបរិបទកម្ពុជាក្នុងការអភ័យទោស គឺខ្ញុំគិតថា ផ្អែកទៅលើផ្នែកជំនឿក្នុងព្រះពុទ្ធសាសនា ដែលវាជាការបូកបញ្ចូលរវាងការអភ័យទោសនៅក្នុងផ្នែកផ្លូវលោកហើយនិងផ្លូវធម៌ ។ ចំពោះការអភ័យទោសក្នុងផ្នែកផ្លូវលោក ខ្ញុំជឿថាប្រជាជនអាចអភ័យទោសបានប្រសិនបើមានការសុំការអភ័យទោស ប្រសិនបើការពិតត្រូវបានទទួល ប្រសិនអ្វីៗត្រូវបានផ្សះផ្សានិងដោះស្រាយ ។

ប៉ុន្តែ នៅក្នុងផ្លូវធម៌តាមបែបព្រះពុទ្ធសាសនា អ្នកដែលធ្វើអំពើអ្នកហ្នឹងនឹងទទួលផល អ្នកដែលធ្វើបាប អ្នកហ្នឹងនឹងទទួលរងកម្មនៅក្នុងជាតិក្រោយ ។ អ៊ីចឹង ការអភ័យទោសចួនកាលអាចមាននៅក្នុងផ្លូវលោក ប៉ុន្តែចំពោះផ្លូវធម៌អ្នកដែលប្រព្រឹត្តកំហុសអ្នកហ្នឹងនឹងទទួលទោស ។ ដូច្នេះ ហ្នឹងគឺជាអ្វីដែលប្រជាជនកម្ពុជាជំនឿថា ចួនកាលវាអាចជាកត្តាល្អដែរពីព្រោះគាត់គិតថា គាត់អាចមិនអាចធ្វើអ្វីចំពោះជនរងគ្រោះបាននៅក្នុងជាតិនេះ ប៉ុន្តែព្រះទេព្តានឹងដាក់ទណ្ឌកម្មនៅពេលដែលគាត់ស្លាប់ទៅជាតិក្រោយ ។ អ៊ីចឹងនេះគឺជាការយល់តាមបែបអភ័យទោសតាមបែបព្រះពុទ្ធសាសនា ដែលប្រជាជនយើងបានយល់

និងបានជឿ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ខ្ញុំត្រូវការពេលបន្ថែមបន្តិចទៀត ដោយខ្ញុំមិនប្រាកដថាលោកប្រធានចង់សម្រាកពេលនេះដែរឬទេ ប៉ុន្តែតាមពិតខ្ញុំត្រូវការពេលបន្តិចទៀត ។

[១១:៥៦:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកបន្ត ព្រោះសាមសិបមីនុតទៀត លោកមានពេលវេលារហូតដល់ម៉ោងដប់ពីរ ប្រាំពីរនាទី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនប្រាកដថា ខ្ញុំនឹងបញ្ចប់នៅម៉ោងដប់ពីរ ប្រាំពីរមីនុតនោះទេ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្ដើមបន្តទៅទៀត ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** ខ្ញុំដូចជាមានអារម្មណ៍រំខានបន្តិច នៅពេលដែលមនុស្សមួយចំនួន នៅក្នុងដំណើរការនីតិវិធីនេះប្រើពាក្យថា ការអត់ឱនទោសនោះ ថាជាការងាយស្រួល ។ ខ្ញុំសូមឲ្យលោករំឭកប្រាប់យើងថា តើការអត់ឱនទោស ការអភ័យទោសនេះ គឺជាដំណើរការយឺត ប្រព្រឹត្តទៅយឺតឬដូចម្ដេច? ដែលថាអាចនឹងប្រើពេលឆ្ងាយផុតពីដំណើរការនីតិវិធីនេះទៅទៀត ។ ប៉ុន្តែ តាមដែលខ្ញុំយល់ ខ្ញុំមិនយល់ច្បាស់ទេថា តើនៅទីនេះយើងប្រាប់ទៅជនរងគ្រោះដែលមកសម្ដែងអំពីសេចក្ដីទុក្ខសោករបស់គាត់នោះ ។ ហើយយើងអាចសួរថាតើអ្នកអាចនឹងត្រៀមខ្លួនដើម្បីលើកលែងទោសបានដែរឬទេ? នេះជាចំណុចមួយ ។

លោកអាចនឹងជម្រាបប្រាប់យើងថា ក្នុងខណៈពេលដែលថា មានយុត្តិធម៌ អាចនឹងធ្វើឲ្យអ្វីនឹងដោះស្រាយបានរវាងជនរងគ្រោះហើយនិងជនជាប់ចោទ ។ តើខ្ញុំនិយាយអ៊ីចឹងត្រូវទេថា ឥឡូវនេះវាឆាប់ពេកដើម្បីនឹងយើងនិយាយថានឹងសុំឲ្យជនរងគ្រោះពេលនេះ ថាតើអ្នកនឹងផ្ដល់ការអភ័យទោសនោះដូចជាឆាប់ពេកនៅពេលនេះ?

**ឆ៖** បាទ, សូមអរគុណលោក ។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនមានជំនាញនៅក្នុងការងារទាក់ទងនឹងការអភ័យទោស ឬក៏យុត្តិធម៌ ឬក៏យ៉ាងណានោះទេ ។ ដូច្នេះ ប៉ុន្តែព្រឹកមិញហ្នឹងហាក់ដូចជាមានការពិភាក្សាច្រើនទាក់ទងទៅនឹងការអភ័យទោស ទាក់ទងនឹងជំងឺផ្លូវចិត្តទាក់ទងអី ដូច្នេះការពន្យល់របស់ខ្ញុំ

វាអាចមានការមិនច្បាស់លាស់ ឬក៏មិនគ្រប់ជ្រុងជ្រោយខ្លះ ។

ប៉ុន្តែ ខ្ញុំសូមបញ្ជាក់ថា អង្គជំនុំជម្រះនេះ នៅក្នុងដំណាក់កាលនេះ ការសុំអភ័យទោស ខ្ញុំយល់ស្របតាមលោកថា វាជាដំណាក់កាលមួយរាងនៅ*អ៊ីលី* បន្តិច ដូចជាឆាប់ពេកបន្តិច ពីព្រោះអ្វីៗមិនទាន់បានច្បាស់នៅក្នុងចិត្តទាំងសាក្សីដើមបណ្ដឹង ទាំងប្រជាពលរដ្ឋទូទាំងប្រទេសទេ ដែលគាត់បានតាមដានដែលបានស្ដាប់នោះ ។ ដូច្នេះ វាជាដំណើរការមួយដែលនៅវែងឆ្ងាយតទៅទៀត ក្រោយពីតុលាការនេះបានបញ្ចប់ទៅ ចួនកាលអភ័យទោស ឬក៏ការផ្សះផ្សាអាចមិនទាន់មានក៏ថាបាន ។ ការអភ័យទោសវាជាដំណើរការមួយ ហើយវាអាចមានលក្ខណៈជាបុគ្គល ហើយក៏វាអាចមានលក្ខណៈជារួមដែរ ។

ប៉ុន្តែ ចំពោះបុគ្គលខ្ញុំជឿថា វាខុសគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀត វាអាស្រ័យទៅលើអត្ថន័យដែលគាត់ផ្ដល់ទៅលើអ្វីដែលកើតឡើង អាស្រ័យទៅលើអ្វីដែលគាត់ទទួលបាន អាស្រ័យទៅលើការពិត ឬក៏អ្វីៗផ្សេងទៀតដែលគាត់ទទួលបាននឹងការយល់ស្របដែលគាត់ទទួលបានពីជនជាប់ចោទក្ដី ឬក៏ពីក្នុងតុលាការនេះ ។ ដូច្នេះ គឺជារឿងមួយដែលលំបាកស្មុគស្មាញវែងឆ្ងាយ ជនមួយចំនួនអាចទទួលបាននូវការអភ័យទោស ប៉ុន្តែ ក៏អាចមានជនមួយចំនួនក៏អាចផ្ទុកនូវការគំនុំ និងការមិនអភ័យទោសហ្នឹងក្នុងជីវិតរបស់គាត់ក៏មានដែរ ។ ហ្នឹងគឺជាអ្វីដែលខ្ញុំអាចគ្រាន់តែបញ្ជាក់បានតាមចំណេះដឹងខ្លះៗបាទ ។

[១២:០១:៤០]

**ស៖** សូមអរគុណ ។ តើលោកយល់ស្របជាមួយខ្ញុំដែរឬទេថា វាមានភាពចាំបាច់ត្រូវការបែងចែកឲ្យបានច្បាស់លាស់រវាងជនជាប់ចោទ នៅពេលដែលគាត់និយាយថា "ខ្ញុំសូមឲ្យអស់លោកអ្នកអភ័យទោស" នេះគឺជាផ្នែកមួយដែលជាសំណើររបស់គាត់ ហើយការអត់ឱនទោសនោះនឹងផ្ដល់ឲ្យបាន ឬក៏មិនអាចផ្ដល់ឲ្យបានដោយជនរងគ្រោះ នោះគឺវាអាស្រ័យទៅលើពេលវេលា ។

តើលោកយល់ស្របជាមួយខ្ញុំដែរឬទេថា នៅថ្ងៃនេះការទទួលខុសត្រូវរបស់ជនជាប់ចោទ គឺការដែលគាត់សុំឲ្យការអភ័យទោស។ ប៉ុន្តែជនរងគ្រោះគាត់មិនមានកាតព្វកិច្ច និងការទទួលខុសត្រូវក្នុងការផ្ដល់អត់ឱនទោសនោះទេ តើលោកយល់ស្របទេចំណុចពីរនេះ គឺជាចំណុចពីរខុសគ្នាតែម្ដង?

**ឆ៖** បាទ, ខ្ញុំគិតថាវាជាការឆាប់ពេក ពីព្រោះអ្វីៗមិនទាន់បានបង្ហាញឲ្យឃើញច្បាស់ទេ ថាតើសុំអភ័យទោស សុំការលើកលែងទោសទៅជនដើមបណ្ដឹងនៅពេលនេះ ខ្ញុំគិតថា វាហាក់ដូចជានៅថ្មី ។ ដូច្នេះ ខ្ញុំយល់ស្របតាមលោកថា ប្រហែលជានៅរយៈពេលវែងឆ្ងាយតទៅទៀត ដែលការអភ័យទោស ឬក៏ការសុំអភ័យទោស អាចនឹងកើតឡើងនៅពេលមុខ ខ្ញុំថានៅពេលនេះ ខ្ញុំបាទមិនទាន់ច្បាស់ទេគឺខ្ញុំបាទ

គិតថា សំខាន់ត្រូវធ្វើយ៉ាងណាដើម្បីឲ្យដឹងអំពីព័ត៌មាន ដើម្បីឲ្យដឹងពីរឿងរ៉ាវដែលកើតឡើង ដើម្បីឲ្យដឹងពីការពិត ហើយដើម្បីឲ្យពួកគាត់ហ្នឹងបានស្ងប់នូវបញ្ហាអាថ៌កំបាំង ដែលគាត់មិនបានដឹងតាំងពីសាមសិបឆ្នាំមកហើយ ។

[១២:០៣:៥២]

**ស៖** សូមអរគុណលោក ។ លោកស្រីចៅក្រម ខាតវ៉ាយថ៍ លោកស្រីបានរំឭកយើងថា យើងនៅទីនេះ ដើម្បីរកភាពត្រឹមត្រូវនៃសេចក្ដីស្វែងរកការពិត ។ ប៉ុន្តែ ខ្ញុំមានសំណួរបន្ថែមមួយទៀត ជនរងគ្រោះគឺមានលក្ខណៈសាមញ្ញ គាត់ចង់ស្វែងយល់ដូចដែលលោកបានរៀបរាប់ គាត់បានជនរងគ្រោះបានសួរថា ហេតុអ្វីបានជាវាកើតឡើងដូច្នោះ? តើលោកឹតដែរឬទេ ឬក៏លោកមិនយល់ទេទៅលើចំណុចនេះដែលថា វាជាពេលមួយដែលយើងគួរតែជម្រាបទៅដល់ជនរងគ្រោះថាគាត់នឹងទទួលបាននូវចម្លើយទាំងអស់នោះទេ ។ ហើយគ្មាននរណាអាចនឹងពន្យល់អំពីមូលហេតុអ្វី បានជារបប ប៉ុល ពត វាកើតឡើងដូច្នោះនោះទេ ។ តើយើងគួរតែកុំឲ្យជនរងគ្រោះ គាត់យល់ឃើញអ្វីដែលគាត់ចង់បានទាំងអស់នោះដែរឬទេ? ចំពោះមូលហេតុ ដែលគាត់ចង់យល់អំពីរបប ប៉ុល ពត ។

នៅទីនេះហើយ ដែលយើងព្យាយាមរកឲ្យឃើញសេចក្ដីពិតឲ្យបានត្រឹមត្រូវ ។ ប៉ុន្តែ ចំពោះមូលហេតុ ដែរថាហេតុអ្វីបានជាមានរបបខ្មែរក្រហមបែបនោះ? ថាតើមាននរណាម្នាក់ គាត់អាចមានជំហរពន្យល់ឲ្យបានច្បាស់លាស់ទៅលើចំណុចនេះដែរឬទេ?

ដូច្នេះហើយតើថាយើងត្រៀមខ្លួនឲ្យគាត់យល់ទៅលើបញ្ហានោះ ចំពោះជនរងគ្រោះនោះ? ហើយចង់ឲ្យជនរងគ្រោះ គាត់យល់ថាគាត់នឹងមិនទទួលនូវចម្លើយ-សំណួររបស់គាត់នោះទេ ទោះបីជាសំណួររបស់គាត់នោះ មានភាពត្រឹមត្រូវយ៉ាងណាក៏ដោយ ។ ថាតើយើងមិនគួរ ឬក៏យើងគួរតែបញ្ជាក់ប្រាប់គាត់ថា គាត់នឹងមិនទទួលបានចម្លើយទាំងអស់នោះទេ ។

**ឆ៖** បាទ, សូមអរគុណ ។ សំណួរនេះ គឺជាសំណួរពិបាក ហើយ គឺជាបញ្ហាសាំញ៉ាំមួយ ។ ខ្ញុំគិតថា ការដឹងការពិត និងយុត្តិធម៌ គឺជារឿងសំខាន់ ។ នេះគឺអ្វីដែលជនរងគ្រោះចង់បាន ហើយគឺជាលក្ខខណ្ឌមួយដែលភ្ជាប់ជាមួយនឹងការជាសះស្បើយនៃបញ្ហាផ្លូវចិត្ត ដែលគាត់បានទទួល ។ ប៉ុន្តែការពិតគឺជារឿងមួយដែលលំបាកនៅក្នុងបញ្ចេញ ។ ខ្ញុំគិតថាមនុស្សម្នាក់ៗអាចបញ្ចេញនូវការពិត *វើរហ្សិនអហ្វ ទ្រូស (Version of Truth)* រៀងៗខ្លួន ។ ប៉ុន្តែ វាអាស្រ័យទៅលើការទទួលបាននូវពិត ការយើងទទួលយកបានការពិតនេះ ពីសំណាក់ជនរងគ្រោះយ៉ាងណា ។ បើតាមនិយាយឲ្យខ្លីទៅ គឺថាការពិតវា

មានការលំបាកណាស់ អ៊ីចឹងអ្នកដែលនូវដឹងការពិតបាន គឺវាអាចមានតែដែលប្រព្រឹត្តផ្ទាល់ ហើយព្រះជាម្ចាស់ដែលអាចដឹងនូវការពិតបាន ។

ដូច្នេះ ការសម្តែងចេញការពិត ឬមិនពិត វាអាស្រ័យទៅលើបុគ្គល ហើយនិងអាស្រ័យទៅលើលទ្ធភាពធ្វើយ៉ាងណាដើម្បីឲ្យជនរងគ្រោះអាចទទួលយកបាន ។ ខ្ញុំមិនមានចម្លើយអីលើសពីហ្នឹងទៀតទេបាទ ។

**ស៖** ខ្ញុំនៅសល់សំណួរចុងក្រោយមួយទៀត។ លោកវេជ្ជបណ្ឌិតបានធ្វើការពិពណ៌នារៀបរាប់អំពីប្រទេសដែលបានទទួលរងគ្រោះប៉ះទង្គិចផ្លូវចិត្តនូវអ្វីដែលកើតឡើង ហើយយើងយល់ទៅលើចំណុចនេះ ។ ហើយនៅពេលនេះដែរ បុគ្គលដែលគាត់មកប្រទេសកម្ពុជា គឺគាត់បានឃើញអំពីការវិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា ដែលប្រទេសនេះកំពុងតែព្យាយាមធ្វើការចាត់ចែង និងដោះស្រាយទៅលើសោកនាដកម្ម និងប៉ះទង្គិចផ្លូវចិត្តនេះ នៅក្នុងពេលអនាគត ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេថាសូមឲ្យលោកពន្យល់ខ្លីៗថាអ្វីទៅដែលហៅថា ភាពស្ងប់ស្ងាត់នោះ? ហើយនិងក្តីសង្ឃឹមដែរថានៅថ្ងៃណាមួយប្រទេសកម្ពុជានឹងប្តូរ ហើយបើកទំព័រថ្មីសន្តាងមួយសម្រាប់ប្រទេសរបស់ខ្លួន?

**ឆ៖** បាទ, សូមអរគុណ ថានៅក្នុងដំណាក់កាលឥឡូវនេះ ចាប់តាំងពីសម័យបញ្ចប់សម័យខ្មែរក្រហម មកដល់ពេលនេះ យើងគ្រប់ៗគ្នា ទាំងក្នុងកម្រិតបុគ្គល កម្រិតគ្រួសារ សង្គម រដ្ឋាភិបាល សុទ្ធតែខំប្រឹងធ្វើយ៉ាងណា ដើម្បីលើកស្ទួយជីវភាព ដើម្បីកសាងឡើងវិញ ដើម្បីបណ្តុះបណ្តាលនូវធនធានមនុស្ស គ្រួសារ ដើម្បីធ្វើយ៉ាងណាៗ ដើម្បីឲ្យយើងនឹងអាចមានលទ្ធភាពនៅក្នុងការឈរជើងដោយខ្លួនឯងបាន។ ប៉ុន្តែ មិនមានន័យថា យើងមិនមានការឈឺចាប់ទេ ។ ការឈឺចាប់នៅតែមាន។ ដូចខ្ញុំបាទបានលើកហើយថា ដោយសារតែបញ្ហាខ្វះខាត ធ្វើឲ្យយើងបង្ខំធ្វើការទាំងយប់ទាំងថ្ងៃ ។ បង្ខំធ្វើជម្នះការលំបាកផ្សេងៗ ដើម្បីធ្វើយ៉ាងណាដើម្បីបំពេញនូវតម្រូវការរស់នៅប្រចាំថ្ងៃ ។ ដោយសារការខ្វះខាតអ៊ីចឹងបញ្ហាឈឺចាប់អាចទុកនៅមួយឡែក ។ អ៊ីចឹង នៅពេលដំណាក់កាលណាមួយដែលជីវភាពរស់នៅអាចកើនឡើងវិញ ស្ថានភាពបានស្ងប់ស្ងាត់ឡើងវិញ អាការឈឺចាប់នុ៎ង វានឹងកើតមានឡើងវិញ ចំពោះជនរងគ្រោះដែលខ្ញុំបាទលើកព្រឹកមិញច្រើនដងហើយថា មានជនរងគ្រោះជាច្រើន ដែលគាត់គិតថាក្រោយពីមានបញ្ហាហើយ ក្រោយពីបានរស់នៅសុខស្រួលហើយ បញ្ហាផ្លូវចិត្តនឹងកើតឡើង ។

ដូច្នេះ វាជាការលំបាកនៅក្នុងពេលបន្តិចទៅមុខទៀតដែលប្រទេសយើងទាំងមូលត្រូវ-- ដែលយើងត្រូវប្រឈមមុខទៅនឹងការដោះស្រាយបញ្ហាទាំងអស់នោះ បូករួមនឹងការរកយុត្តិធម៌ បូករួមនឹង

ការដោះស្រាយទៅនឹងការឈឺចាប់របស់ជនរងគ្រោះក្តី បូករួមនឹងជនជំនាន់ក្រោយក្តី ។ ដូច្នេះ ជាបន្ទុកធ្ងន់មួយ ដែលយើងទាំងអស់គ្នានឹងប្រឈមមុខ ។ ខ្ញុំមិនដឹងថា ខ្ញុំឆ្លើយនឹងសំណួរលោក ឬក៏យ៉ាងម៉េចទេ? ប៉ុន្តែលោកអាចបញ្ជាក់បន្ថែមទៀត ហើយសំណួរហាក់ដូចជាវែង ដូច្នេះខ្ញុំអាចបាត់ខ្លះ ។

**ស៖** សូមថ្លែងអំណរគុណលោកយ៉ាងជ្រាលជ្រៅ ចំពោះជំនាញរបស់លោកដែលបានរៀបរាប់នៅទីនេះ និងសក្ខីកម្មរបស់លោក ហើយខ្ញុំជឿថា នៅក្នុងទីនេះហើយដែលយើងព្យាយាមរកនិងបំពេញការងារសម្រាប់ប្រទេសកម្ពុជាទាំងអស់គ្នា ។ សូមអរគុណលោកច្រើន ។

**លោក ហុង គឹមសួន៖**

សូមអនុញ្ញាត លោកប្រធានជម្រាបបន្តិច ដោយសារអម្បាញ់មិញ ខ្ញុំបាទមិនចង់កាត់នូវសំណួរចម្លើយរបស់លោកមេធាវីការពារក្តីជាតិ ដែលគាត់លើកឡើងថា ជនរងគ្រោះសុទ្ធតែបានដឹង ។ ខ្ញុំបាទសូមអនុញ្ញាតកែពាក្យថា សុទ្ធតែបានដឹងអំពីលោក ឌុច ទទួលបញ្ជាពីថ្នាក់លើ ។ ត្រង់នេះ ខ្ញុំបាទសូមជម្រាបថា ជនរងគ្រោះទាំងអស់មិនបានដឹងទេ គ្រាន់តែឮលោក ឌុច មានប្រសាសន៍នឹងមែន ។ សូមកែអ៊ីចឹងបាទ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវជាចុងក្រោយនេះ អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវបទបង្ហាញរបស់អ្នកជំនាញរូបនេះ អំពីហេតុផលទាំងឡាយនៃស្ថានភាពជនរងគ្រោះ ឬក៏ជំងឺផ្លូវចិត្តរបស់ជនរងគ្រោះ ដែលកើតមានពីមុនរហូតដល់បច្ចុប្បន្ន និងទិដ្ឋភាពនានាដែលមានការពាក់ព័ន្ធទៅនឹងផលវិបាកដែលកើតឡើងចំពោះជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យបន្សល់ទុកនៅក្នុងសង្គមកម្ពុជា។ សូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ដំបូងខ្ញុំសុំមានមតិពីរបីម៉ាត់អំពីស្នាដៃរបស់បណ្ឌិត ឈឹម សុធារ៉ា ។ ខ្ញុំអត់មានការយល់ដឹងខាងចិត្តសាស្ត្រជ្រាលជ្រៅទេ ។ ក៏ប៉ុន្តែ ខ្ញុំស្តាប់ស្នាដៃរបស់លោក ។ ខ្ញុំគិតថា ជាស្នាដៃមួយល្អប្រសើរ ដែលថាល្អប្រសើរ ព្រោះឈរនៅលើទ្រឹស្តីវិទ្យាសាស្ត្រសុទ្ធសាធដើម្បីបកស្រាយប្រាសចាកការលម្អៀងទៅតាមគតិផ្ទាល់ខ្លួន ។

នេះខ្ញុំសូមមានមតិប៉ុណ្ណោះ អំពីស្នាដៃរបស់លោកបណ្ឌិត ឈឹម សុធារ៉ា ។ ទន្ទឹមនេះ ខ្ញុំក៏សូមគោរពដល់លោកបណ្ឌិតដែរ គោរពដោយស្មោះ ។

[១២:១៥:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំសូមអនុញ្ញាតឆ្លើយទៅលោក ហុង គឹមសួន តែមួយម៉ាត់ទេ តែមួយឃ្លាទេ ដែរខ្ញុំនិយាយថា “សុទ្ធតែបានដឹង” ពីព្រោះក្នុងចំណោមសាក្សីទាំងអស់ គ្មានសាក្សីណាមួយបានឃើញតាឌុច ទៅធ្វើទារុណកម្ម ឬសម្លាប់អ្នកណាទេ ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ គ្មានដើមបណ្ដឹងរដ្ឋប្បវេណីណាមួយបានឃើញ តាឌុច ទៅសម្លាប់ ឬធ្វើទារុណកម្មអ្នកណាទេ ដែលខ្ញុំនិយាយថា “សុទ្ធតែបានដឹង” នោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវអ្វីៗទាំងអស់នេះជាសម្ដីរបស់ភាគី ហើយអង្គជំនុំជម្រះបានបង្កើតឡើងនូវប្រព័ន្ធនៃការកត់ត្រានូវប្រតិចារឹកនូវពាក្យពេចន៍ទាំងអស់ ហើយពាក្យពេចន៍ទាំងអស់នេះ ភាគីគឺអាចធ្វើការបូកសរុបនៅក្នុងសេចក្ដីសន្និដ្ឋានបិទការបញ្ចប់ការដេញដោល ដើម្បីអង្គជំនុំជម្រះយកទៅពិនិត្យពិចារណាសម្ដីភាគីម្ខាង មិនអាចភាគីមួយម្ខាងមកកែបានទេ អាចកំណត់សម្គាល់បាន មិនមែនកែតម្រូវសម្ដីរបស់អ្នកដទៃទេ ។ ប៉ុន្តែ ដោយសារតែពេលវេលាដូចជាវែងហើយ បានន័យថាលើសពីពេលវេលាដែលបានកំណត់រហូតដល់ដប់ប្រាំមីនុតហើយ វាប៉ះពាល់ដល់សាធារណជនជាច្រើន ដែលលោកបានអញ្ជើញមកចូលរួមនៅក្នុងដំណើរការនេះ ។

អ៊ីចឹង យើងយល់ថាគ្រាន់តែកែសម្រួលពីពាក្យថា កែពាក្យរបស់គេមកធ្វើការកត់សម្គាល់ នោះជាការត្រឹមត្រូវហើយ ។ សូមអញ្ជើញ លោកជនជាប់ចោទអាចធ្វើការកត់សម្គាល់បន្ត ។

[១២:១៧:២៨]

**ជនជាប់ចោទ៖**

តទៅទៀត ខ្ញុំបាទសុំនិយាយអំពីការយល់ឃើញរបស់ខ្ញុំបាទ ។ តាមការយល់ឃើញរបស់ខ្ញុំបាទ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាពិតជាចាប់កំណើតក្រោយថ្ងៃ១៧ មេសា ១៩៧៥ មែន ។ តែវាចប់ទាំងស្រុងនិងជាស្ថាពរនៅថ្ងៃ៦ មីនា ១៩៩៩ គឺថ្ងៃដែល តាម៉ុក ត្រូវចាប់យកមកដាក់មន្ទីរឃុំឃាំងរង់ចាំការកាត់ក្តីទោស ។

តទៅទៀត ខ្ញុំសូមនិយាយអំពីបច្ច័យនៃរបបប្រល័យពូជសាសន៍ (អ៊ំ សូមទោស) បច្ច័យនៃរបបឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បច្ច័យនេះធំធេង គ្រប់ផ្នែក ដូចលោកបណ្ឌិត ឈឺម សុធារ៉ា លោកមានប្រសាសន៍អ៊ីចឹង ហើយយូរអង្វែង ដល់ឥឡូវនេះក៏ទាន់ចប់ដែរៗ ។ ដូច្នេះ និក្ខេបបទរបស់លោកបណ្ឌិត ឈឺម សុធារ៉ា បង្ហាញឲ្យឃើញផ្នែកនេះ ផ្នែកនោះ សព្វគ្រប់ទាំងអស់ ។ ខ្ញុំទទួលស្គាល់ថា ជាការស្រាវជ្រាវប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ។ ដោយឡែកខ្ញុំជាអ្នកទទួលខុសត្រូវនៅមន្ទីរស-២១ ក្នុងឋានៈជាប្រធាននៃយន្តការឧក្រិដ្ឋនេះ ខ្ញុំនៅតែតាំងចិត្តដាច់ខាតថាទទួលខុសត្រូវគ្រប់ឧក្រិដ្ឋកម្មទាំងអស់ ដែលកើតមាននៅស-២១ ទាំងខាងផ្លូវច្បាប់ ទាំងខាងផ្លូវចិត្ត ។

ទីពីរ ខ្ញុំបាទ កាំង ហ្កេកអ៊ាវ ហៅ ឌុច មិនមែនជាអ្នកទទួលខុសត្រូវលើមន្ទីរសន្តិបាលទូទាំងប្រទេសទេ ក៏ប៉ុន្តែខ្ញុំបាទជាបក្ខជនម្នាក់របស់បក្សកុម្មុយនីស្តកម្ពុជា ។ ខ្ញុំនៅតែទទួលខុសត្រូវខាងផ្លូវចិត្តលើឧក្រិដ្ឋកម្មទាំងអស់ទៅលើជាតិប្រជាជនកម្ពុជាគ្រប់រូបក្នុងរបបនោះ ជាតិប្រជាជនកម្ពុជាធ្វើខ្ញុំយ៉ាងម៉េចធ្វើចុះ ។

តទៅទៀត ខ្ញុំសូមនិយាយអំពីបញ្ហាជាក់ស្តែងខ្លះ ផ្ទាល់ខ្លួនខ្ញុំ នៅពេលដែលប្រឈមមុខនឹងជនរងគ្រោះ ស្ត្រីមេម៉ាយ កុមារកំព្រា ស្ត្រីមេម៉ាយច្រើនណាស់ដែលអញ្ជើញមកនៅទីនេះ ថ្កោលទោសខ្ញុំ ចង្អុលខ្ញុំ ខ្ញុំបានធូរចិត្តហើយ ។ ខ្ញុំបានដាក់ខ្លួនឲ្យអ្នកផងឃើញថា ខ្ញុំទទួលស្គាល់ទោសឧក្រិដ្ឋរបស់ខ្ញុំហើយ ។ តែសោកស្តាយដែរ ស្រីមេម៉ាយផ្សេងទៀតអត់បានមក ។ ឧទាហរណ៍ ដំបូងខ្ញុំគិតថា *ម៉ាដាម* ចៅ សេង លែងលោក ចៅ សេង បាត់ហើយ បានជាមិនបានមកដាក់បណ្តឹង ដើម្បីថ្កោលទោសខ្ញុំ ។ ដល់ឥឡូវខ្ញុំបានដឹងដំណឹងហើយថា ម៉ាដាមចៅ សេង នៅរស់ អត់លែងគ្នាទេ។ ក៏ប៉ុន្តែ លោកមិនបានដាក់បណ្តឹងមកទេ នេះមួយ ។

មួយទៀត អ្នកគ្រូខ្ញុំ តាន់ ប៉ូលីន មុនដំបូងគាត់ដាក់ឈ្មោះ តាន់ ប៉ូលីន ក្រោយ១៩៧៩ គាត់ប្រែឈ្មោះភ្លាម ឌីផុន ប៉ូលីន យកឈ្មោះប្តីគាត់យកទៅដាក់ ។ ប៉ុន្តែអត់ឃើញអ្នកបង ប៉ូលីន មកដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ដើម្បីចង្អុលមុខខ្ញុំ ខ្ញុំមិនដឹងជា អ្នកបងយល់យ៉ាងម៉េចទេ ទាំងពីរនាក់នេះ ។ ក៏ប៉ុន្តែខ្ញុំជឿដូចលោកបណ្ឌិត ឈឺម សុធារ៉ា លោកមានប្រសាសន៍អ៊ីចឹង សុទ្ធតែទទួលការប៉ះពាល់ខាងផ្លូវចិត្ត ។

ខ្ញុំសូមគោរព សុំទោសស្ត្រីមេម៉ាយទាំងអស់អំពីចម្ងាយ រួមទាំងម៉ាដាម ចៅ សេង រួមទាំងអ្នក តាន់ ប៉ូលីន ផង ឯចំណែកប្រពន្ធ រ័ត្ន គត់ ប្រហែលជាដាច់ពូជហើយ ។

ដោយឡែកកុមារកំព្រាមកដាក់ពាក្យបណ្តឹងនៅទីនេះច្រើនគួរសម ប៉ុន្តែក៏នៅខ្លះទៀតមិនបានមកថ្លែងក្នុងសវនាការទេ ។ ក៏ប៉ុន្តែ មានអ្នកមិនដាក់ពាក្យមក បើតាមខ្ញុំប្លូកសរុបដប់នាក់ហើយ ដប់នាក់ហើយ គេអត់ដាក់ពាក្យបណ្តឹងមកទេ ។ ដាក់ពាក្យបណ្តឹង ឬមិនដាក់បណ្តឹង ខ្ញុំនៅតែទទួលខុសត្រូវ ឱនកាយទទួលស្តាប់ ហើយនៅតែជឿថា គេទទួលឥទ្ធិពលអាក្រក់ខាងផ្លូវចិត្ត ដូចលោកបណ្ឌិត ឈឹម សុធារ៉ា លោកមានប្រសាសន៍អ៊ីចឹង ។ នេះជាឧក្រិដ្ឋកម្មមួយដែលទាមទារពេលវេលាយូរណាស់ ដើម្បីដោះស្រាយ ។

ដូច្នេះសរុបមកស្នាដៃជានិក្ខេបបទរបស់ដុកទ័រ ឈឹម សុធារ៉ា ខ្ញុំអត់អីប្រកែកប្រណាំងទេ ទទួលស្គាល់ថា ជាស្នាដៃវិទ្យាសាស្ត្រ ។ សូមគោរព ហើយសូមគោរពបងប្អូនទាំងអស់ ដែលនៅទីនេះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍មានផ្លាស់ប្តូរ ដូរនូវ ឌីវីឌី (DVD) រួចរាល់ គឺរាយការណ៍ប្រាប់យើងវិញ ។

*(ផ្នែកបច្ចេកទេស អេ.វី ផ្លាស់ប្តូរ ឌីវីឌី)*

[១២:២៤:២៨]

**ប្រធានអង្គជំនុំ៖**

លោកវេជ្ជបណ្ឌិត អង្គជំនុំជម្រះអរគុណដល់លោកវេជ្ជបណ្ឌិត ដែលបានអញ្ជើញចូលរួមនៅក្នុងដំណើរការនៃនីតិវិធីរបស់តុលាការតាមការអញ្ជើញ ។ ហើយសេចក្តីថ្លែងការណ៍របស់លោកពាក់ព័ន្ធជាមួយនឹងស្ថានភាពនៃផ្លូវចិត្តរបស់ជនរងគ្រោះ និងផលប៉ះពាល់នៃស្ថានភាពនានាចំពោះជនរងគ្រោះដែលសល់ពីរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺមានតម្លៃធំធេងសម្រាប់ដល់អង្គជំនុំជម្រះ ដើម្បីយកទៅពិចារ-ណាថ្លឹងថ្លែងនៅក្នុងការពិចារណាសម្រេចរឿងក្តីនេះ ប្រកបដោយភាពត្រឹមត្រូវយុត្តិធម៌ ។

ឥឡូវនេះដំណើរការសវនាការសម្រាប់ព្រឹកនេះឃើញថាដល់ទីបញ្ចប់ហើយ ហើយអាចមានការលើសនៅពេលផង ត្រូវសម្រាប់ពិសារថ្ងៃត្រង់ ហើយសូមអធ្យាស្រ័យដែរដោយសារពេលវេលាខ្លី គឺមិនគប្បីទុកពេលនោះ ហើយធ្វើឱ្យចប់ ។ ហើយដំណើរការសវនាការនៅរសៀលនេះ យើងនឹងលើកទៅបន្តដំណើរការនៅរសៀលចាប់ពីម៉ោងមួយនិងសាមសិបនាទី ។

ហើយសូមជម្រាបដល់ភាគីនិងសាធារណជនថា នៅរសៀលនេះ អង្គជំនុំជម្រះនឹងស្តាប់ការជំទាស់របស់មេធាវីការពារក្តីចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងស្តាប់នូវការឆ្លើយតបពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការជំទាស់នោះ ។

ហើយអង្គជំនុំជម្រះនឹងដំណើរពីម៉ោងមួយសាមសិបនាទី រហូតដល់ម៉ោងបីសាមសិបនាទី ហើយអង្គជំនុំជម្រះនឹងសម្រាកត្រឹមម៉ោងបីសាមសិបនាទី ដោយហេតុថាកិច្ចរបស់អង្គជំនុំជម្រះ ដែលបានគ្រោងប្រជុំផ្ទៃក្នុងកាលពីម្សិលមិញត្រូវបានអាក់ខាន ដើម្បីធ្វើការប្រជុំពិភាក្សាដោះស្រាយបញ្ហាបន្ទាន់មួយចំនួន ដើម្បីណែនាំដល់ភាគីនៅក្នុងការចូលរួមដំណើរការនីតិវិធីសម្រាប់ពេលវេលាទៅសប្តាហ៍បន្ទាប់ទៀត ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ បន្ទប់សម្រាក ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:២៧នាទី ដល់ម៉ោង ១៣:៤០នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយដូចអ្វីដែលយើងបានជម្រាបជូនដំណឹងបញ្ជាក់បន្ថែមកាលពីព្រឹកមិញរួចហើយ ថានៅរសៀលនេះ អង្គជំនុំជម្រះនឹងស្តាប់នូវការជំទាស់របស់មេធាវីការពារក្តី ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងស្តាប់នូវការឆ្លើយតបពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះការជំទាស់នោះ ហើយអង្គជំនុំជម្រះនឹងស្តាប់ការជំទាស់ពីការឆ្លើយតប ចំពោះការជំទាស់នេះទៅវិញទៅមកឃើញថា ដើម្បីឲ្យដំណើរការប្រព្រឹត្តទៅបានល្អ គឺអង្គជំនុំជម្រះប្រគល់វេទិកានេះទៅមេធាវីការពារក្តី ដើម្បីបង្ហាញអំពីការជំទាស់របស់ខ្លួន ហើយការជំទាស់នេះ គឺយើងបង្ហាញជាទូទៅ ហើយនិងការបង្ហាញជាលក្ខណៈដោយឡែក ដើម្បីមានការពិភាក្សាជាក់លាក់ចំពោះករណីនីមួយៗ ។ សូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមអរគុណលោកប្រធាន ។ មេធាវីការពារបានចង្អុលបង្ហាញកាលពីថ្ងៃច័ន្ទ គឺយើងមានការជំទាស់មួយចំនួនពាក់ព័ន្ធទៅនឹងមូលហេតុនៃពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន គឺទាក់ទងទៅនឹងចំណុចពីរ ។ ទីមួយ គឺវានាំឲ្យមានការសង្ស័យអំពីថា មិនមានទំនាក់ទំនងសាច់ញាតិរវាង

ដើមបណ្តឹងរដ្ឋប្បវេណីហើយនិងជនរងគ្រោះ។ ចំណុចមួយទៀត គឺទាក់ទងទៅនឹងអវត្តមាននៃភស្តុតាង។ ភស្តុតាងដែលបង្ហាញថា ជនរងគ្រោះអាចនឹងត្រូវបានឃុំខ្លួននៅស-២១ ហើយកាលពីថ្ងៃច័ន្ទមុននោះ យើងបានបញ្ជាក់ពីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ។ សូមអនុញ្ញាតពីលោកប្រធាន ខ្ញុំនឹងពិនិត្យមើលបញ្ជីនេះម្តងមួយៗ ដែលថានីមួយៗនោះ គឺខ្ញុំនឹងមានសេចក្តីពន្យល់ខ្លីៗ ។

ជាបឋមនោះ មានដើមបណ្តឹងរដ្ឋប្បវេណីពីរ ក្នុងពាក្យសុំរបស់គាត់នោះ ដែលនាំឲ្យមានចំណុចនេះឯង ថាដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនមានទំនាក់ទំនងសាច់ញាតិអ្វីសោះជាមួយនិងជនរងគ្រោះ ដែលគេបានបញ្ជាក់ក្នុងពាក្យបណ្តឹងនោះ ។ ដូច្នេះហើយ មេធាវីការពារសូមយោងទៅ E2/22 ដែលក្នុងនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់អំពីការចាប់ខ្លួនជាទូទៅនៅកងពល៧១០ ដែលគាត់នៅក្នុងនោះ ដែលជាអតីតយោធាខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យបណ្តឹងទាក់ទងទៅដែលថាជាមិត្តភក្តិរបស់គាត់ទេ ។ ហើយនៅទីនេះ មិនមានទំនាក់ទំនងសាច់ញាតិឲ្យឃើញច្បាស់នោះទេ ។ ហើយក៏ដូចគ្នាដែរ ចំពោះ E2/37 ពីព្រោះថាដើមបណ្តឹរដ្ឋប្បវេណីបានទាមទារថា មានមិត្តភក្តិចំនួនប្រាំមួយនាក់ ដែលត្រូវបានចាប់ខ្លួន ហើយនិងសម្លាប់នៅស-២១ ។ ហើយមេធាវីការពារសូមបញ្ជាក់ថា មិនឃើញមានទំនាក់ទំនងសាច់ញាតិនៅទីនេះទេ ។ ដូច្នេះ ធ្វើឲ្យយើងកំណត់ថា ដើមបណ្តឹងរដ្ឋប្បវេណីនោះ វាប្រាកដមិនអាចទទួលយកបាន ។

[១៣:៤៤:២៧]

បញ្ហាទាក់ទងទៅនឹងសាច់ញាតិលោហិតយើងនេះ គឺជាបញ្ហាសំខាន់ចំពោះពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៀតនោះគឺ E2/66 ដើម្បីបណ្តឹងរដ្ឋប្បវេណីនៅទីនេះ ក៏បានចង្អុលបង្ហាញថា បងស្រីរបស់គាត់ គឺ តេង សុភាព គឺថាអាចនឹងត្រូវបានឃុំខ្លួននៅទួលស្លែង ។ អ៊ីចឹងយើងពិនិត្យឃើញថា ទំនាក់ទំនងសាច់ញាតិរបស់គាត់ និងជនរងគ្រោះនោះ គឺមិនបានបង្ហាញភស្តុតាងឲ្យច្បាស់ទេ ពីព្រោះថា នៅពេលមេធាវីការពារពិនិត្យមើលលើឯកសារក្នុងសំណុំរឿងទៅ យើងរកឃើញថា ជនរងគ្រោះដែលគាត់បានលើកឡើងនោះ ឈ្មោះ តេង សុភាព គឺជាកូនរបស់ វន វ៉េត ។

ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលអះអាងថា ជាកូនរបស់ មុំ ប៉េង ហើយនិង តាំង ឈីន នោះ គឺយើងកត់សម្គាល់ឃើញថា ទំនាក់ទំនងសាច់ញាតិនៅទីនេះ គឺមិនត្រូវទេ ។ ហើយក៏ដូចគ្នានេះដែរ ទំនាក់ទំនងរឿងសាច់ញាតិនេះ យើងអាចលើកឡើងអំពីដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលខ្ញុំនឹងជម្រាបជូនដូចខាងក្រោមនេះ ដែលថា ដែលយើងពិនិត្យទៅឃើញថា ពួកគេមិនមានភស្តុតាងនៅក្នុង

សំណុំរឿង ឬមិនមានភស្តុតាងគ្រប់គ្រាន់នៅក្នុងសំណុំរឿងដែលអនុញ្ញាតឲ្យយើងចាត់ទុកថា ជនរងគ្រោះពិតជាបានឃុំខ្លួននៅស-២១ នោះទេ ។ ដូច្នេះហើយ ក្នុងដើមបណ្ដឹងរដ្ឋប្បវេណីដូចខាងក្រោមនេះ គឺ D25/15 ដែលជាលើកឡើងបងប្អូនប្រុសបីនាក់ ដែលទាក់ទងទៅនឹងការឃុំខ្លួននៅស-២១ ប៉ុន្តែមិនមានអ្វីនៅក្នុងសំណុំរឿង ដែលអនុញ្ញាតឲ្យយើងបញ្ជាក់ពីអង្គហេតុនេះ ដែលថា ទំនាក់ទំនងរវាងដើមបណ្ដឹងរដ្ឋប្បវេណីនិងជនរងគ្រោះទេ ហើយមិនមានឯកសារអ្វីក្រៅពីប្រវត្តិរូបទេ ។ ទាក់ទងនឹង ប៊ុង អ៊ឹម ដែលបានចងក្រងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអនុញ្ញាតឲ្យយើងថា ជនរងគ្រោះ គឺត្រូវបានឃុំខ្លួននៅស-២១ នោះ ។ ដូច្នេះ យើងជឿ ដូចគ្នានេះផងដែរ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដូចខាងក្រោមនេះ E2/30 ដែលបានបញ្ជាក់ថា មានបងប្អូនប្រុសពីរនាក់ ។ នៅកន្លែងនេះ ក៏មិនមានឯកសារផ្លូវច្បាប់ណាមួយ ដើម្បីគាំទ្រពីសាច់ញាតិ ទំនាក់ទំនងសាច់ញាតរបស់គាត់ទេ ។ ហើយមិនមានឯកសារណាមួយដែលបង្ហាញភស្តុតាងថា ជនរងគ្រោះត្រូវបានជាប់ឃុំនៅស-២១ ទេ ។

[១៣:៤៧:២០]

ដូចគ្នាដែរ ចំពោះឯកសារ E2/38 ហើយនិង E2/41 ដែលនៅក្នុងនោះ ដើមបណ្ដឹងរដ្ឋប្បវេណីសន្និដ្ឋានថា ជីតារបស់គាត់ត្រូវបានសម្លាប់នៅទួលស្លែង ប៉ុន្តែមិនមានឯកសារអ្វីសោះ ដែលគាំទ្រការអះអាងរបស់គាត់នោះ ទាក់ទងទៅនឹងជីតារបស់គាត់ ដែលគាត់លើកឡើងនោះ ។ ហើយក៏មិនបានផ្ដល់ឯកសារអ្វីមួយទាក់ទងទៅនឹងចំណុចដែលថា ជីតារបស់គាត់ត្រូវបានឃុំខ្លួននៅស-២១ នោះដែរ ។ ដូច្នេះជីតារបស់នាង ឈ្មោះរបស់គាត់ គឺមិនមាននៅក្នុងបញ្ជីអ្នកទោសស-២១ នោះដែរ ហើយយើងមានសេចក្ដីសង្កេតដូចគ្នានេះដែរ ពាក់ព័ន្ធទៅនឹង E2/49 ដែលគាត់អះអាងថា ជាបងប្រុសរបស់គាត់ ប៉ុន្តែមិនមានទំនាក់សាច់ញាតិ ឬញាតិពន្ធទេនៅកន្លែងនេះ ហើយមិនមានភស្តុតាងដែលថា បងប្រុសរបស់គាត់ត្រូវបានគេឃុំខ្លួននៅស-២១ នោះដែរ ។

នៅកន្លែងនេះដែរ យើងសូមបញ្ជាក់ថា នៅក្នុងករណីនេះ ដូចជាករណីខាងដើមដែរ បងប្រុសរបស់គាត់នោះ មិនមានឈ្មោះនៅក្នុងបញ្ជីអ្នកទោសស-២១នោះទេ ។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយទៀត គឺE2/57 ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងនិងថា ប្អូនស្រីរបស់គាត់ត្រូវបានសម្លាប់នៅស-២១ ។ កន្លែងនេះ ក៏មិនមានឯកសារដែលបញ្ជាក់ពីទំនាក់ទំនងពីសាច់សារលោកហិតដែរ ហើយមិនមានឯកសារនៅក្នុងសំណុំរឿង ដូចគ្នានេះដែរនៅកន្លែងនេះ គឺថាឯកសារដែលគាត់មានតែមួយគត់នៅក្នុងសំណុំរឿងនោះ គឺមានតែជាភាសាអង់គ្លេស មិនមានជាភាសាបារាំង មិនមានជាភាសាខ្មែរទៀត ហើយមិនមាន

ឯកសារណាមួយដែលបង្ហាញឲ្យយើងជឿថា ប្អូនប្រុសរបស់គាត់ត្រូវបានសម្លាប់នៅស-២១ទេ ។ នៅក្នុងពេលនោះដូចគ្នាដែរ គឺថាបងស្រីរបស់គាត់ក៏មិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកទោសស-២១នោះដែរ ។

ដូចគ្នាផងដែរ ចំពោះដើមបណ្ដឹងរដ្ឋប្បវេណីដូចខាងក្រោមគឺ E2/63 នៅកន្លែងនេះ ក៏មិនមានទំនាក់ទំនងសាច់ញាតិ ឬក៏ញាតិពន្ធ មិនមានភស្តុតាងថា ជនរងគ្រោះត្រូវបានឃុំខ្លួននៅស-២១ ហើយឈ្មោះរបស់ជនរងគ្រោះក៏មិនមាននៅក្នុងបញ្ជីអ្នកទោសនោះដែរ ។ មួយទៀត E2/64, E2/65 នៅទីនេះផងដែរ យើងមិនមានឯកសារណាមួយ ដែលគាំទ្រថាឪពុកមាររបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេឃុំខ្លួននៅស-២១ ។ មិនមានឯកសារណាមួយនៅក្នុងសំណុំរឿងពាក់ព័ន្ធទៅនឹង E2/69, E2/70, E2/71, E2/73 នៅទីនេះផងដែរ យើងសូមបញ្ជាក់ថា ហើយខ្ញុំសូមទាញអារម្មណ៍អង្គជំនុំជម្រះថា នៅក្នុងនេះ ក្នុងសំណុំរឿង គឺថាមិនមានឯកសារជាភាសាបារាំងទេ ក្រៅតែពីសំបុត្រដែលតែងតាំងមេធាវីរបស់គាត់ ។

អ៊ីចឹង E2/74, E2/75, E2/76 ដែលនៅក្នុងដើមបណ្ដឹងរដ្ឋប្បវេណី បានបញ្ជាក់ថាបងប្រុសរបស់គាត់ជាអតីតទាហាន លន់ នល់ ត្រូវបានគេយកឃុំខ្លួន ហើយសម្លាប់នៅទួលស្លែង ហើយក្រៅពីអង្គហេតុដែលថា ដើមបណ្ដឹងរដ្ឋប្បវេណីមានឈ្មោះ ត្រកូលដូចជនរងគ្រោះនោះ គឺមិនមានឯកសារអ្វីនៅក្នុងសំណុំរឿង ដើម្បីបង្ហាញទំនាក់ទំនងសាច់ញាតិ ឬញាតិពន្ធដែលអាចធ្វើឲ្យគាត់ស្ថិតនៅក្នុងក្រុមគ្រួសារតែមួយទេ ។ ប៉ុន្តែនៅក្នុងសំណុំរឿង មិនមានឯកសារណាមួយ ដែលគាំទ្រថា ជនរងគ្រោះអាចនឹងត្រូវឃុំខ្លួននៅស-២១ទេ ។ ដូច្នេះហើយជនរងគ្រោះ មិនមានឈ្មោះនៅក្នុងបញ្ជីអ្នកទោសស-២១ ។

អ៊ីចឹងមួយទៀត E2/77, E2/81, E2/82 ហើយនៅទីបំផុត គឺE2/83 នៅទីនេះដូចគ្នាដែរ គឺមិនមានទំនាក់ទំនងសាច់ញាតិលោហិត ទៅនឹងជនរងគ្រោះ ហើយមិនមានភស្តុតាងបង្ហាញនោះដែរ ថាជនរងគ្រោះជាប់នៅស-២១ នោះ ។

[១៣:៥២:៤៣]

ចំពោះ E2/83 ដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយថា នៅឆ្នាំ២០០៨ គាត់បានរកឃើញរូបថតនៅទួលស្លែងរបស់ឪពុកមារគាត់ ប៉ុន្តែរូបថតនេះ មិនបានដាក់មកពីមុននៅក្នុងសំណុំរឿងទេ ។ អ៊ីចឹង ខ្ញុំត្រឡប់ទៅដើមបណ្ដឹងរដ្ឋប្បវេណីពីរ ឬបី គឺD25/20 នៅទីនេះ ក៏ដូចគ្នាដែរ ដោយហេតុថា ឯកសារនីមួយៗនៅក្នុងសំណុំរឿងនោះ យើងពិនិត្យឃើញថា យើងមានការលំបាកក្នុងការកំណត់ពីទំនាក់ទំនង

រវាងដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះ ហើយយើងមានពិបាកកំណត់ទំនាក់ទំនងថា ជនរងគ្រោះទៅនឹង ស-២១ ។

មួយទៀត E2/35 ប្រហែលជាខ្ញុំភ្លេចនៅពេលដែលកំណត់នៅក្នុងបញ្ជីនេះ ឃើញថាមិនមានភស្តុតាងទំនាក់ទំនងសាច់ញាតិរវាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងជនរងគ្រោះ ដែលថាជាក្មួយប្រុសរបស់គាត់នោះ ។ មិនមានឯកសារណាមួយ ដើម្បីគាំទ្រថា ក្មួយប្រុសរបស់គាត់ត្រូវបានជាប់ឃុំនៅស-២១ នោះទេ ។ មានតែនៅក្នុងឧបសម្ព័ន្ធនៃពាក្យបណ្តឹងរបស់គាត់ ដែលថាមានរូបថតជនរងគ្រោះ ប៉ុន្តែយើងមិនដឹងថា ជននេះពិតជាក្មួយរបស់គាត់មែន ឬមិនមែននោះទេ ។ ដូច្នេះហើយយើងបានពិនិត្យឃើញថា រូបថត ប៉ុន្តែមិនមានឈ្មោះនៅលើរូបថតនោះទេ ។ អ៊ីចឹងហើយ E2/62 ជនដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា បងប្អូនប្រុសពីរនាក់របស់គាត់ជាជនរងគ្រោះ ប៉ុន្តែមិនឃើញថា មិនមានទំនាក់ទំនងសាច់ញាតិជាមួយនិងដើមបណ្តឹងរដ្ឋប្បវេណី ហើយក៏មិនមានឯកសារផ្សារភ្ជាប់ទៅនឹងស-២១ ។ ហើយយើងមិនភស្តុតាងគ្រប់គ្រាន់ដែលអនុញ្ញាតឲ្យយើងគាំទ្រទំនាក់ទំនងនេះ រវាងដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះ ដើម្បីដាក់ជូននៅតុលាការ ដែលថាត្រូវដាក់រូបថតជូនអង្គជំនុំជម្រះ ដែលថាខ្លួនទទួលរូបថតនោះពីស-២១ ។

[១៣:៥៥:០៣]

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ដើមបណ្តឹងរដ្ឋប្បវេណីទាំងម្ភៃប្រាំមួយ ដែលមេធាវីការពារមានបំណងចង់តវ៉ាទាក់ទៅនឹងមូលដ្ឋាន ឬក៏ភាពអាចទទួលយកបាននៅក្នុងពាក្យបណ្តឹងរបស់គាត់នោះគឺដោយសារកង្វះនៃឯកសារដែលអនុញ្ញាតឲ្យមេធាវីជឿថា មានទំនាក់ទំនងសាច់ញាតិទៅនឹង ជនរងគ្រោះដែលបង្ហាញថាជនរងគ្រោះនោះ ដែលឈ្មោះរបស់គាត់ត្រូវបានឃុំខ្លួននៅស-២១ នោះ មែន ឬមិនមែន ។ នេះគឺជាសេចក្តីសង្កេតទាំងឡាយដែលមេធាវីសូមជម្រាបជូនអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមឲ្យមានការបំភ្លឺពីខាងមេធាវីការពារក្តី លោកស្រីបានលើកឡើងថា វាមានពីរប្រភេទការជំទាស់នោះ ហើយខ្ញុំហាក់ដូចជាមិនធ្លាប់ប្រើពាក្យថាជំទាស់នោះទេ ។ ហើយថា តើខ្ញុំចង់ដឹងលោកស្រីគិតថា នៅពេលដែលពុំមានភស្តុតាងគាំទ្រទៅលើទំនាក់ទំនងញាតិលោ-

ហិតនោះ គឺជាឧបសគ្គដែលមិនអាចឲ្យចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីឬក៏យ៉ាងម៉េច? ហើយថាតើការពុំមានអំពីភស្តុតាងដែលបង្ហាញអំពីការចោទប្រកាន់ទៅលើបទឧក្រិដ្ឋនោះ ថាតើចំណុចនេះយើងអាចថាវាមិនមានមូលហេតុដែលថា អាចឲ្យចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី? ខ្ញុំចង់ដឹងទៅលើចំណុចហ្នឹង។

បញ្ជីដែលលោកស្រីទើបតែលើកឡើងនេះ តើលោកស្រីបានបញ្ចូលការតវ៉ាដែលលោកស្រីបានលើកឡើងដែរឬទេ? ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់បានមកផ្តល់សក្ខីកម្មនៅទីនេះ ឬក៏វាពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលវានៅសល់តែប៉ុណ្ណោះ ។ គឺខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ទៅលើចំណុចនេះ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារេស៖**

សូមឲ្យខ្ញុំឆ្លើយនៅសំណួរទីពីរជាមុនសិន ។ ជាការពិតបញ្ជីដើមបណ្តឹងរដ្ឋប្បវេណីដែលខ្ញុំទើបតែផ្តល់ឲ្យនេះ គឺវាទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានការស្នើសុំឲ្យស្តាប់សេចក្តីថ្លែងរបស់គាត់ ។ មេធាវីការពារក្តីបានលើកឡើងកាលពីថ្ងៃច័ន្ទមុន និងពីសប្តាហ៍មុនហើយ ។ ហើយក៏បានបង្ហាញអំពីជំហររបស់ខ្លួនទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្តាប់រួចហើយនោះ ។ ហើយចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងស្តាប់គាត់នោះ ហ្នឹងគឺក្នុងបញ្ជីដែលខ្ញុំលើកឡើងអម្បាញ់មិញនេះ។

[១៣:៥៨:០០]

ហើយដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺយើងមិនបានរៀបគម្រោងស្តាប់គាត់នោះទេ ហើយចំពោះសំណួរទៅមួយវិញ ដើមបណ្តឹងរដ្ឋប្បវេណីប្រសិនបើគាត់មិនបានផ្តល់ភស្តុតាងអំពីទំនាក់ទំនងញាតិលោហិត ឬក៏សាច់ញាតិនោះទេ យើងចាត់ទុកថាពាក្យសុំរបស់គាត់មិនអាចទទួលយកបាន ដោយសារតែវាជាលក្ខខណ្ឌតម្រូវនៅក្នុងវិធានផ្ទៃក្នុងរបស់យើងដែលតម្រូវឲ្យផ្តល់ឯកសារទាំងអស់នោះ។ ហើយចំពោះជនរងគ្រោះដែលគាត់ពុំបានបង្ហាញ ឬក៏គាត់ពុំអាចបង្ហាញ ។ ហើយចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលគាត់អាចបង្ហាញអំពីចំណងសាច់ញាតិរបស់គាត់ជាមួយនឹងជនរងគ្រោះ មេធាវីការពារក្តីយល់ឃើញថាពាក្យសុំរបស់គាត់នោះក៏ពុំអាចទទួលយកបាន ។ ហើយជនរងគ្រោះ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីគាត់អាចយល់ខុសអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងជនរងគ្រោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក អាឡាំង វែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ លោកប្រធានជាទីគោរព លោក លោកស្រីចៅក្រម ដើម្បីឲ្យខ្ញុំអាចបំភ្លឺទៅលើចំណុចដែលលើកឡើងទាំងអស់នោះ ហើយខ្ញុំយល់ហើយថា តើយើងគួរតែដំណើរការយ៉ាងម៉េចទៅលើនីតិវិធីរបស់យើងខ្ញុំនិយាយនេះក្នុងនាមសហសេវិករបស់ខ្ញុំ ។ ហើយខ្ញុំព្យាយាមទៅលើការវាយតម្លៃទៅតាមករណីនីមួយៗ ហើយនិងការតវ៉ារបស់មេធាវីការពារក្ដីនៅក្នុងដំណាក់កាលនេះទាក់ទងទៅនឹងការមិនអាចទទួលយកបាននៃពាក្យសុំដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយខ្ញុំយល់ថា គឺខ្ញុំមិនតែឈរនៅទីនេះម្នាក់ឯងនោះទេ ដែលខ្ញុំនឹងលើកឡើងទៅលើបញ្ហានេះ ។ ហើយប្រសិនបើអាច ខ្ញុំអាចលើកឡើងនោះ គឺខ្ញុំសូមពេលបួនទៅប្រាំនាទី ដើម្បីបង្ហាញទៅលើចំណុចរបស់ខ្ញុំ ហើយសហសេវិករបស់ខ្ញុំក៏គាត់ចង់លើកឡើងទៅលើការការកត់សម្គាល់បឋមនេះផងដែរ ។ មុនពេលដែលយើងធ្វើការវាយតម្លៃទៅតាមពាក្យសុំនឹងករណីនីមួយៗ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ លោកប្រធានជាទីគោរព! ចំពោះភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី យើងឃើញមានចែងនៅក្នុងមាត្រាចំនួនពីរ ដែលវាមានចែងនៅក្នុងវិធានផ្ទៃក្នុង ។ វិធាន២៣ កថាខណ្ឌ៤ ហើយនិងវិធាន៨៣.១ ។ ប្រសិនបើយើងមើលវិធាន២៣.៤ នៃវិធានផ្ទៃក្នុង និង៨៣.១ នោះវាបានបង្ហាញនឹងចែងយ៉ាងច្បាស់លាស់នៅក្នុងវិធានទាំងពីរ ថាការវាយតម្លៃទៅលើការទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវលើកឡើងនៅក្នុងដំណាក់កាលសវនាការបឋម ហើយមិនអាចមានការបកស្រាយណាមួយយកទៅតាមវិធាន២៣.៤ និង៨៤.១ ដែលអនុញ្ញាតឲ្យបកស្រាយក្រៅពីនេះ នោះទេ ។ វិធាននេះគឺចែងច្បាស់ហើយទាក់ទងទៅនឹងការទទួលយកបាននៃពាក្យសុំដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើរសវនាការបឋម ។ ហើយយើងដឹងហើយថាសវនាការបឋមរបស់យើងធ្វើឡើងនៅថ្ងៃទី១៧-១៨ ខែកុម្ភៈ ឆ្នាំនេះ ហើយកាលវិភាគនោះបានធ្វើឡើងរួចហើយ ។

នៅក្នុងសវនាការបឋមនោះ ទាក់ទងទៅនឹងE2/36, E2/51 និង E2/69 បានពិភាក្សាយ៉ាងច្រើននៅក្នុងសវនាការបឋម អំពីអត្តសញ្ញាណរបស់ពាក្យសុំដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នោះ ហើយ

លោក លោកស្រីចៅក្រម បានចេញសេចក្ដីសម្រេចនៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០០៩ទាក់ទងទៅនឹងឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី E2/69, 36 នោះរួចហើយ ។

[១៤:០៣:៤១]

ហើយចំពោះពាក្យសុំ E2/36 នោះ គឺមិនអាចទទួលយកបាន គឺមានការចេញសេចក្ដីសម្រេចរួចហើយ ហើយយើងឃើញថាវានៅក្នុងវិធានផ្ទៃក្នុងវាមានភាពចន្លោះប្រហោង ប៉ុន្តែយ៉ាងក៏ដោយ គឺក៏វាមិនអាចមានលក្ខណៈផ្ទុយពីចំណុចនេះផងដែរ ។ ហើយចំពោះវិធាន១០០.១ គឺវាបានចែងយ៉ាងច្បាស់ផងដែរទៅលើករណីនេះ ដែលថានៅដំណាក់កាលណាដែលពាក្យសុំនោះមិនអាចទទួលយកបាន ។ ហើយលោក លោកស្រីចៅក្រម បានចេញសេចក្ដីសម្រេច ហើយក៏មានសិទ្ធិក្នុងការប្រកាសមិនអាចទទួលយកបាន ។ ប៉ុន្តែការផ្លាស់ប្ដូរនោះ គឺវាមិនអាចផ្ទុយទៅនឹងអង្គហេតុទាក់ទងទៅនឹងការតវ៉ារបស់ភាគីណាមួយចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ។ ហើយយើងមិនអាចតវ៉ានៅក្នុងដំណាក់កាលណាផ្សេង ក្រៅពីសវនាការបឋមនោះទេ ។ នៅពេលដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានប្រកាសថា មិនអាចទទួលយកបាននោះ គឺបានបើលទ្ធភាពឲ្យមានការប្ដឹងសារទុក្ខ។ ដូច្នេះដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើការប្ដឹងសាទុក្ខប្រឆាំងទៅនឹងសេចក្ដីសម្រេចនោះ ហើយគាត់អាចប្ដឹងទៅតុលាការកំពូលទៅលើករណីនោះ ។

[១៤:០៥:២៥]

ហើយកាលពីថ្ងៃច័ន្ទ អាទិត្យមុនមេធាវីការពារក្ដីគាត់បានជំទាស់ និងតវ៉ាទៅលើបញ្ហាហ្នឹង ។ ខ្ញុំមានប្រតិចារិកដែលបញ្ជាក់ទៅលើចំណុចហ្នឹង ចៅក្រម ឡាវ៉ែន៍ គាត់បានលើកឡើងអំពីបញ្ហាញាតិលោកហិត ហើយលោកចៅក្រម លើកឡើងថា វាទាក់ទងទៅនឹងភាពទទួលយកបានដែរឬទេ ឬក៏វាទាក់ទងទៅនឹងមូលហេតុផ្សេងៗទៅលើចំណុចនេះ ។ ហើយចៅក្រម ខាតវ៉ាយថ៍ ក៏បានឡើងឡើងទៅលើបញ្ហាទាំងអស់នោះផងដែរ ហើយយើងបានយល់ស្របទៅនឹងមេធាវីការពារក្ដីកានីហ្សារេស ដែលបានលើកឡើងថា បញ្ហាមិនអាចទទួលយកបាននោះ ។ ប៉ុន្តែយើងត្រូវផ្អែកទៅលើវិធានរបស់យើង ។

វិធាន២៣.២ នៃវិធានផ្ទៃក្នុងវាបានចែងអំពីបញ្ហាពុំអាចទទួលយកបាននៃពាក្យសុំ ហើយបានលើកឡើងថា ដើម្បីឲ្យពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្យសនកម្មត្រូវតែជាការខូចខាតខាងរាងកាយសម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទល្មើសជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតឡើងពិតប្រាកដមកទល់នឹងបច្ចុប្បន្ន ។ ហើយចំពោះបញ្ហាញាតិលោហិតនោះ

គឺសាច់ញាតិដែលគាត់បានលើកឡើងគឺវាមានចែងនៅក្នុងចំណុចពីរ ដែលថា បញ្ហានេះគួរតែលើកឡើងនៅក្នុងខែកុម្ភៈ មិនគួរលើកនៅក្នុងថ្ងៃនេះ ។

អ្វីដែលយើងនៅទីនេះ គឺចៅក្រម ឡាវែន៍ គាត់បានលើកឡើងហើយនៅក្នុងខែកុម្ភៈ ដែលវាបង្ហាញអំពីភាពជាក់ស្តែងរបស់យើង គឺជាការជំទាស់ទៅលើអង្គហេតុនឹងការឈឺចាប់ផ្សេងៗដែលជនរងគ្រោះទទួលរង ហើយបញ្ហានេះយើងគួរចោទសួរទៅលើចំណុចនេះមិនមែនទាក់ទងទៅនឹងបញ្ហាអាចទទួលយកបាននោះទេ ។ ដូច្នេះ ខ្ញុំគិតថាមេធាវីគាត់អាចពន្យល់បន្ថែម ហើយចំពោះបញ្ហាសង្កេតបឋមនោះ យើងត្រូវតែសុំទៅអង្គសវនាការនូវដំណាក់កាលមុន ។

យើងអាចស្នើសុំឱ្យអង្គសវនាការធ្វើការសម្រេចទៅលើបញ្ហាទាំងអស់នោះ ថាតើផ្អែកទៅលើវិធានផ្ទៃក្នុងមុនពេលដែលយើងធ្វើការបិទសេចក្តីដេញដោល ថាតើមេធាវីការពារក្តីគាត់នៅជំទាស់យ៉ាងម៉េចទៀតទៅលើដើមបណ្តឹងរដ្ឋប្បវេណីចំនួនម្ភៃប្រាំមួយដែលគាត់បានលើកឡើងនោះ ។

[១៤:០៨:០៩]

**ប្រធានអង្គជំនុំ៖**

មេធាវីក្រុមមួយខាងភាគីជាតិ តើមានមតិយោបល់អ្វីទេ បញ្ហានេះ? បញ្ហាលើកឡើងនូវការជំទាស់ទៅនឹងបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ហើយដែលលើកឡើងដោយមេធាវីអន្តរជាតិរួចហើយ ។

**កញ្ញា ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន! ទាក់ទងទៅនឹងចំណុចនេះ នាងខ្ញុំសូមធ្វើការគាំទ្រជាមួយនិងសហភាគារបស់ខ្ញុំដែលបានលើកឡើងអម្បាញ់មិញ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**លោក គង់ ពិសី៖**

សូមអរគុណលោកប្រធាន ហើយសូមគោរពលោកចៅក្រម និងលោកស្រីចៅក្រមជាតិ អន្តរ-ជាតិទាំងអស់ ។ ខ្ញុំបាទសូមធ្វើការឯកភាពជាមួយសហភាគារបស់ខ្ញុំ ។ សូមអរគុណ បាទ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីក្រុមបី ។

**លោកស្រី ហ្សាប៊ីយ៉ែន ទូស្សណាព្រូស៖**

លោកប្រធាន! គឺខ្ញុំយល់ស្របទាំងស្រុងតែម្តងជាមួយនឹងសេចក្តីសង្កេតដែលលើកឡើងដោយមេធាវី អាឡាំង វ៉ែនណឺ ហើយខ្ញុំគាំទ្រទៅលើការសង្កេតរបស់គាត់ ។ ហើយគឺយើង-- ខ្ញុំស្នើសុំទៅដេញដោលទៅលើបញ្ហានេះមុនពេលដែលយើងចូលទៅដល់បញ្ហាមួយទៀត ដែលវាកើតចេញពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីក្រុមប្អូន មានបញ្ហាអីទេ?

[១៤:០៩:៥៨]

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទក៏មានចំណុចតិចតួច។ ទីមួយ សូមគាំទ្រនូវការលើកឡើងរបស់លោកមេធាវី អាឡាំង វ៉ែនណឺ ។ ហើយទីពីរទៀត ខ្ញុំបាទ សូមជម្រាបលោកប្រធានថា ទាក់ទងជាមួយនឹងឯកសារ ដែលខាងមេធាវីការពារគាត់លើកឡើងថាមិនមានភស្តុតាងគ្រប់គ្រាន់នេះក៏មានការលើកឡើងអំពីជនជាប់ចោទ កាលពីចាប់ផ្តើមដំណើរការនីតិវិធីសវនាការផងដែរ ថាឯកសារនៅមន្ទីរស-២១ នេះ ចួនកាលមាន ចួនកាលបាត់បង់ ក្រោយពេលដែលឈ្មោះ អ៊ិន លន ហៅ ណាត ដែលប្រធាន ហើយលោក ឌុច គាត់កាន់កាប់តាមក្រោយ ។ អ៊ីចឹងពេលខ្លះលោក ឌុច ផ្ទាល់ គាត់ទទួលស្គាល់ថា មិនមានរូបថតតែគាត់ទទួលស្គាល់ ហើយខ្លះមានឯកសារ តែមិនមានអ្វីបញ្ជាក់ផ្សេងទៀត តែលោកដឹង លោកទទួលស្គាល់ ។ ដូច្នេះនៅត្រង់ចំណុចនេះ ទាក់ទងឯកសារភស្តុតាង ទាក់ទងជនរងគ្រោះដែលត្រូវឃុំខ្លួន ឬក៏ត្រូវបានយកទៅសម្លាប់នៅទីណាផ្សេងក្រៅពីស-២១ នោះ យើងមិនអាចរកឲ្យបានគ្រប់គ្រាន់ទេ ប៉ុន្តែដូចជារូបថត និងឯកសារក្នុងដើមបណ្តឹងរដ្ឋប្បវេណីលេខ E2/83 និង E2/64 គឺខ្ញុំបាទបានទាក់ទង ទៅជួបផ្ទាល់ហើយដែលគាត់នៅឆ្ងាយនៅខេត្តក្រចេះផងដែរគាត់ថា គាត់បានដាក់ជូនតាមរយៈអង្គភាពជនរងគ្រោះ ។

ដូច្នេះ បើសិនជាពេលនេះលោកប្រធានអនុញ្ញាត គឺយើងខ្ញុំនឹងស្វែងរកបន្ថែមទៀត ព្រោះការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីគាត់ថា បានដាក់មកហើយមានភ្ជាប់ទាំងរូបថតបងប្អូន ឬក៏សាច់ញាតិដែលបានឃុំខ្លួននៅមន្ទីរស-២១ ផងដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅខាងតំណាងសហព្រះរាជអាជ្ញាវិញ? បញ្ហាដែលលើកឡើងដោយភាគីមេធាវីការពារក្តី ហើយមានការឆ្លើយតបទៅនឹងបញ្ហា ដែលលើកឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមអម្បាញ់មិញនេះ ។ តើតំណាងសហព្រះរាជអាជ្ញាមានអ្វីត្រូវនិយាយដែរទេ? អញ្ជើញ ។

**លោក វាំងសង់ ដឺវាយដ៏ ដេស្មាឯល៖**

សូមអរគុណលោកប្រធានជាទីគោរព! នៅក្នុងដំណាក់កាលនេះយើងពុំមានសេចក្តីសង្កេតណាមួយនោះទេ លើកលែងតែបញ្ហាដែលវាតម្រូវឲ្យយើងធ្វើការដោះស្រាយសំខាន់ណាមួយ យើងនឹងធ្វើការសង្កេតទៅលើបញ្ហានោះ ។ ប៉ុន្តែ នៅពេលនេះយើងមិនទាន់មាននៅឡើយទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

[១៤:១៤:៤៨]

មេធាវីការពារក្តី តើមានអ្វីបន្ថែមទៅលើមតិលើកឡើងរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមដែរឬទេ? សូមអញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមធ្វើការសង្កេតមួយចំនួនតូច ។ ជាបឋមខ្ញុំកត់សម្គាល់ឃើញថា ហុង គឹមសួន លោក ហុង គឹមសួន បានលើកឡើងអំពីខ្លឹមសារសំខាន់នៃការដេញដោល ដែលនៅដំណាក់កាលដំបូងយើងបានលើកឡើងហើយ ។ ហើយយើងមិនអាចនិយាយថា ពាក្យសុំរបស់យើងមិនអាចទទួលយកបាន ហើយនិយាយទៅលើខ្លឹមសារនោះទេ ។

យើងបានលើកឡើងហើយដែលថា សេចក្តីសន្និដ្ឋានសង្កេតរបស់លោកមេធាវី គឺវាទាក់ទងទៅនឹងចំណុចមួយមិនត្រឹមត្រូវ ហើយខ្ញុំជឿថា កាលពីសប្តាហ៍មុន និងថ្ងៃច័ន្ទមុន អង្គសវនាការ គឺបានស្នើសុំពីខាងមេធាវីការពារក្តីឲ្យរៀបចំដើម្បីធ្វើការដាក់ការតវ៉ារបស់ខ្លួន។ ប្រសិនបើលោកមេធាវីមានការសង្កេតធ្វើឡើងនោះគួរតែលើកនៅថ្ងៃនោះមិន មែននៅថ្ងៃហ្នឹងទេ ។

អង្គសវនាការកាលពីអាទិត្យមុនមួយសប្តាហ៍ហើយ គឺឲ្យខាងមេធាវីការពារក្តីរៀបចំការដេញដោលទៅលើបញ្ហានោះនៅថ្ងៃនេះ ។ ហើយនៅពេលនោះមេធាវីមិនបានលើកឡើងនោះទេ ហើយនៅពេលនេះ គឺក្រោកឈរឡើង ដើម្បីតវ៉ាទៅលើបញ្ហានេះ ហើយលើកឡើងទៅលើខ្លឹមសាររបស់លោក ។

ហើយចំណុចទីពីរ ជាចំណុចចុងក្រោយដែរ វាទាក់ទងទៅនឹងសវនាការបឋម ដែលខ្ញុំសូមរំឭក

ឡើងវិញទៅលើករណីមួយចំនួន ដែលថា សំណុំរឿងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានទទួលយកបណ្ដោះអាសន្ន ហើយមេធាវីការពារក្ដីបានស្នើសុំថា រក្សាសិទ្ធិនឹងធ្វើការតវ៉ាទៅលើពាក្យសុំទាំងឡាយដែលបានទទួលយកបណ្ដោះអាសន្ន ។ ហើយយើងមិនមានលទ្ធភាពតវ៉ានៅពេលនោះ ហើយយើងរក្សាសិទ្ធិតវ៉ានៅពេលនេះ ។ នេះជាអ្វីដែលវាកើតឡើងនៅក្នុងនីតិវិធីរបស់យើង ។ ហើយប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនោះគាត់ចង់លើកឡើងនោះ លោកមេធាវីគួរតែលើកឡើងកាលពីសប្ដាហ៍មុន ។ ហើយយើងគួរតែ ប្រសិនជាបើយើងត្រូវការដោះស្រាយយើងត្រូវមើល ទៅលើប្រតិចារឹករបស់យើង ថាតើយើងបានសម្រេចអ្វីខ្លះនៅថ្ងៃសវនាការបឋម? កាលពីសប្ដាហ៍មុន ថ្ងៃច័ន្ទសប្ដាហ៍មុន មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីគាត់ថា គាត់នឹងជំទាស់ និងតវ៉ាហើយលើកឡើងនៅថ្ងៃអង្គារ ប៉ុន្តែគាត់មិនបានលើកឡើង ។ ហើយនៅពេលនេះគាត់បានលើកឡើងអំពីការតវ៉ារបស់គាត់ ។ ហើយមេធាវីការពារក្ដីនៅពេលនេះ គឺខ្ញុំស្នើសុំឱ្យធ្វើការពន្យូរសវនាការ ឬក៏ពន្យារសវនាការរបស់យើងចំពោះបញ្ហានេះ ហើយយើងពិចារណាទៅលើអ្វីដែលខ្ញុំបានលើកឡើងនេះ ។

[១៤:១៨:១៨]

**លោក អាឡាំង វែនណឺ៖**

លោកប្រធានខ្ញុំសូមធ្វើការឆ្លើយតបដោយខ្លីៗត្រង់ចំណុចនេះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក អាឡាំង វែនណឺ៖**

លោកប្រធាន លោក លោកស្រី ភាគីជាទីគោរព! ខ្ញុំចង់លើកចំណុចចំនួនបី ។

ចំណុចទីមួយ ខ្ញុំទទួលខុសត្រូវចំពោះដើមបណ្ដឹងរដ្ឋប្បវេណីសាមសិបប្រាំបីរូប ហើយខ្ញុំមិនធ្វើការទទួលខុសត្រូវដែលទាក់ទងទៅនឹងយោបល់របស់មេធាវីក្រុមផ្សេងនោះទេ ។ ដូច្នេះ ជំហររបស់ខ្ញុំគឺជាជំហរមួយផ្សេង ហើយជំហររបស់ខ្ញុំក៏មិនពាក់ព័ន្ធទៅនឹងជំហររបស់ក្រុមផ្សេងនោះដែរ ។ ហើយយើងឃើញថា សេចក្ដីសម្រេចពីដំបូង គឺមានលក្ខណៈច្បាស់លាស់ហើយ ។ ហើយយើងចាំហើយថាយើងមានចំណុចយល់ខុសគ្នានៅក្នុងអតីតកាល ។ ហើយកាលពីថ្ងៃច័ន្ទអាទិត្យមុន សហសេវិកមេធាវីការពារក្ដីប្រហែលជាមិនចាំទេ កាលពីថ្ងៃច័ន្ទអាទិត្យមុន គឺដើមបណ្ដឹងរដ្ឋប្បវេណីពុំទទួលបានឱកាសក្នុងការលើកឡើងនោះទេ ។ សហព្រះរាជអាជ្ញានិងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវបានទទួល

សិទ្ធិលើកឡើងទៅលើសេចក្ដីសង្កេត គ្រាន់តែជម្រាបឲ្យមេធាវីការពារក្ដីរៀបចំខ្លួនលើកសេចក្ដីសង្កេតរបស់គាត់ ។ ហើយយើងត្រៀមខ្លួន សម្រាប់លើកសេចក្ដីសង្កេតនៅថ្ងៃនេះ ហើយយើងបានធ្វើឡើងហើយ ។ ហើយនៅថ្ងៃនេះ គឺយើងបានបង្ហាញសេចក្ដីសង្កេតរបស់យើង ។

ហើយចំណុចដែលថា ការលើកខុស ឬក៏លើកខុសពេលវេលានោះ គឺជាអ្វីដែលខ្ញុំត្រូវតែពន្យល់នៅត្រង់ចំណុចនេះ ។ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំមានប្រតិចារឹកខែកុម្ភៈដែលខ្ញុំយកមកជាមួយ ។ មេធាវីការពារក្ដី ហ្វ្រង់ស្វ័រ រ៉ូ គាត់មានការចងចាំល្អណាស់ គឺគាត់បានរក្សាសិទ្ធិមួយចំនួន ប៉ុន្តែគាត់ គឺជាមេធាវីការពារក្ដី ដែលគាត់បានលើកឡើងទៅលើការរក្សាសិទ្ធិទាំងអស់នោះ ។ ហើយយើងគោរពតាមវិធានផ្ទៃក្នុង។ ដូច្នេះហើយផ្អែកទៅតាមវិធាននៅក្នុងវិធានផ្ទៃក្នុង គឺខ្ញុំសូមលើកឡើងថា មិនមានមូលដ្ឋានផ្លូវច្បាប់ណាមួយ ដែលអាចអនុញ្ញាតឲ្យមេធាវីការពារក្ដីជំទាស់អំពីការទទួលយកបាន ជាជាងការមិនទទួលយកបាននៃពាក្យសុំនោះទេ ។

ដូច្នេះ វាមិនអាចឲ្យយើងយកវិធានផ្ទៃក្នុងមកបកស្រាយផ្សេងទេ ដោយសារតែយើងនៅក្នុងសវនាការត្រូវតែពន្យល់ឲ្យបានច្បាស់លាស់ថា តើមេធាវីគាត់យល់យ៉ាងម៉េចចំពោះលទ្ធភាពរបស់គាត់ដែលគាត់ត្រូវតវ៉ាទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលគាត់លើកឡើងនៅក្នុងថ្ងៃនេះ?

[១៤:២១:៣០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រ៉ូ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

ខ្ញុំសូមលើកដោយសង្ខេប ។ យើងផ្អែកទៅលើវិធានផ្ទៃក្នុង វិធាន១០០នៃវិធានផ្ទៃក្នុង ។ វិធាន១០០នោះ គឺនៅសវនាការបឋម ខ្ញុំបានបង្ហាញការព្យួរសិទ្ធិរបស់ខ្ញុំ ហើយតាមការយល់របស់ខ្ញុំនោះ គឺវាជាការព្យួរសិទ្ធិដែលត្រឹមត្រូវ ។ ហើយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី គឺគាត់ក៏បានលើកឡើងត្រឹមត្រូវដែរ គឺវិធាននេះអនុញ្ញាតឲ្យអង្គសវនាការធ្វើការសម្រេច អង្គចៅក្រមធ្វើការសម្រេច ហើយចំណុចនេះហើយដែលយើងបានធ្វើការរក្សាសិទ្ធិ ដើម្បីអនុញ្ញាត និងសូមឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេច ដោយផ្អែកទៅលើវិធាន១០០ ។

ដូច្នេះ ការតវ៉ារបស់លោកចំពោះវិធាន១០០ អ្វីដែលយើងបានលើកឡើងនោះ គឺមិនអាចទទួលយកបាន ហើយមិនត្រឹមត្រូវនោះទេ ។ ហើយយើងមានមូលហេតុត្រឹមត្រូវរបស់យើង ហើយយើង

ឆ្លើយតបទៅនឹងសំណើដែលស្នើសុំដោយអង្គជំនុំជម្រះ ។ ហើយសំណើនោះ គឺវាមានចែងនៅក្នុងវិធាន ១០០ ។ នេះជាអ្វីដែលយើងយល់។ ប៉ុន្តែ ចំពោះមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានច្រានចោលវិធាននេះ ហើយយកវិធាន ២៣ និង៨៤.១ មកធ្វើជាមូលដ្ឋានលើកទៅលើការសង្កេតរបស់ខ្លួន ។ ប៉ុន្តែ ទាំងអស់នោះ គឺជាការសម្រេចរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ។

ថ្ងៃនេះយើងខ្ញុំសូមជម្រាបថា យើងខ្ញុំឆ្លើយតបទៅនឹងសំណើរបស់អង្គសវនាការ ។ ហើយយើងនៅក្នុងពេលនេះលើកឡើង ទៅលើ-- ឆ្លើយតបទៅលើសំណើរបស់អង្គជំនុំជម្រះ ។ ហើយអង្គជំនុំជម្រះគឺមានអំណាចទាំងស្រុងទៅលើចំណុចទាំងអស់នេះ ហើយការសម្រេចទៅលើករណីទាំងអស់នេះ ។ យោងតាមវិធាន១០០ គឺអង្គជំនុំជម្រះមានអំណាចទាំងស្រុងក្នុងការសម្រេចទៅលើឋានៈ និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

**ប្រធានអង្គជំនុំ៖**

[១៤:២៤:០០]

អញ្ជើញលោក អាឡាំង វ៉ែនណឺ ហើយដូចជាអាចគួរតែត្រូវបានជាក់ច្បាស់ទម្តងនេះ ឬក៏លោកអាចងើបប៉ុន្មានដងទៀត?

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ អង្គជំនុំជម្រះមិនបានស្នើពីខាងមេធាវីការពារក្តីក្រៅតែពីការតវ៉ានោះទេ ។ ហើយខ្ញុំចង់ដឹងថា តើលក្ខណៈនៃការតវ៉ារបស់មេធាវីការពារក្តីនោះគឺជាអ្វី? គឺជាមូលហេតុ ឬក៏ការមិនទទួលយកបាន? ហើយដោយសារហេតុនេះហើយបានជាលោកចៅក្រមឡាវ៉ែន៍ កាលពីថ្ងៃច័ន្ទសប្តាហ៍មុនឱ្យ កានីហ្សារេស ឱ្យបង្ហាញអំពីលក្ខណៈនៃការតវ៉ានោះ ដោយសារតែលក្ខណៈនៃការតវ៉ា ។ ហើយមេធាវី កានីហ្សារេស បានបង្ហាញច្បាស់ហើយថា លក្ខណៈនៃការតវ៉ា គឺភាពមិនអាចទទួលយកបាន ។ ដូច្នេះហើយទើបយើងក្រោកឈរឡើងដោយផ្អែកទៅលើវិធានរបស់យើង ។ ហើយយោងតាមវិធានផ្ទៃក្នុងរបស់យើងលោកមិនមានសិទ្ធិក្នុងការលើកទៅលើការតវ៉ាបែបនោះទេ ។ ប្រសិនបើមេធាវីលើកឡើងទៅលើបញ្ហានោះ ចំពោះការតវ៉ាដែលមានលក្ខណៈបែបនោះ យើងប្រាកដជាមានជំហរផ្សេងពីអ្វីដែលយើងបានលើកឡើងការពីថ្ងៃមុននោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមឲ្យលោកបញ្ជាក់នូវចំណុចមួយ ប្រសិនបើអាចលោក អាឡាំង វ៉ែនណឺ លោកហាក់ដូចជា សេចក្តីសន្និដ្ឋាន និងការលើកឡើងរបស់លោក គាំទ្រដោយក្រុមរបស់លោក និងក្រុមផ្សេងទៀត នៅក្នុងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ នៅក្នុងនេះពេលនេះ គឺយើងបង្ហាញឃើញយ៉ាងច្បាស់ថា បញ្ហាចោទលើទំនាក់ទំនងសាច់ញាតិ ឬក៏បញ្ហាទាក់ទងទៅនឹងការឃុំខ្លួននោះ ថាតើលោកចង់និយាយថា អង្គសវនាការរបស់យើងពុំមានយុត្តាធិការពិចារណាទៅបញ្ហាទាំងពីរនេះ ឬក៏យ៉ាងម៉េច?

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកស្រីចៅក្រមដែលលោកស្រីសួរសំណួរមួយនេះ ។ ជាការពិត តាមអ្វីដែលខ្ញុំចាំនៅពេលដែលខ្ញុំដកស្រង់វិធាន១០០នោះ នៅពេលដែលធ្វើការសម្រេចនោះ មុនពេលដែលសម្រេចសាលក្រមនោះ លោក លោកស្រីចៅក្រម អាចមានសិទ្ធិក្នុងការសម្រេចទៅលើបញ្ហាដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយក្រុមរបស់ខ្ញុំ នៅពេលដែលយើងខ្ញុំមកទីនេះ ហើយឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ និងខាងមេធាវីការពារក្តី និងសហព្រះរាជអាជ្ញា យើងបានផ្តល់ការបញ្ជាក់ត្រឹមត្រូវ ហើយយើងបានបង្ហាញឯកសារក្នុងនាមក្រុមរបស់យើង ដោយសារតែយើងពិចារណាថា យើងត្រូវបានកោះហៅឲ្យមកជម្រាបមុខអង្គសវនាការ ។ ហើយកាតព្វកិច្ចភារកិច្ចរបស់យើងជាអ្នកពន្យល់ទៅលើបញ្ហានេះ ហើយតាមបង្គាប់របស់អង្គសវនាការ គឺបានឲ្យយើងបញ្ជាក់ ចង់ឲ្យយើងបញ្ជាក់ទៅលើបញ្ហាទាំងអស់នេះ ។

[១៤:២៧:៤៧]

ដូច្នេះហើយទើបយើងនៅទីនេះ យើងសូមបញ្ជាក់ថា អង្គជំនុំជម្រះគោរពតាមវិធាន១០០ ដោយត្រូវសួរទៅលើបញ្ហាទាំងអស់នេះ ។ ហើយយើងខ្ញុំ គឺយើងមិនមាននរណាបង្ខំយើងឲ្យដាក់ឯកសារនៅមុខអង្គសវនាការ ដើម្បីបង្ហាញអំពីទំនាក់ទំនងសាច់ញាតិនោះទេ ប៉ុន្តែនោះមិនមែនជាបញ្ហាចោទនោះទេ ។ បញ្ហាចោទនៅពេលនេះ គឺមេធាវីការពារក្តីគាត់បានត្រលប់ទៅរកចំណុចចាស់ ដែលថាវិធានផ្ទៃក្នុងរបស់យើងគឺមានចែងច្បាស់ហើយ ទៅលើករណីនោះ ។ ហើយចំណុចទាំងអស់នេះហើយ ដែលយើងតវ៉ាសាជាថ្មី ។ យើងមិនតវ៉ាទៅលើករណីដែលថា រហូតដល់ពេលចេញសាលក្រមនោះ អង្គជំនុំជម្រះគាត់មានសិទ្ធិធ្វើការចេញសេចក្តីសម្រេច ឬក៏ចោទសួរអំពីសំណួរផ្សេងៗទាក់ទងទៅនឹងការទទួល

យកបាននៃពាក្យសុំ ហើយភាគីគាត់អាចឆ្លើយតបទៅលើសំណួរទាំងឡាយដែលមាន ហើយខ្ញុំសង្ឃឹមថា ខ្ញុំឆ្លើយតបទៅលើចំណុចទាំងអស់នេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដូច្នេះ ក្រោយពីការសួរបញ្ជាក់ ទៅលើបញ្ជីដើមបណ្តឹងរដ្ឋប្បវេណី ដូចដែលមេធាវីការពារក្តីបានបង្ហាញថា ពាក្យសុំទាំងអស់នោះ ពុំមានទំនាក់ទំនងនឹងភស្តុតាងបង្ហាញអំពីសាច់ញាតិ ហើយនិងការពុំអាចទទួលយកបាន ។ ដូច្នេះហើយគឺលោក មិនអាចទទួលយកបានទៅលើចំណុចនេះ ឬក៏យ៉ាងម៉េច?

**លោក អាឡាំង វែនណឺ៖**

លោកស្រីចៅក្រមជាទីគោរព! ខ្ញុំយល់ទៅលើស្ថានភាពនេះ អង្គជំនុំជម្រះបានស្នើសុំឲ្យមេធាវីការពារក្តីបញ្ជាក់ឲ្យបានច្បាស់ថាតើការតវ៉ាមួយណាដែលគាត់មាន ហើយបើសិនមាននោះ ថាតើលក្ខណៈនៃការតវ៉ាហ្នឹងវាយ៉ាងម៉េច ទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

ប្រសិនបើលោក លោកស្រីចៅក្រមចង់ឲ្យខ្ញុំនិយាយឡើងវិញនៅក្នុងសវនាការខែកុម្ភៈ គឺមានការជជែករវាងចៅក្រម ឡាវែន៍ និងមេធាវី ហ្វ្រង់ស្វ័រ រូ ។ ចៅក្រម ឡាវែន៍ បានស្នើសុំ ហ្វ្រង់ស្វ័រ រូ ឲ្យលោក ហ្វ្រង់ស្វ័រ រូ បញ្ជាក់អំពីបញ្ហាទទួលយកបាននៃពាក្យសុំ ។ ហើយមិនមានការតវ៉ាបញ្ជាក់ណាមួយពីខាងមេធាវីការពារក្តីទេ ។ នេះក្នុងប្រតិចារឹកទំព័រ៤៦ គឺនៅក្នុងសវនាការខែកុម្ភៈ ។ មេធាវីហ្វ្រង់ស្វ័រ រូ គាត់បានលើកឡើងថា នៅដំណាក់កាលនោះ គាត់មិនមានការតវ៉ានោះទេ ហើយខ្ញុំមិនយល់ទៅលើចំណុចនោះ ហើយនិងការដែលគាត់ថាគាត់មិនមានការតវ៉ាទៅលើភាពមិនអាចទទួលយកបាន។ ហើយយើងដឹងហើយយោងតាមវិធានផ្ទៃក្នុងរបស់យើង គឺត្រូវគោរព និងដាក់ការជំទាស់ និងតវ៉ានៅពេលនោះ ។

[១៤:៣០:៤៨]

ហើយនៅពេលនោះ គឺអង្គសវនាការ បានធ្វើការសេចក្តីសម្រេចមួយចំនួនហើយ ហើយវាបើកផ្លូវឲ្យប្តឹងសារទុក្ខនោះទេ ។ ដូច្នេះហើយមេធាវីការពារក្តី គាត់មកថ្ងៃនេះ ហើយតវ៉ាទៅលើពាក្យសុំ ២៥,២៦ នោះ ចំណុចនោះ គឺវាបើកឲ្យមានចំណុចហ្នឹង វាបើកឲ្យមានការប្តឹងសារទុក្ខតាំងពីពេលមុនទៅតុលាការកំពូលពីរអាទិត្យ បន្ទាប់ពីមានការចេញសេចក្តីសម្រេចនៅពេលនោះ ។ ដូច្នេះហើយចំណុចនេះ មានន័យថា បើសិនជាគាត់លើកឡើងថា ពាក្យសុំរបស់យើងមិនអាចទទួលយកបាននោះ

ដូច្នេះយើងសូមនិយាយថា តាមវិធានផ្ទៃក្នុងគឺគាត់មិនអាចមានសិទ្ធិលើកឡើងចំណុចនេះនៅពេលនេះទេ គាត់ត្រូវតែលើកបញ្ហានេះ នៅក្នុងដំណាក់កាលសវនាការបឋម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ចំពោះខ្ញុំលោក អាឡាំង វ៉ែនណឺ លោកហាក់ដូចជាចង់ឲ្យអង្គសវនាការ ចាប់អារម្មណ៍ទៅភាគីទៅលើបញ្ហាមួយចំនួនទាក់ទងទៅនឹងការមិនទទួលយកបាននៃពាក្យសុំដែលមេធាវីមិនអាចធ្វើលើកឡើងទៅលើចំណុចនេះ វាគួរតែលើកឡើងនៅក្នុងដំណាក់កាលមុន ។

**លោក អាឡាំង វ៉ែនណឺ៖**

ប៉ុន្តែ តាមការជំទាស់របស់មេធាវីការពារ គឺថានៅថ្ងៃមុននោះ យើងនិយាយអំពី២៥,២៦ នៃដើមបណ្តឹងរដ្ឋប្បវេណី គឺបានលើកឡើងនៅក្នុងពេលសវនាការ ដោយសារថា អ្នកទាំងអស់នោះមិនទាន់បានបង្ហាញខ្លួននោះទេ ដូចថាវាមានការអង្កេតនៅពេលនោះ ប៉ុន្តែពេលនោះគេបានចង្អុលបង្ហាញថា មិនមានទំនាក់ទំនងសាច់ញាតិលោហិត ញាតិពន្ធនោះ គឺថាមិនមានធាតុផ្សំនេះ ធាតុផ្សំនោះ ឬក៏បញ្ហាមួយដែលថា វាកើតចេញពីអ្វីដែលកើតចេញមកពីការជំនុំសវនាការ ដែលថាមេធាវីការពារលើកឡើងនោះគឺថា បីអាទិត្យបន្ទាប់ពីការសវនាការនោះមិនបានជំទាស់ទេ ។ ប៉ុន្តែការជំទាស់គឺផ្អែកទៅលើការទទួលយកបាននោះ គឺថាត្រូវធ្វើឡើងនៅក្នុងខែកុម្ភៈ ។

ក្រុមរបស់ខ្ញុំគឺត្រូវតែបញ្ជាក់ពីមូលហេតុ និងអំពីទំនាក់ទំនងសាច់ញាតិលោហិត និងទាក់ទងតែរឿងដើមបណ្តឹងរដ្ឋប្បវេណី ហើយគាត់បានសម្រេចចិត្តមិនប្តឹងឧទ្ធរណ៍ទៅនឹងសេចក្តីសម្រេចនោះ ។ អ៊ីចឹងហើយដើម្បីឧទ្ធរណ៍ប្រឆាំងនឹងសំណើទាំងអស់នោះត្រូវតែកើតឡើងនៅខែកុម្ភៈ ។ ប៉ុន្តែ ឆ្លើយតបទៅនឹងបញ្ហានេះ គឺថាមិនមានអ្វីបានលើកឡើងនៅក្នុងសវនាការនេះដែលថា អាចនឹងបើកច្រកឲ្យមេធាវីការពារអាចនឹងជំទាស់ទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី២៦ ឬក៏២៥ ហ្នឹងទាក់ទងទៅនឹងការទទួលយកបាន ឬក៏មិនបាននោះ ដែលត្រូវតែលើកឡើងនៅក្នុងខែកុម្ភៈនេះវាហាក់ដូចជាយឺតពេកក្នុងការលើកឡើងពីបញ្ហានេះ ។

[១៤:៣៣:៥៥]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹងគឺថាសំណួរចុងក្រោយមួយ ប្រសិនបើអង្គជំនុំជម្រះសម្រេច បន្តស្តាប់ការលើកឡើងរបស់ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះ ថាតើលោកអាចបញ្ជាក់បានដូចម្តេច?

**លោក អាឡាំង វែនណឺ៖**

ដោយហេតុថា ខ្ញុំមិនមែនជាមេធាវីរបស់ក្រុមពីរ បី និងបួន នោះ ខ្ញុំសូមឆ្លើយក្នុងនាមក្រុមរបស់ខ្ញុំ យើងមានដើមបណ្តឹងរដ្ឋប្បវេណីដប់ដែលត្រូវបានជំទាស់តវ៉ាដោយមេធាវីការពារ ក្នុងក្រុមរបស់ខ្ញុំ គឺដើមបណ្តឹងរដ្ឋប្បវេណីដប់ ។ នៅក្នុងនោះ ប្រាំគឺយើងបានធ្វើការសិក្សាស្រាវជ្រាវ យើងមានឯកសារ ហើយយើងត្រៀមខ្លួនជាស្រេចនូវខណៈពេលណាមួយ ដើម្បីយើងចូលទៅដល់ខ្លឹមសារនៃការពិភាក្សាដេញដោល ។ ហើយខ្ញុំខ្លួនឯង ខ្ញុំនឹងមានសេចក្តីសង្កេតទាក់ទងទៅនឹងប្រាំទៀត អ៊ីចឹងថ្ងៃនេះយើងត្រៀមខ្លួនជាស្រេច ។ នៅពេលនេះ គឺអំណះអំណាងផ្លូវច្បាប់របស់ខ្ញុំគឺ សមស្រប យើងសូមស្នើឱ្យអង្គជំនុំជម្រះធ្វើសេចក្តីសម្រេចមុននឹងបន្តនីតិវិធីទៅអនាគតទៀត អ៊ីចឹងនោះ ។ ហើយសូមរក្សាសិទ្ធិនឹងធ្វើការអះអាងក្នុងពេលករណីមួយៗ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធានប្រហែលជាយើងត្រូវ ដែលថាមេធាវីការពារអាចនឹងផ្តល់មតិយោបល់ទៅលើបញ្ហាដែលខ្ញុំបានលើកឡើងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ។

**លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សណាព្រូស៖**

សូមអរគុណលោកប្រធាន ។ តាមពិតទាក់ទងទៅនឹងក្រុមទីបី យើងគាំទ្រទាំងស្រុង អំពីសំណើដែលបានលើកឡើង ដោយលោក អាឡាំង វែនណឺ ។ យើងមានជំហរដូចគ្នាពាក់ព័ន្ធទៅនឹងគោលជំហររបស់មេធាវីការពារនិយាយអំពីការភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណី នៃពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ហើយយើងក៏ត្រៀមខ្លួនជាស្រេចដើម្បីនឹងឆ្លើយសំណួររបស់អង្គជំនុំជម្រះទាក់ទងទៅនឹងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ។ ទាក់ទងទៅនឹងមូលហេតុ មូលដ្ឋាននៃការដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យើងមាន យើងអាចនឹងឆ្លើយភ្លាមនៅពេលដែលមានសំណួរ។ ហើយតាមពិតយើងនឹងមានសេចក្តីសង្កេតទូទៅជាបឋមមួយចំនួន ហើយនិងមានសំណើមួយចំនួនផងដែរនៅពេលនោះ ។ ប៉ុន្តែក្នុងខណៈនេះ ខ្ញុំជឿថា សំខាន់បំផុត យើងត្រូវដោះស្រាយបញ្ហាដែលបានលើកឡើងនេះ ហើយនិងបញ្ជាក់ថាតើមេធាវីការពារថ្ងៃនេះអាចតវ៉ាទៅនឹងភាពអាចទទួលយកបាននៃពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានឬមិនបាននោះ គឺថាមិនអាចទៅរួចទេ ពីព្រោះថាត្រូវបានលើកឡើងរួចហើយនៅក្នុងសវនាការបឋមនោះ ។

[១៤:៣៧:២០]

មេធាវីការពារនៅកាលនោះ គឺខ្លួនមានលទ្ធភាពនឹងជំទាស់នៅពេលនោះហើយ ។ ដូច្នេះ ខ្លួនបានទទួលរឿងក្ដីរួចហើយ ដែលថា កន្លងផុតមកពេលនេះ ដែលខ្លួនទៅជំទាស់ថាមិនមានអត្តសញ្ញាណប័ណ្ណ ។ល។ និង ។ល។ នោះគឺជាការកត្តាមួយដែលថា យើងនឹងបំភ្លឺទៅតាមហ្នឹង ។ ដោយយើងមានបញ្ហាទេអំពីបញ្ហានោះ អំពីរឿងពាក្យសុំនីមួយៗនោះ ។ អ៊ីចឹង ខ្ញុំគាំទ្រអ្វីដែលបានបញ្ជាក់ឡើងដោយមេធាវី អាឡាំង វែនណឺ នោះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន លោកស្រី លោកចៅក្រមម្ដងទៀត ។ ខ្ញុំបាទមេធាវី ហុង គឹមសួន តំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងក្រុមទីពីរ និងក្រុមទីបួន អ៊ីចឹងខ្ញុំបាទសូមធ្វើការកត់សម្គាល់ទាំងពីរក្រុមនេះតែម្ដង ។

ទីមួយ ថ្វីដ្បិតថាលោកមេធាវីបរទេស អាឡាំង វែនណឺ ជាតំណាងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្រុមមួយ គាត់ក្នុងនាមក្រុមរបស់គាត់ ប៉ុន្តែក្នុងនាមក្រុមពីរ និងក្រុមបួន នៅតែទទួលយក មានន័យថា ឯកភាពតាមការលើកឡើងរបស់គាត់ និងមេធាវីក្រុមបីផងដែរ ។ ហើយបើនិយាយឲ្យចំទៅទៀត ក្នុងនេះមិនមានកូនក្ដី ឬដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងក្រុមបួន ដែលត្រូវបានមេធាវីការពារជំទាស់ទេ។ អ៊ីចឹងបើនិយាយឲ្យខ្លី ខាងក្រុមបួន មិនមានបញ្ហាអ្វីទេ ។ សូមនិយាយតែពីក្រុមពីរតែប៉ុណ្ណោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីការពារក្ដី ។

[១៤:៣៩:១៧]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ដោយសារមេធាវី អាឡាំង វែនណឺ បានកត់សម្គាល់ហើយ ខ្ញុំមិនបានវត្តមានទេកាលពីថ្ងៃច័ន្ទមុននៅក្នុងសវនាការ ដោយហេតុថា ខ្ញុំត្រូវតែទៅប្រទេស *លីបាណង់* នៅពេលនោះ ។ ប៉ុន្តែ ខ្ញុំបានប្រើភ្នែកដើម្បីមើល ហើយនិងត្រចៀកដើម្បីស្ដាប់ នៅពេលដែលខ្ញុំនៅឆ្ងាយ ហើយខ្ញុំក៏បានយល់ដែរ សំណើដែលបានលើកឡើងដោយអង្គជំនុំជម្រះ គឺថាជាសំណើរបស់អង្គជំនុំ

ជម្រះ ។ ដូច្នេះលោកប្រធាន លោក លោកស្រីចៅក្រម ថ្ងៃនេះយើងមិនទាន់បានទទួលសំណើរបស់មេធាវីការពារដែលមានបំណងប្រកាសថា ច្រានចោល ឬក៏មិនអាចទទួលយកបាននូវដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ប៉ុន្តែថ្ងៃនេះគឺយើង យើងគ្រាន់តែបំពេញតម្រូវការ ដើម្បីឆ្លើយតបទៅនឹងសំណួមពរ ដែលលើកឡើងដោយអង្គជំនុំជម្រះ គឺសំណើនោះគឺសុំឱ្យបង្ហាញទៅតាមវិធាន១០០ នៃវិធានផ្ទៃក្នុង ។ អ៊ីចឹងហើយខ្ញុំគិតឃើញថា អង្គជំនុំជម្រះដោយបញ្ញាញាណរបស់ខ្លួន គឺថាបានសួរមកយើងនូវបញ្ហាមួយចំនួនទាក់ទងទៅនឹងពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ហើយអង្គជំនុំជម្រះក៏បានមានចេតនានឹងទទួលយកនូវសេចក្ដីសង្កេតរបស់មេធាវីការពារ និងរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនោះផងដែរ ។ ហើយយើងសង្កេតឃើញថា តាមពិតទោះបីជាមានការពិភាក្សា ច្រើនសប្ដាហ៍ហើយនោះក៏ដោយ ទាក់ទងទៅនឹងពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ដើមបណ្ដឹងរដ្ឋប្បវេណីមិនទាន់បានផ្ដល់នូវភស្តុតាងឱ្យគ្រប់គ្រាន់ ដើម្បីឱ្យមេធាវីការពារហ្នឹងអាចនឹងកំណត់ថា មានអាចទទួលយកបាន ឬក៏អង្គជំនុំជម្រះអាចសម្រេចថាគ្រប់គ្រាន់នោះទេ ។

ពេលនេះគឺថាយើងបានលើកឡើង អំពីសំណើរបស់អង្គជំនុំជម្រះថា ដើម្បីការវាយតម្លៃទៅតាមភស្តុតាងឯកសារដែលបានដាក់ជូនដល់អង្គជំនុំជម្រះ ដើម្បីនឹងអង្គជំនុំជម្រះធ្វើសេចក្ដីសម្រេច ដោយហេតុថា ករណីទាំងឡាយនោះ ដែលមេធាវីការពារក៏បានលើកឡើងដោះស្រាយទៅតាមសំណើរបស់អង្គជំនុំជម្រះ គឺមិនមែនដោយគំនិតផ្ដួចផ្ដើមរបស់យើងនោះទេ យើងគ្រាន់តែលើកឡើងជម្រាបជូនទៅតាមសំណើរបស់អង្គជំនុំជម្រះ ហើយអ៊ីចឹងសូមអង្គជំនុំជម្រះមេត្តាពិចារណាទៅលើអង្គហេតុ ដោយហេតុថាការលើកឡើងនេះ ករណីនេះមិនទាន់គ្រប់លក្ខណៈទាំងស្រុងទេគឺមិនពេញលេញ ហើយមេធាវីការពារយល់ថា ពាក្យសុំទាំងអស់នោះ គឺមិនមានមូលដ្ឋានគ្រប់គ្រាន់ ហើយមិនមានភស្តុតាងគ្រប់គ្រាន់នេះហើយជាសំណើដែលអង្គជំនុំជម្រះស្នើសុំឱ្យមាន ។ នេះជាមូលហេតុដែលខ្ញុំបញ្ជាក់ថា សេចក្ដីសង្កេតគឺជាប្រការគួរឱ្យចាប់អារម្មណ៍ណាស់ក្នុងដំណើរការនីតិវិធី ប៉ុន្តែយើងពិនិត្យឃើញទៅគឺថា មិនមានភស្តុតាង និងមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ បានជាអង្គជំនុំជម្រះស្នើបែបនេះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកផង ហើយបញ្ហាក៏មិនទាន់ច្បាស់លាស់ផង អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកសាមសិបនាទីរហូតដល់ម៉ោងបីនិងដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តដំណើរការសវនាការ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៤៦នាទី ដល់ម៉ោង ១៥:២៥នាទី ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយជាបន្តនេះដើម្បីឲ្យបានច្បាស់នូវដំណោះស្រាយពាក់ព័ន្ធជាមួយនឹងសេចក្ដីអត្ថាធិប្បាយរបស់មេធាវីការពារក្ដី និងសេចក្ដីអត្ថាធិប្បាយតបរបស់មេធាវីអ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងបញ្ហាដែលកើតឡើងមុននេះគឺអង្គជំនុំជម្រះសុំ-- ខ្ញុំប្រគល់ភារៈនេះទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីឆ្លើយតបដោយសារហេតុនៃភាសា វានាំឲ្យមានបញ្ហាមួយដែរ ដើម្បីងាយស្រួលនៅក្នុងស្ដាប់យល់អំពីបញ្ហានេះ ។

សូមអញ្ជើញ លោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណ លោកប្រធាន ។ ជាបឋម ខ្ញុំសូមឲ្យមានការបំភ្លឺអំពីសំណើដែលបានលើកឡើងដោយអង្គជំនុំជម្រះជូនមេធាវីការពារក្ដី គឺការស្នើរបស់អង្គជំនុំជម្រះ ។ ប្រហែលជាអាចជាបញ្ហាចំពោះការបកប្រែ គឺអង្គសវនាការអង្គជំនុំជម្រះមានបំណងស្នើសុំមេធាវីការពារក្ដីឲ្យផ្ដល់យោបល់អំពីបញ្ហាពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីឲ្យគាត់លើកបញ្ហានេះនៅក្នុងនីតិវិធី ។

ហើយបញ្ហានោះ វាពាក់ព័ន្ធទៅនឹងមូលដ្ឋាននៃការជំទាស់ និងការតវ៉ា និងការទទួលយកបាននៃពាក្យសុំ ។ ហើយយើងបានកត់សម្គាល់ឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណី គាត់បានលើកឡើងអំពីបញ្ហាសំណួរបឋមផ្សេងៗ ដែលមេធាវីការពារក្ដីគាត់មានសិទ្ធិក្នុងការតវ៉ាទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ។ ដូច្នេះហើយគឺយើងបានកត់សម្គាល់លើបញ្ហានេះ ។ ប៉ុន្តែយ៉ាងក៏ដោយ យើងមានបំណងដើម្បីឲ្យដំណើរការនេះមានភាពត្រឹមត្រូវនោះ ហើយនិងដើម្បីធានាទៅដល់ភាពដំណើរការឲ្យបានលឿន ។ យើងចង់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញអំពីយោបល់ និងសេចក្ដីសង្កេតរបស់ខ្លួន ដែលចំពោះយោបល់ និងសេចក្ដីសង្កេតរបស់មេធាវីការពារក្ដី ទាក់ទងទៅនឹងពាក្យសុំដើមបណ្ដឹងរដ្ឋប្បវេណី ។ ដូច្នេះហើយ គឺយើងនឹងស្ដាប់នូវយោបល់សេចក្ដីសង្កេតរបស់ដើមបណ្ដឹង

រដ្ឋប្បវេណីនៅថ្ងៃស្អែក ហើយឲ្យគាត់ពន្យល់ទៅលើចំណុចទាំងអស់នោះនៅពេលរួមគ្នាតែម្តង ចំពោះបញ្ហាទាក់ទងទៅនឹងសាច់ញាតិ និងការជាប់ទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ហើយយើងនឹងឿឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញអំពីយោបល់ ហើយនិងភស្តុតាងពាក់ព័ន្ធទៅនឹងទំនាក់ទំនងដែលកើតឡើងនៅស-២១ ។ ប៉ុន្តែ យើងចង់បញ្ជាក់ថា យើងនឹងចេញសេចក្តីសម្រេចរួមតែម្តងទៅលើបញ្ហាបឋមទាំងនោះ ដែលបានលើកឡើងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើអង្គសេចក្តីដែលមេធាវីការពារក្តីបានលើឡើង តាមសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ។

[១៥:៣០:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំគ្រាន់តែមានបំណងធ្វើការសង្កេតតែប៉ុណ្ណោះ ។ យើងបានទាញបានធ្វើការពិចារណាក្នុងពេលសម្រាក ហើយយើងបានយកប្រតិចារឹកនៅក្នុងសវនាការបឋម ហើយខ្ញុំសូមអញ្ជើញគ្រប់ភាគីទាំងអស់ និងអង្គសវនាការ ដោយគោរព ឲ្យធ្វើការពិនិត្យលើប្រតិចារឹកនៃនីតិវិធីរបស់យើងដែលបានកត់ត្រានៅក្នុងសវនាការបឋម ។

នៅក្នុងប្រតិចារឹកនោះបានចែងយ៉ាងច្បាស់លាស់ ថាតើអ្វីដែលបានផ្តល់ទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺជាការទទួលស្គាល់បឋមដែលបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយនៅពេលនោះយើងមានបញ្ហាទាក់ទងទៅនឹងការបកប្រែ ។ ហើយអង្គជំនុំជម្រះបានពិចារណាទៅលើវិធានផ្ទៃក្នុង ហើយនៅពេលនោះ អង្គសវនាការបានសម្រេចថាជាការទទួលស្គាល់បណ្តោះអាសន្ន ។ ហើយបន្ទាប់ពីនោះមកអង្គជំនុំជម្រះបានស្នើសុំឲ្យភាគីឲ្យដាក់សេចក្តីសង្កេត ហើយខ្ញុំសូមលើកឡើងសេចក្តីសង្កេតរបស់មេធាវីការពារក្តី ដែលលើកឡើងជាភាសាបារាំងនៅពេលនោះ ។

លោក លោកស្រីចៅក្រម ជាទីគោរព! និយាយជាទូទៅមេធាវីការពារក្តី មិនមានបំណងតវ៉ាទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ប៉ុន្តែមេធាវីការពារក្តី មានបំណងបញ្ជាក់ជូនអង្គសវនាការថា ចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន យើងខ្ញុំទទួលឯកសារតែភាសាជាអង់គ្លេសតែប៉ុណ្ណោះ ។ ដូច្នេះហើយដោយសារបញ្ហានេះ យើងខ្ញុំមិនមានលទ្ធភាពក្នុងការឆ្លើយតបដោយសារកង្វះ

ឯកសារបារាំង ។ ហើយពីរបីថ្ងៃមុន យើងបានទទួលឯកសារដែលយើងមិនអាចផ្តល់យោបល់បាន។ នេះជាអ្វីដែលយើងបានលើកឡើងនៅក្នុងសវនាការបឋម ហើយប្រសិនបើអង្គសវនការអនុញ្ញាតខ្ញុំបន្ថែមទៅលើចំណុចនេះ ។ កាលពីម្សិលមិញយើងបានទទួលឯកសារ ហើយអ្វីដែលយើងបាន និយាយនៅពេលនោះ គឺវាពាក់ព័ន្ធទៅនឹងករណីនេះ ។

ខ្ញុំសូមលើកឡើងបន្ត ចំពោះករណីមួយចំនួនបញ្ហាចោទអាចកើតឡើង ទាក់ទងទៅនឹងទំនាក់ទំនងដែលដើមបណ្តឹងរដ្ឋប្បវេណីមានការទាក់ទងទៅនឹងស-២១ ។ មេធាវីការពារក្តីមិនអាចនិយាយនៅដំណាក់កាលនេះបានទេ ដោយសារតែយើងពុំមានឯកសារជាភាសាបារាំង ។ ដូច្នេះ យើងមិនអាចដាក់សេចក្តីសន្និដ្ឋានបាន យើងសុំរក្សាសិទ្ធិរហូតដល់សវនាការលើអង្គសេចក្តីដើម្បីលើកបញ្ហានានា ដែលអាចលេចឡើង ហើយវាហាក់ដូចជាបង្ហាញថាដើមបណ្តឹងរដ្ឋប្បវេណីទាំងមួយចំនួនដែលគាត់ដាក់ពាក្យតាំងខ្លួននោះ មិនមែនជាជនរងគ្រោះនៅស-២១ ឬក៏មិនមានជាប់ពាក់ព័ន្ធតែម្តង ។ ហើយប្រសិនបើមានការបញ្ជាក់យ៉ាងច្បាស់លាស់ថាជាជនរងគ្រោះពីស-២១ នោះ មិនមានការតវ៉ានោះទេ ។ ហើយចៅក្រមឡាវែន៍ គាត់បានលើកឡើងថា លោកចៅក្រមចង់ឲ្យមានការបំភ្លឺ ថាតើមេធាវីការពារក្តីចង់លើកការព្យួរសិទ្ធិទៅលើបញ្ហានៃពាក្យសុំ ឬក៏ការទទួលយកបាននៃពាក្យសុំ ។ ហើយពេលនោះ ខ្ញុំតវ៉ា-- បានឆ្លើយតបថា មេធាវីការពារក្តីថាពិចារណាថាដើមបណ្តឹងរដ្ឋប្បវេណីមួយ គឺវាស្លាប់នៅស-២១ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំបានលើកឡើងថាវាទាក់ទងទៅនឹងភាពទទួលយកបាននៃពាក្យសុំតាំងខ្លួន ។ ហើយចៅក្រមឡាវែន៍ បានលើកឡើងថានៅដំណាក់កាលនេះ យើងហាក់ដូចជាយល់ច្បាស់ហើយ ដូច្នេះយើងមិនបាច់និយាយអំពីខ្លឹមសារនៃពាក្យសុំតាំងខ្លួននោះទេ ។ យើងគ្រាន់តែវាយតម្លៃទៅលើព្យសនកម្មដែលកើតឡើងតែប៉ុណ្ណោះបានហើយ ។

[១៥:៣៤:៥៧]

ចៅក្រម ឡាវែន៍ បានបន្តទៀតថា នៅក្នុងអំឡុងពេលនោះគឺក្នុងអំឡុងពេលដំណាក់កាលអង្គសេចក្តីគឺយើងត្រូវធ្វើការពិចារណា និងវិភាគទៅលើអង្គខ្លឹមសារនៃពាក្យសុំដើម្បីយល់អំពីព្យសនកម្ម ។ ដូច្នេះហើយ ទាក់ទងទៅនឹងបញ្ហាសង្ស័យណាមួយ គឺវាទាក់ទងទៅនឹងព្យសនកម្ម ហើយនៅពេលនោះយើងមិននិយាយអំពីភាពអាចទទួលបានទោះទេ ។ នៅពេលនោះខ្ញុំឆ្លើយតបថា ទាក់ទងទៅនឹងការទទួលយកបាននៃពាក្យសុំ ហើយផ្អែកទៅលើការទទួលស្គាល់បឋមបណ្តោះអាសន្ននេះ គឺខ្ញុំមិនមានបញ្ហានោះទេ ហើយខ្ញុំបានលើកឡើងការរក្សាសិទ្ធ ប្រសិនបើមានករណីណាកើតឡើងនៅក្នុងអង្គសវនាការ លើ

អង្គសេចក្តី ។ ចៅក្រម ឡាវ៉ែន៍ គាត់និយាយថាគាត់យល់ស្រប ដូច្នេះហើយទើបយើងពិភាក្សាគ្នាត្រង់ចំណុចនេះនៅពេលនេះ ដែលនៅពេលនោះខ្ញុំបានលើកឡើងអំពីការរក្សាសិទ្ធិរបស់ខ្ញុំ ហើយបានទទួលការយល់ព្រមពីអង្គជំនុំជម្រះសាលាដំបូង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗ មេធាវី អាឡាំវ៉ែនណី ។

**លោក អាឡាំង វ៉ែនណី៖**

សូមអរគុណ សូមគោរព លោក លោកស្រីចៅក្រម ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី នេះជាចំណុចមួយដែលខ្ញុំចង់បញ្ជាក់ជូន បានបង្ហាញ-- មិនបង្ហាញអំពីចេតនាអាក្រក់អំពីគោលបំណងនេះទេ ដែលយើងលើកឡើងនូវវិធាននេះ ។ ប៉ុន្តែ មូលដ្ឋានដែលយើងលើកឡើងអំពីសវនាការបឋមនោះ គឺថាវាមានសេចក្តីសម្រេចទាក់ទងទៅនឹងភាពអាចទទួលយកបាន គឺថាពីប្រហែលបួន ប្រាំខែមកហើយកន្លងទៅហើយ គឺថាយើង-- យើងជាអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺថាវិធាន២៣.៦ នៃវិធាននោះចែងថា អង្គហេតុថាដើមបណ្តឹងរដ្ឋប្បវេណីដែលអាចទទួលយកបានៗនោះ គឺថាផ្តល់ឲ្យសិទ្ធិឲ្យគាត់នោះគឺថាអាចចូលរួមនៅក្នុងសវនាការមកភ្នំពេញ ហើយថាក្នុងដំណាក់កាលណាមួយ ដែរថាមកផ្តល់សក្ខីកម្ម ហើយពួកគេមិនចាំបាច់ស្បថទេ ដោយសារគេជាភាគីនៃដំណើរការនីតិវិធី ។

អ៊ីចឹង អនុលោមតាមការអាននូវវិធានផ្ទៃក្នុងតាមសុច្ឆន្ទៈនោះ គឺយើងយល់យ៉ាងច្បាស់អំពីបញ្ហានៃភាពអាចទទួលយកបាន ដែលលើកឡើងដោយភាគីគឺថាមិនអាចលើកឡើងនៅដំណាក់កាលក្រោយទៀតទេ ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងបានប្រើសិទ្ធិដែលបានទទួលជាច្រើនខែមកហើយ ដូច្នេះគឺថាពីរបីអាទិត្យមុនពេលបញ្ចប់ នោះគ្រាន់តែយើងទទួលការជំទាស់ថា អ្នកឯងមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីគ្រប់គ្រាន់ ។ អ៊ីចឹង ហើយគេដូចជាយកសិទ្ធិពីគាត់ទៅវិញ អ៊ីចឹងវិធាន១០០ ខ្ញុំយល់គឺថាមានកម្រិតនៃភាពមិនច្បាស់លាស់ គឺថាមានសិទ្ធិរហូតទាល់តែមានសេចក្តីសម្រេច គឺថាលោកមានសិទ្ធិនឹងតទល់ថាមានសិទ្ធិជំទាស់ទៅរឿងហ្នឹង ។

[១៥:៣៨:៣៥]

ប៉ុន្តែ ដល់នៅពេលនេះមេធាវីទើបតែលើកឡើង ។ គប្បីតែបញ្ជាក់ទាំងពីមុន គឺថាមិនមានអ្វីបានប្រែប្រួលគឺថាបញ្ហាសាច់លោហិតនោះ គឺថាបានបញ្ជាក់ហើយគឺថា វាមានបញ្ហាការបកប្រែបន្តិចបន្តួច

ប៉ុន្តែគួរតែលើកពេលនោះ ។ ប៉ុន្តែលោកលើកឡើងនៅពេលនេះ គឺថាដើមបណ្ដឹងរដ្ឋប្បវេណីគឺថាត្រូវបានទទួលស្គាល់ជាច្រើនខែរួចមកហើយ អ៊ីចឹងគឺថាដោយមានការទទួលស្គាល់នោះ លោកបានដកស្រង់ ហើយខ្ញុំក៏បានដកស្រង់ ដែរថាលោកបានទទួលស្គាល់ថាមានការរក្សាសិទ្ធិ នោះគឺជាសិទ្ធិហើយនិងការប្ដេជ្ញារបស់មេធាវីការពារ មិនមែនរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ។

នៅថ្ងៃទី២៦ ដែលលោកបានបញ្ជាក់សក្ខីភាពពីបារាំងតាមវីដេអូ *ខនហ្វើរិន* នោះគឺថាគាត់បាន-- អ៊ីចឹងហើយគឺមានដំណាក់កាលផ្សេងៗជាច្រើននៅក្នុងដំណាក់កាលនេះ លោក រូ ។ យើងមានហើយគឺថាការទទួលស្គាល់ជាបណ្ដោះអាសន្ន ថាជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺទៅលោក អ៊ូ បាទ ។ លោក អ៊ូ ស៊ីវ៉ាត់ គឺថានៅឆ្នាំ២០០៩ គេបាន-- គាត់បានទទួលដំណឹងថាចំណុចទីពីរ ។ ឥឡូវនេះគឺថា លោកត្រូវបានទទួលស្គាល់ជាបណ្ដោះអាសន្នថាអ្នកដាក់ពាក្យសុំតាមបណ្ដឹងរដ្ឋប្បវេណីរហូតទល់តែមានសវនាការបឋមទាក់ទងទៅនឹងរឿងសម្រេចរបស់លោក ។ ហើយគិតថាបន្ទាប់ពីនោះគឺមាត្រាវិធាន៨៣ នៃវិធានផ្ទៃក្នុងសម្រេចនឹងទៅតាមហ្នឹង។ នេះហើយជាករណីមួយដែលយើងយល់នេះជាជំនឿជឿជាក់របស់យើង យើងមានការទទួលស្គាល់ជាបណ្ដោះអាសន្ន ហើយនៅសវនាការបឋមប្រសិនបើភាគីនានាចង់ធ្វើមតិយោបល់ គឺថាបន្ទាប់មកអង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេច នឹងហើយគឺថាអាចនឹងផ្ដល់សិទ្ធិទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ។ អ៊ីចឹងហើយគឺថាមិនអាចប្រើពេលឥតប្រយោជន៍របស់អង្គជំនុំជម្រះទេ ។ ប៉ុន្តែ មិនមែនមានន័យថាយើងមិនអាចទទួលយកបានតាំងពីពេលនោះមកនោះទេ អ៊ីចឹងយើងប្រើជាមូលដ្ឋានរបស់យើងគឺវិធានផ្ទៃក្នុងនេះឯង ។

[១៥:៤១:១៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំនឹងឆ្លើយតប គឺថា ចម្លើយរបស់យើងគឺថានៅក្នុងវិធាន១០០ នៃវិធានផ្ទៃក្នុង ដែលអង្គជំនុំជម្រះបានជម្រាបហើយ នៅក្នុងកថាខណ្ឌទីមួយ គឺអង្គជំនុំជម្រះអាចធ្វើសេចក្ដីសម្រេចទៅលើពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងភាពអាចទទួលយកបាន ឬមិនយកបាន ហើយនិងខ្លឹមសារទាក់ទងទៅនឹងពាក្យសុំហ្នឹង គឺថាសេចក្ដីសម្រេចហ្នឹងគឺថាស្ថិតនៅក្នុងសិទ្ធិរបស់អង្គជំនុំជម្រះ ។ ហើយ

សេចក្តីសង្កេតរបស់ខ្ញុំគឺបានលើកឡើងពីចំណុចនេះ ។ ខ្ញុំសូមបញ្ជាក់ឡើងវិញ គឺថាពីម្សិលមិញ ល្ងាចម្សិលមិញ យើងទទួលបានឯកសារគឺថាកំណត់បញ្ជាក់អំពីដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងមិនឃើញជាបញ្ហានោះទេ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ថា បើបណ្តែតបណ្តោយឲ្យមេធាវីតទល់គ្នារបៀបនេះ ប្រហែលជាបួនប្រាំថ្ងៃទៀតក៏មិនចប់ដែរ លើកលែងតែពេលដេកលក់ប៉ុណ្ណោះ ។ ហើយផែនការនៃអង្គសវនាការនៅរសៀលនេះ ជាការចាំបាច់ត្រូវសម្រាកត្រឹមម៉ោងបី សាមសិបនាទី ដើម្បីដកឃ្លាទៅប្រជុំពិភាក្សាធ្វើសេចក្តីណែនាំដល់ភាគីក្នុងការដេញដោលចំពោះសាក្សីបញ្ជាក់អំពីអត្តចរិតរបស់ជនជាប់ចោទ ថាតើទៅតាមវិធីណា? ធ្វើរបៀបណា ដើម្បីឲ្យវាត្រឹមត្រូវបំផុតនៅក្នុងដំណើរការរកយុត្តិធម៌នៅក្នុងរឿងក្តីនេះ?

ហេតុដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ដំណើរការសវនាការលើកទៅបន្តនៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹកដូចសព្វដង ។

អនុរក្សមន្ទីរឃុំឃាំងឲ្យជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ៕

*[សវនាការផ្អាកនៅម៉ោង១៥:៤៤នាទី]*